ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 30-Jan-2012, 09:12
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១២**

**ម៉ោង ០៩:០៩ នាទី**

**សវនាការលើកទី២២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ធូ មណី (បម្រុង)
ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ណាតាចា វ៉ិចស៊ែល រីសឺ
*(Ms. Natacha WEXELS-RISER)*
លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី
លោក សេង ប៊ុនឃាង
លោក ឌេល លីសាក់ (*Mr. Dale LYSAK*)
លោក ពេជ្រ សម្បត្តិ

**ជនជាប់ចោទ៖**

លោក នួន ជា
លោក ខៀវ សំផន
លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក ហ្សាក់ វែកហ្សេស

*(Mr. Jacques VERGES)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោក សំ សុគង់

លោកស្រី ជេត វណ្ណលី

កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍ *(Ms.Phillipine SUTZ)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោកស្រី ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក អាង ឧត្តម | ខ្មែរ |
| កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍ | បារាំង |
| លោក ហ្សាក់ វែកហ្សេស | បារាំង |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក សំ សុគង់ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ូណូហ្វត | បារាំង |
| លោកស្រី ប្រាក់ យុត | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅលោកស្រី ថ្នាក់ យុត** (TCW-542)

សួរដោយលោក សេង ប៊ុនឃាង ផ្ដើមពី ........ ទំព័រ ១៤
សួរដោយលោក ឌេល លីសាក់ ផ្ដើមពី ........ ទំព័រ ២១
សួរដោយលោក សំ សុគង់ ផ្ដើមពី ........ ទំព័រ ៧១
សួរដោយកញ្ញា ហ្វីលីពីន ស៊ុតហ្ស៍ ផ្ដើមពី ........ ទំព័រ ៨០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៩:២៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

ក្រឡាបញ្ជី ឌុច ផារី តើនៅថ្ងៃនេះមានវត្តមានសាក្សី ប្រាក់ យុត ដែលយើងបានធ្វើការស្តាប់សក្ខីកម្មកាលពីម្សិលមិញដោយសហព្រះរាជអាជ្ញាដែរឬទេ?

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សាក្សី ប្រាក់ យុត គាត់មានវត្តមាននៅថ្ងៃនេះ ហើយគាត់នៅក្នុងបន្ទប់រង់ចាំៗ ការកោះហៅពីអង្គជំនុំជម្រះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោក ផារី។

មុននឹងបន្តកិច្ចដំណើរការពិភាក្សាដេញដោលស្តាប់សក្ខីកម្មសាក្សី ប្រាក់ យុត តើភាគីនៃរឿងក្តីនេះមានបញ្ហាអ្វីចង់លើកឡើងនៅចំពោះមុខអង្គជំនុំជម្រះដែរឬទេ? បើមានលើកឲ្យហើយ ដើម្បីអង្គជំនុំជម្រះយកគិតពិចារណា ដើម្បីសម្រេចជាមុនៗនឹងអញ្ជើញសាក្សីចូលមកកាន់សាលសវនាការ។

សូមអញ្ជើញលោកមេធាវីការពារក្តីរបស់លោក អៀង សារី។

[០៩:១១:១០]

**លោក ម៉ៃខល កាណាវាស៖**

អរុណសួស្តីលោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព និងសួស្តីអស់លោក លោកស្រីនៅក្នុងបន្ទប់ និងក្រៅបន្ទប់សវនាការ។ ខ្ញុំមានសំណើសុំ ប៉ុន្តែខ្ញុំនឹងលើកឡើងដោយខ្លីទេ ដោយសារតែយើងមានសាក្សីមួយរូប កំពុងតែរង់ចាំដើម្បីបញ្ចប់សក្ខីកម្មរបស់យើងនៅថ្ងៃនេះ។ សហព្រះរាជអាជ្ញាកាលពីម្សិលមិញ ក្រៅពីសួរសំណួរនាំមុខនៅពេលដែលដេញដោលសំណួររបស់គាត់ គឺខ្ញុំនឹងលើកប្រធានបទនេះនៅពេលឆាប់ៗ។

[០៩:១១:៤៣]

យើងខ្ញុំយល់ឃើញថា ការលើកសំណួររបស់គាត់នោះ ក្រៅពីចំណុចដែលខ្ញុំលើកឡើងនោះ គឺវានៅក្រៅវិសាលភាពនៃសវនាការដំណាក់កាលដំបូងទៀត។ តើយ៉ាងម៉េចដែរ?

នៅក្នុងសេចក្តីសង្ខេបរបស់សហព្រះរាជអាជ្ញា គឺគាត់បានលើកឡើងកថាខណ្ឌនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះពាក់ព័ន្ធទៅនឹងសាក្សីរូបនោះ ដែលគាត់នឹងគ្រោងសាកសួរ។ សេចក្តីសង្ខេបដែលគាត់ដកស្រង់នោះ គឺបានដាក់ជូនចំពោះមុខរបស់អង្គជំនុំជម្រះនៅថ្ងៃទីម្ភៃ-- នៅខែធ្នូ ឆ្នាំ២០១០។ នៅពេលដែលយើងមើលនូវសេចក្តីសង្ខេបនោះ គឺសហព្រះរាជអាជ្ញាហាក់ដូចជាកំពុងតែគិតសាក្សីនឹងផ្តល់សក្ខីកម្មពីកថាខណ្ឌ ១៦៨ ដល់ ១៧៧, ១៧៨ ដល់ ២០៤, ៧៤០ ដល់ ៧៤៤, ៧៤៥ ដល់ ៧៩០។ ដូច្នេះនេះគឺជាកថាខណ្ឌដែលគាត់ចង់ចង្អុលយោង។

នៅក្នុងដីកាបំបែកសំណុំរឿងរបស់អង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់លាស់ដោយក្នុងនោះបានភ្ជាប់ឧបសម្ព័ន្ធ ឯកសារE124/7.2 ដោយនៅក្នុងនោះ ជម្រាបភាគីអំពីលក្ខណៈនៃការជំនុំជម្រះលើកទីមួយ។ យើងខ្ញុំយល់ឃើញថា លើកលែងតែចំពោះអ្នកជំនាញដែលគាត់នឹងមកផ្តល់សក្ខីកម្មទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូលតែម្តង។ សាក្សីទាំងឡាយក្រៅពីអ្នកជំនាញនោះ គឺត្រូវតែតាំងសំណួរចំពោះតែសវនាការដំណាក់កាលដំបូងប៉ុណ្ណោះ លើកលែងតែភាគីយើងទាំងអស់គ្នាធ្វើការស្នើសុំផ្សេងពីនេះ ដោយសារតែហេតុផលល្អជាងនេះ។

[០៩:១៣:៥៣]

ចំណុចនេះ គឺបានលើកឡើងនៅក្នុងសវនាការរៀបចំរបស់យើងរួចមកហើយ យើងខ្ញុំយល់ឃើញថា យើងខ្ញុំគួរ-- ភាគីគួរតែស្នើសុំ ដាក់ពាក្យស្នើសុំការអនុញ្ញាតថា ហេតុអ្វីបានជាខ្លួនចង់សួរសាក្សីរូបនេះនៅក្រៅវិសាលភាពនៃសវនាការដំណាក់កាលដំបូង។ នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ នៅក្នុងទំព័រទីពីរ នៅក្នុងនោះអង្គជំនុំជម្រះបានលើកឡើងថា មិនអនុញ្ញាតឲ្យសួរសំណួរក្រៅវិសាលភាពដំណាក់កាលដំបូង លើកលែងតែដំណាក់កាលក្រោយតែប៉ុណ្ណោះ។ នៅថ្ងៃទី២៨ ខែវិច្ឆិកា លោក លោកស្រីចៅក្រមបានចេញអនុស្សរណៈ E141/12 ដែលក្នុងនោះកត់សម្គាល់ថា ខ្ញុំសូមដកស្រង់កថាខណ្ឌនោះ “អង្គជំនុំជម្រះសូមរំឭកទៅដល់សហព្រះរាជអាជ្ញាថា ការដេញដោលសំណួរនោះគឺកម្រិតតែទៅលើអង្គហេតុក្នុងដំណាក់កាលសវនាការដំបូងតែប៉ុណ្ណោះ”។

[០៩:១៥:០២]

ប្រសិនបើសាក្សីណាមួយចង់-- សហព្រះរាជអាជ្ញាចង់ដេញដោលសំណួរ ក្រៅពីវិសាលភាព

សំណុំរឿង០០២/០១ នោះ គឺសហព្រះរាជអាជ្ញាត្រូវតែដាក់សំណើសុំទៅអង្គជំនុំជម្រះ ដើម្បីសម្រេចអំពីផលប្រយោជន៍នៃដំណើរការសវនាការដែលមានប្រសិទ្ធភាព។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះសូមជូនដំណឹងថា នៅពេលដែលយើងទទួលពាក្យសុំនោះ គឺយើងនឹងសម្រេចថាតើទទួល ឬក៏មិនទទួល? ឯកសារនេះ គឺចុះថ្ងៃទី២៨ ខែវិច្ឆិកា។

[០៩:១៥:៤៧]

នៅថ្ងៃទី២៩ ខែវិច្ឆិកា ឯកសារ E145 អង្គជំនុំជម្រះ ចេញអនុស្សរណៈមួយទៀត។ នៅក្នុងទំព័រទីបីនៃអនុស្សារណៈនោះ អង្គជំនុំជម្រះបានបញ្ជាក់ថា មិនមាន មិនអនុញ្ញាតឲ្យមានការតាំងសំណួរណាក្រៅវិសាលភាពនៃសវនាការដំណាក់កាលដំបូងនោះទេ។

ដូច្នេះហើយ យើងឃើញថាអង្គជំនុំជម្រះ មិនត្រឹមតែច្បាស់ទេ គឺច្បាស់ដូចកញ្ចក់អ៊ីចឹង បញ្ជាក់យើងរួមមកហើយ ប្រាប់ទៅដល់ភាគី ថាតើអង្គជំនុំជម្រះចង់បានអ្វីពីភាគីពាក់ព័ន្ធទៅនឹងការតាំងសំណួរទៅកាន់សាក្សី។

ដូច្នេះ ខ្ញុំបានិនិយាយថា គឺភាគីគួរតែធ្វើការរៀបចំខ្លួន ដុះខាត់ខ្លួនឲ្យបានជាក់លាក់ ដើម្បីគោរពទៅតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ។

ដូច្នេះ យើងខ្ញុំលើកឡើងថា នៅក្នុងករណីនេះ គឺសហព្រះរាជអាជ្ញា ឬភាគីមិនបានកំណត់ និងគោរពទៅតាមសេចក្តីសម្រេចនោះទេ ចំពោះសាក្សីរូបនេះ។

ម្សិលមិញសហព្រះរាជអាជ្ញាលើកឡើង តាំងសំណួរពាក់ព័ន្ធទៅនឹងទំនប់ ប្រឡាយ។ ដូច្នេះហើយ វាបង្ហាញយ៉ាងច្បាស់ថា សក្ខីកម្មរបស់សាក្សីហាក់ដូចជាស្ថិតនៅក្រៅដែនកំណត់ និងវិសាលភាពនៃការជំនុំជម្រះដំណាក់កាលដំបូង។ វាអាចមានការពន្យល់ពីខាងសហព្រះរាជអាជ្ញា ក៏ប៉ុន្តែសក្ខីកម្មសំណួរទាំងឡាយនោះ គឺព្យាយាមទាញយកចម្លើយនៅក្រៅវិសាលភាព។ ហើយយើងក៏មិនដឹងថាតើគាត់ចង់ទាញសក្ខីកម្មនៅក្រៅវិសាលភាពនេះ គឺដើម្បីចេតនាអ្វីដែរនោះទេ ពីសាក្សីរូបនេះ?

[០៩:១៧:២៧]

យើងគួរ-- យើងត្រូវតែបញ្ជាក់យ៉ាងច្បាស់ថា យើងបានដឹងមុនពេលចេញដីកាបំបែកសំណុំរឿង នៅពេលដែលរឿងក្តីកំពុងស៊ើបអង្កេត មានចម្លើយសាក្សីដែលផ្តល់ជូនដោយសាក្សីរូបនេះ។ អ្នកស៊ើបអង្កេតនៅពេលនោះ គឺគាត់មិនដឹងថា អង្គជំនុំជម្រះនឹងបំបែកសំណុំរឿងនោះទេ។

ដូច្នេះចម្លើយរបស់សាក្សីនោះ រូបនេះ វាអាចមានព័ត៌មានមានតម្លៃទៅដល់សហព្រះរាជអាជ្ញា

និងភាគីដទៃទៀតដែលព័ត៌មានទាំងអស់នោះនៅក្រៅវិសាលភាពនៃសវនាការដំណាក់កាលដំបូង។

ដូច្នេះសាមញ្ញបំផុតនោះ គឺយើងមិនមែនថា យើងមិនអាចយោងទៅលើចម្លើយរបស់សាក្សីនោះទេ ក៏ប៉ុន្តែត្រូវតែសុំការអនុញ្ញាតពីអង្គជំនុំជម្រះ ប្រសិនបើចង់សួរក្រៅវិសាលភាពដំណាក់ដំបូងនៃសវនាការនេះ។

[០៩:១៨:២៥]

ដូច្នេះយើងខ្ញុំស្នើសុំដោយគោរពថា អង្គជំនុំជម្រះគួរតែចេញដីកាបង្គាប់ទៅដល់ភាគីគួរតែគោរពទៅតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ។ នៅថ្ងៃនេះយើងឃើញថាសហព្រះរាជអាជ្ញាអង្គុយនៅទីនេះដល់ទីបីនាក់នោះ ហើយធ្វើយ៉ាងណានោះ គឺអង្គជំនុំជម្រះគួរតែធ្វើការសម្របសម្រួល និងបង្គាប់ទៅដល់សហព្រះរាជអាជ្ញាឲ្យធ្វើការគោរពទៅតាមសេចក្ដីសម្រេច។

ដូច្នេះ វាមិនមែនជាការរៀបចំដោយចៃដន្យ ការសួរដោយចៃដន្យដើម្បីចូលទៅដល់វិសាលភាពក្រៅការជំនុំជម្រះដំណាក់កាលដំបូងនោះទេ។ វាចំណាយពេលរបស់យើង នៅពេលដែលយើងឡើងឈរជំទាស់បែបនេះ។

[០៩:១៩:០៧]

នៅពេលដែលយើងក្រោកឈរដូច្នេះ គឺគេនឹងលើកឡើងទៀតហើយថា មេធាវីការពារក្ដីនឹងធ្វើការរារាំង ធ្វើការជំនុំជម្រះក្ដីមិនឲ្យដំណើរការទៅមុខ។ ក៏ប៉ុន្តែវាជាពេលមានតម្លៃរបស់យើង ដែលថាភាគីគាត់លើកឡើងនៅក្រៅវិសាលភាពនៃការជំនុំជម្រះរបស់យើង។

ដូច្នេះ គឺភាគីនៅពេលដែលតាំងសំណួរ គឺនៅពេលបើគាត់ដឹកនាំការតាំងសំណួរនាំមុខនោះ គឺគាត់គួរតែដឹងឲ្យបានច្បាស់ ហើយធ្វើយ៉ាងណា គាត់យល់ ហើយអនុញ្ញាតឲ្យភាគីផ្សេងឆ្លើយតបទៅនឹងសំណួររបស់គាត់ ជំទាស់ទៅនឹងសំណួររបស់គាត់។ នេះមិនមែនជាការរារាំងការជំនុំជម្រះនោះទេ។

កាលពីម្សិលមិញ គឺខ្ញុំមិនលើកឡើងក្រោកឈរជំទាស់ដោយសារតែខ្ញុំមិនចង់ស្ទាត់គាត់ ហើយអ្វីដែលខ្ញុំធ្វើកាលពីម្សិលមិញ គឺដើម្បីចង់ឲ្យសហព្រះរាជអាជ្ញានុំង គាត់ដឹងខ្លួន ហើយធ្វើការកែតម្រូវឲ្យគាត់ដំណើរការឲ្យមានប្រសិទ្ធភាពឡើងវិញទៅតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ។

ដូច្នេះ ប្រសិនបើសហព្រះរាជអាជ្ញានៅតែធ្វើអ៊ីចឹងទៀត គឺខ្ញុំនឹងក្រោកឈរជំទាស់ៗភ្លាមៗតែម្ដងនឹងដោយម៉ឺងម៉ាត់។

[០៩:២០:០៩]

ចំណុចនេះ ដូចគ្នាគឺខ្ញុំសូមជំទាស់ផងដែរ ទៅលើសំណួរនាំមុខ កាលពីម្សិលមិញសំណួរនាំមុខគឺសន្មតទៅលើអង្គហេតុ ហើយបន្ទាប់មកដឹកមុខសាក្សី ហើយគាត់ថាប្រហែលមាននៅក្នុងសេចក្តីសម្រេច សេចក្តីប្រកាសរបស់សាក្សីដូច្នេះ ដូច្នោះ។ ហើយបន្ទាប់មកគឺគាត់ប្រើចម្លើយទាំងអស់នោះគឺបង្កើតជាសំណួរដើម្បីឲ្យសាក្សីនិយាយ។ យើងខ្ញុំសូមជំទាស់សំណួរនាំមុខគ្រប់ទាំងអស់ ជាពិសេសនៅពេលដែលសំណួរទាំងឡាយនោះ គឺសួរឡើងជាលក្ខណៈស្នើឲ្យសាក្សីនិយាយតែម្តង។ ដូច្នេះហើយគឺខ្ញុំសូមថ្លែងអំណរគុណអង្គជំនុំជម្រះដែលបានផ្តល់វេទិកា ពេលវេលាមកឲ្យខ្ញុំលើកឡើង។

ខ្ញុំដឹងថា សហព្រះរាជអាជ្ញាគាត់ចង់ឆ្លើយតបទៅលើចំណុចនេះ ហើយគាត់ប្រហែលជាអាចពន្យល់ថាតើសំណួរពាក់ព័ន្ធទៅនឹងទំនប់ប្រឡាយនោះ គឺវាចូលទៅក្នុងដំណាក់កាលសវនាការដំបូងតាមរបៀបណា ហើយវាស៊ីសង្វាក់ទៅនឹងកថាខណ្ឌណាមួយនៅក្នុងដីកាបញ្ជូនទៅជំនុំជម្រះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងព្យាយាមលើកឡើងដោយសង្ខេប ខ្ញុំពិតជាឯកភាពថាសហមេធាវីការពារក្តីគឺគាត់មិនចង់ធ្វើការស្តាត់យើងនៅពេលម្សិលមិញ ហើយមេធាវីការពារក្តីគឺត្រូវតែគោរពតួនាទីរបស់ខ្លួនឲ្យបានប្រុងប្រយ័ត្ន មើលទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលវាស្ថិតនៅក្នុងដំណាក់កាលសវនាការវគ្គដំបូង។ ជាពិសេសគឺត្រូវផ្តោត នៅពេលដែលយើងផ្តោតទៅលើការតាំងសំណួររបស់យើងគឺ សាក្សីរូបនេះ ដែលបានដាក់បញ្ចូលនៅក្នុងបញ្ជីរបស់យើង គឺដោយសារតួនាទីរបស់គាត់នៅតំបន់ និងស្រុក។

[០៩:២២:២២]

ដូចដែលអង្គជំនុំជម្រះបានជ្រាបហើយកថាខណ្ឌ៦៤ ទៅដល់៧១ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះគឺពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធ។ ហើយចំពោះកថាខណ្ឌ៧២ គឺពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធនៃការធ្វើទំនាក់ទំនងដែលស្ថិតនៅក្នុងការជំនុំជម្រះរបស់យើង។ កថាខណ្ឌទាំងអស់នោះ គឺវាពាក់ព័ន្ធទៅនឹងអំណាចរបស់ភូមិភាគ ស្រុក និងតំបន់។ ការទំនាក់ទំនងបញ្ជូនគោលនយោបាយពីតំបន់ទៅភូមិភាគទៅស្រុក...។ល។

ដូច្នេះហើយ នៅក្នុងនោះក៏យើងឃើញពាក់ព័ន្ធទៅនឹងការធ្វើទំនាក់ទំនងពីឃុំ ស្រុក តំបន់

ភូមិភាគ។ ជាឧទាហរណ៍ កថាខណ្ឌ៦៨ រួមមានអង្គហេតុដូចតទៅ៖ កថាខណ្ឌ៦៨ នៃដីកាបញ្ជូនរឿងជំនុំជម្រះ "ការអនុវត្តនូវសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម គឺបានបញ្ជូនទៅដល់តំបន់ ភូមិភាគ។ គោលនយោបាយរបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍គឺបញ្ជូនទៅតំបន់ស្វ័យត និងទៅតាមតំបន់ឯករាជ្យផ្សេងៗដើម្បីធ្វើការអនុវត្តតាម។ ផ្ទុយមកវិញឃុំ ត្រូវរាយការណ៍មកវិញទៅដល់ឃុំ ទៅស្រុក តំបន់ បន្ទាប់មកតំបន់ទាំងឡាយគឺត្រូវរាយការណ៍ទៅកាន់ភូមិភាគ"។

[០៩:២៤:០០]

ខ្ញុំអាចបន្តអាននៅក្នុងកថាខណ្ឌនេះទៀតថា៖ "ចំពោះផែនការនៃការជំនុំជម្រះនេះ អង្គជំនុំជម្រះបានសូមឲ្យមានការបង្ហាញពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរដ្ឋបាលទូទៅ តើនរណាមានតួនាទីអ្វីខ្លះនៅក្នុងភូមិភាគ តំបន់ និងស្រុក ហើយរបបរាយការណ៍នោះ គឺគេធ្វើយ៉ាងម៉េច?"

ដូច្នេះ ដើម្បីសួរឲ្យឆ្លើយនិងបង្ហាញទៅលើចំណុចទាំងអស់នោះ យើងត្រូវតែចូលទៅដល់ចំណុចលម្អិត។ យើងមិនចង់ចូលទៅដល់ចំណុចលម្អិតនៃបទល្មើសដែលវាមិនស្ថិតនៅក្នុងផ្នែកនៃដំណាក់កាលបំដូងនោះទេ។

[០៩:២៤:៤៣]

ក៏ប៉ុន្តែដើម្បីជម្រាបជូនអង្គជំនុំជម្រះឲ្យបានជ្រាបនោះថា តើខាងភូមិភាគ ស្រុក និងតំបន់នោះគេធ្វើរាយការណ៍យ៉ាងម៉េច? ដូច្នេះហើយដើម្បីឆ្លើយតបទៅនឹងបញ្ហាចោទរបស់ខាងមេធាវីការពារក្តីនៅពេលដែលយើងសួរអំពីទំនប់នោះគឺ ដោយសារតែចម្លើយរបស់សាក្សីរូបនេះ គឺគាត់លើកឡើងថាតើមានការលំបាកអ្វីនៅទំនប់នោះរួមទាំងមានមរណភាព និងការអត់ឃ្លានផងដែរ។ ហើយថាតើគេរាយ-ការណ៍យ៉ាងម៉េចទៅថ្នាក់លើ។ ចំណុចនេះហើយដែលយើងបានសួរទៅលើចំណុចទំនប់។ យើងមិនមានចេតនាណាមួយសួរលម្អិតទៅដល់ការដ្ឋាន និងទំនប់ ដែលវាស្ថិតនៅក្នុងផ្នែកផ្សេងនៃដំណាក់កាលជំនុំជម្រះនោះទេ។ យើងមានកាតព្វកិច្ចក្នុងការបង្ហាញអំពីរចនាសម្ព័ន្ធរដ្ឋបាលនៅតាមតំបន់ និងផ្នែកផ្សេងៗនិងភូមិភាគផ្សេងៗ។

ដូច្នេះហើយចំណុចនេះ ខ្ញុំជឿថា ខ្ញុំបានបំភ្លឺទៅដល់អង្គជំនុំជម្រះ ដោយផ្អែកទៅលើចំណុចទាំងអស់នេះហើយ យើងនឹងមានសំណួរបន្ថែមទៀត ពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជន ហើយនិងបញ្ហានៃការតំណាងប្រជាជនដែលមានដាក់បញ្ចូលនៅក្នុងដំណាក់កាលដំបូងនៃសវនាការនេះ។

[០៩:២៦:០០]

ចំណុចមួយទៀតដែលខ្ញុំសូមបន្ថែមផងដែរនោះ គឺចំពោះសាក្សីណាក៏ដោយ វាសំខាន់ដែលយើងត្រូវសួរប្រវត្តិសាវតារអំពីសាក្សីនេះ ថាសាក្សីនេះនៅទីណាមុនពេលកម្ពុជាប្រជាធិបតេយ្យ ហើយមានតួនាទីអ្វីដែរ ដើម្បីឲ្យយើងមានបរិបទស្ថានភាពព័ត៌មានទូទៅ យើងសួរបន្ត។

ដូច្នេះហើយព័ត៌មានទាំងឡាយ សំណួរទាំងឡាយដែលយើងសួរ គឺយើងនឹងសួរនៃវិសាលភាពនៅក្នុងរយៈពេលដែលបានកំណត់។ ហើយឆ្លើយតបទៅនឹងសំណួររបស់មេធាវីការពារក្តី សំណួររបស់យើងសួរគឺពាក់ព័ន្ធ។ ខ្ញុំសូមបន្ថែមថា ហេតុផលដែលយើងចង់កោះហៅសាក្សីរូបនេះ គឺថាមានចំណុចមួយចំនួនដែលយើងមិនបានលើកឡើងនៅក្នុងភូមិភាគកណ្តាល។ យើងដឹងថា វាក៏មិនមែនជាផ្នែកមួយនៃរឿងក្តីនេះ ក៏ប៉ុន្តែវាសំខាន់។

ចំណុចនេះហើយ ដែលយើងចង់កោះហៅសាក្សីនេះមកផ្តល់ចម្លើយ លោកស្រីសាក្សីគឺជាកម្មាភិបាលនៅភូមិភាគនិរតី ដែលបន្ទាប់មកក៏ត្រូវបានគេបញ្ជូនទៅភូមិភាគកណ្តាលកាន់កាប់ក្នុងតួនាទីស្រុក និងតំបន់ នៅពេលដែលមានការបោសសម្អាតកម្មាភិបាលខ្មែរក្រហម។ ដូច្នេះហើយ វាពិបាកក្នុងការឲ្យគាត់រៀបរាប់រឿងរ៉ាវទាំងអស់នេះប្រសិនបើយើងមិនចូលទៅដល់ចំណុចដូចដែលយើងខ្ញុំបានសួរ។ ក៏ប៉ុន្តែយើងខ្ញុំមិនសួរលម្អិតទៅលើបញ្ហានៃការជម្លៀស ឬពាក់ព័ន្ធទៅនឹងដំណាក់កាលក្រោយនោះទេ។ យើងខ្ញុំយល់ឃើញថា ចំណុចដែលយើងសួរគឺវាពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរដ្ឋបាលនិងរបបរាយការណ៍។

ខ្ញុំគិតថា ចំណុចទាំងអស់នេះគឺបានឆ្លើយតប ហើយជាគុណប្រយោជន៍សម្រាប់អង្គជំនុំជម្រះពិចារណា។ ខ្ញុំសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូម១ឲ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកនូវមតិយោបល់ បញ្ចេញនូវមតិយោបល់របស់ខ្លួនមុន។ សូមអញ្ជើញ!

[០៩:២៨:០៣]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំនឹងនិយាយដោយសង្ខេប។ ដើមបណ្តឹងរដ្ឋប្បវេណីគឺយល់អំពីការកង្វល់របស់ខាងមេធាវីការពារក្តី ហើយដើមបណ្តឹងរដ្ឋប្បវេណីយល់ថា សហព្រះរាជអាជ្ញាគឺមិនទៅហួសពីដែនកំណត់នៃការសាកសួរនោះទេកាលពីម្សិលមិញនេះ គឺគាត់កម្រិតតែត្រឹមតែដំណាក់កាលទីមួយនៃសំណុំរឿង០០២នេះ។ ដូច្នេះ ខ្ញុំចង់ឲ្យវិធានត្រូវតែអនុវត្តយ៉ាងតឹងរ៉ឹងចំពោះភាគីទាំងអស់ ហើយសំណួររបស់

ដើមបណ្ដឹងរដ្ឋប្បវេណីក៏ត្រូវដូចគ្នាទៅនឹងការសាកសួរសាក្សីដែរ។

ហើយខ្ញុំបានចងចាំថា កាលពីលោកសាក្សី គឺកាលពីលោក ក្លាន រ៉ិត នេះ គឺថាមានការកម្រិតការសួរសំណួរត្រឹមតែដំណាក់កាលទីមួយ ដោយលើកឡើងអំពីការបោសសម្អាត ហើយគឺយើងមិនចង់ឲ្យហួសពីដំណាក់កាល០០១នេះទេ។ ដូច្នេះយើងចង់ឲ្យអនុវត្តនូវវិធាននេះឲ្យគ្រប់ភាគីទាំងអស់ រួមទាំងមេធាវីការពារក្ដី ដែលជាអ្នកលើកឡើងនូវបញ្ហានេះផងដែរ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី កាណាវ៉ាស!

**លោក ម៉ៃខល កាណាវ៉ាស៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។ អ្វីដែលខ្ញុំឮសុទ្ធតែជាការដោះសាប្រកបដោយឆ្លាតវាងវៃស្ថិតនៅខាងក្រៅវិសាលភាពនៃអ្វីដែលខ្ញុំលើកឡើង។ កថាខណ្ឌ៧៥ គឺថានិយាយអំពីការដ្ឋាននោះ តើការដ្ឋាននេះគឺនិយាយអំពីអ្វី? សហព្រះរាជអាជ្ញាបានលើកឡើងថា នេះគឺជាគោលបំណងនៃរចនាសម្ព័ន្ធរដ្ឋបាល។ ហើយបន្ទាប់មកគឺយើងចង់និយាយថា តើប្រជាជនគាត់មានអ្វីហូប? គាត់ទទួលបានរបបអាហារប៉ុន្មាន? ហើយពេលខ្លះត្រូវបានឈឺ ហើយបន្ទាប់មកក៏ស្លាប់។

[០៩:៣០:១០]

ទាក់ទងទៅនឹងរចនាសម្ព័ន្ធរដ្ឋបាលគឺមិនមាននិយាយទេ គោលបំណងនោះ គឺដើម្បីចាប់ផ្ដើម--បន្ទាប់មកបាននិយាយអំពីការដ្ឋានការងារជាក់លាក់ណាមួយ ព្រោះកាលណានិយាយបែបនេះ គឺដើម្បីឲ្យភាគីដទៃទៀតចូលរួមពាក់ព័ន្ធនៅក្នុងផ្នែកនេះ។ ខ្ញុំគិតថា ពួកគាត់មានបញ្ហានៅត្រង់ចំណុចនេះទាក់ទងទៅនឹងដីកាបំបែកដំណើរការនីតិវិធី ក៏ដូចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ថាតើបរិបទនេះវានឹងឈប់នៅត្រឹមណា បានយើងចូលទៅដល់ខ្លឹមសារនោះ?

បើសិនណាជាសហព្រះរាជអាជ្ញាមានសិទ្ធិអំណាច ឬក៏មានសិទ្ធិចូលនិយាយគ្រប់ផ្នែកទាំងអស់ គឺថាខ្ញុំចង់ដឹងពីដើមទីសិន ថាតើនិយាយអ្វីខ្លះ? ពីព្រោះនេះ គឺជាអត្ថប្រយោជន៍របស់សហព្រះរាជអាជ្ញា។ យើងចង់និយាយអំពីប្រព័ន្ធរាយការណ៍ ហើយបន្ទាប់មកយកកំណត់ហេតុស្ដាប់ចម្លើយសាក្សីយកសាកសួរ ដែលជាការហាមឃាត់ទៅនោះ។

ដូច្នេះ ប្រហែលជាពិបាកនឹងធ្វើសេចក្ដីសន្និដ្ឋានណាស់ ប៉ុន្តែចំណុចរបស់ខ្ញុំ ការអនុវត្តល្អប្រសើរនោះ គឺយើងត្រូវនិយាយឲ្យចំផ្នែកមួយ ហើយតើយើងនិយាយផ្នែកនោះ តើមានការអនុញ្ញាតទេ? បើមិន

ដូច្នេះទេ ខ្ញុំនឹងជំទាស់ហើយ។ ហើយដើម្បីឲ្យមានដំណោះស្រាយទៅលើបញ្ហាទាំងអស់នេះ នោះគឺប្រសិនណាជាអង្គជំនុំជម្រះយល់ឃើញថា សហព្រះរាជអាជ្ញាអាចនិយាយជុំវិញបរិបទទាំងអស់នេះ ខ្ញុំសូមសិទ្ធិជំទាស់គ្រប់ពេលវេលាទាំងអស់ ដោយសារខ្ញុំយល់ឃើញថាវាស្ថិតនៅវិសាលភាពនៃការដែលត្រូវពិភាក្សាដេញដោលគ្នា។ សូមអរគុណលោកប្រធាន។

[០៩:៣២:០៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីការពារក្តីលោក នួន ជា!

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំគ្រាន់តែសុំឆ្លៀតឱកាសនេះ គឺថាសូមគាំទ្រដល់សហការីរបស់ខ្ញុំ មេធាវីការពារក្តី មៃខល កាណាវាស។

[០៩:៣២:២៥]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣៤:៤៤]

**ប្រធានអង្គជំនុំ៖**

ជាបន្តមុននឹងប្រគល់វេទិកាទៅមេធាវីអន្តរជាតិការពារក្តីឲ្យលោក នួន ជា។ ខ្ញុំសូមប្រគល់ភារៈទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីធ្វើការបញ្ជាក់ទៅមេធាវី នួន ជា ជាមុនសិន។

សូមអញ្ជើញលោកស្រីចៅក្រម!

សូមអញ្ជើញលោកមេធាវីការពារក្តី នួន ជា ក្រោកឈរ!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ មេធាវីការពារក្តីលោក នួន ជា ខ្ញុំមិនចង់កាត់ផ្តាច់នូវសំណើសុំរបស់លោកទេ។ ខ្ញុំគ្រាន់តែចង់បញ្ជាក់អំពីនីតិវិធីសម្រាប់ឱកាសនៃដំណើរការនីតិវិធីនៅថ្ងៃមុខនោះ បើសិនណាមានអ្វីកើតឡើងដូចកើតឡើងព្រឹកមិញដូចមេធាវីការពារក្តីបានស្នើ-- អៀង សារី បានស្នើឡើងនោះសំណើនោះ គឺថាត្រូវឆ្លើយតបដោយសហព្រះរាជអាជ្ញា ក៏ដូចមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីឲ្យមានការបញ្ជាក់។ ហើយបន្ទាប់មកមេធាវីការពារក្តី អៀង សារី គាត់នឹងមានសិទ្ធិចុងក្រោយដើម្បីធ្វើការឆ្លើយតប។

ដូច្នេះខ្ញុំចង់បញ្ជាក់ថា នីតិវិធីសម្រាប់ថ្ងៃមុខនោះ សម្រាប់ពេលបច្ចុប្បន្ននេះខ្ញុំយល់ឃើញថា លោកបានគាំទ្រទៅដល់សំណើរបស់មេធាវីការពារក្ដីលោក អៀង សារី។ យើងបានពិចារណារឿងនេះហើយ ហើយប្រសិនណាមេធាវីការពារក្ដី ខៀវ សំផន ចង់គាំទ្រ ឬក៏ជំទាស់ ឬក៏និយាយបែបណានោះនោះមានន័យថា យើងឲ្យឱកាសមេធាវីពារក្ដីលោក អៀង សារី និយាយបន្តទៅទៀត។

ដូច្នេះសូមមេត្តាកម្រិតសំណើនូវសំណើ ឬយោបល់របស់លោក មិនមែនគ្រាន់តែឡើងមកធ្វើការគាំទ្រតែប៉ុណ្ណេះទេ។ នេះគ្រាន់តែជាការបញ្ជាក់សម្រាប់ដំណើរការនីតិវិធីទៅថ្ងៃមុខទៀត។

សូមអរគុណច្រើន។

[០៩:៣៦:៥៩]

**លោក ម៉ៃខល ផេសមិន៖**

អ្វីដែលខ្ញុំនេះ គឺខ្ញុំគ្រាន់តែគាំទ្រ នេះគាំទ្រមេធាវីការពារក្ដីនេះ គឺឥឡូវនេះខ្ញុំយល់ហើយ អ្វីដែលត្រូវអនុញ្ញាត និងអ្វីដែលត្រូវមិនអនុញ្ញាតនោះ។ ជាពិសេសពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ឆ្នាំ១៩៧៥។

សូមអរគុណលោកស្រីចៅក្រម។

**លោក ហ្សាក់ វែកហ្សេស៖**

គឺថាក្រុមមេធាវីការពារ ខៀវ សំផន នេះយល់ស្របជាមួយនឹងមេធាវីការពារផ្សេងទៀតទាំងអស់។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

គិតថា លោក កាណាវាស ប្រហែលជាលោកមិនមានអ្វីឆ្លើយតបតទៅទៀតទេ។

**លោក ម៉ៃខល កាណាវាស៖**

លោកស្រីចៅក្រមមិនមានអ្វីទៀតទេ។ សូមអរគុណច្រើនចំពោះមតិណែនាំ។

[០៩:៣៧:៥៦]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤០:១៨]

**ប្រធានអង្គជំនុំ៖**

បាទអរគុណដល់មេធាវីការពារក្ដីដែលបានលើកសំណើឲ្យអង្គជំនុំជម្រះបញ្ជាក់បញ្ហានេះ ហើយភាគីផ្សេងទៀតក៏បានតប។

បញ្ហានេះ ខ្ញុំនៅចងចាំថា កាលពីម្សិលមិញគឺក្នុងនាមប្រធានអង្គជំនុំជម្រះបានជម្រាបជូនដល់សហព្រះរាជអាជ្ញាយ៉ាងជាក់ច្បាស់ ហើយទន្ទឹមនឹងនេះក៏បានជម្រាបជូនដល់ភាគីផងដែរនៅក្នុងកិច្ចដំណើរការពិភាក្សាដេញដោលដែលអង្គជំនុំជម្រះបាននឹងកំពុងដំណើរការនាពេលនេះ គឺបានបញ្ជាក់ថាឲ្យផ្តល់នូវគំនិតបញ្ហាស្មារតីរៀងៗខ្លួន ដើម្បីពិនិត្យមើលអំពីព្រឹត្តិការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងអង្គហេតុ ដែលអង្គជំនុំជម្រះបានកំណត់ បំបែកយកមកធ្វើសវនាការនៅដំណាក់កាលដំបូងដែល ដូចមានចែងកំណត់នៅក្នុងឯកសារ E124/7.2។ នេះជាវិសាលភាពនៃអង្គហេតុដែលភាគីអាចពិនិត្យសិក្សាស្វែងយល់នៅក្នុងសំណុំរឿង ប្រវត្តិភស្តុតាងដែលខ្លួនយល់ឃើញថាមានការពាក់ព័ន្ធទៅនឹងព្រឹត្តិហេតុពាក់ព័ន្ធទៅនឹងអង្គហេតុដែលកំណត់នៅក្នុងវិសាលភាពនៅក្នុងឯកសារនេះ ដែលយើងហៅឈ្មោះម្យ៉ាងទៀតថា "សំណុំរឿង០០២/១"។

[០៩:៤២:២៦]

បញ្ហាទីពីរ គឺអង្គជំនុំជម្រះក៏បានជម្រាបបន្តទៀតដែរថា ភាគីដែលចូលរួមនៅក្នុងកិច្ចពិភាក្សាដេញដោលគួរតែត្រូវធ្វើការពិភាក្សាដេញដោលនេះ ចំពោះអង្គហេតុដែលបានចោទប្រកាន់តាមលំដាប់នៃលេខរៀង កថាខណ្ឌនីមួយៗដែលមានចែងនៅក្នុងឯកសារ E124/7.2 នេះ តាមលំដាប់នៃលេខរៀងពីតូចទៅធំ។ ហើយបើយើងពិនិត្យមើលឯកសារដែលចែង ដែលចងក្រងនេះ ឃើញថាអង្គហេតុទាំងអស់នេះគឺមានចំណងធំៗទៅទៀត។ ឧទាហរណ៍ ប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា, ឧទាហរណ៍ រចនាសម្ព័ន្ធរដ្ឋបាល រចនាសម្ព័ន្ធយោធា អង្គហេតុនៃសហឧក្រិដ្ឋកម្មរួម គោលនយោបាយដែលបានអនុវត្ត កម្រិតត្រឹមផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ ទីពីរ ជាដើម។ ហើយមានជាច្រើនទៀតនៅក្នុងនេះដែលបានចែង ហើយបានសរសេរយ៉ាងច្បាស់លាស់ដោយកម្រិតនៃលំដាប់លំដោយអង្គហេតុពីលេខតូចមកលេខធំ។ ការធ្វើដូច្នេះ គឺអង្គជំនុំជម្រះយល់ឃើញថា ទាំងភាគីនៅក្នុងការរៀបចំកិច្ចពិភាក្សាដេញដោលក៏ដូចជាគោលដៅដែលទទួលការសួរ សាកសួរដែរ គាត់នឹងងាយយល់ ហើយនិងអាចឆ្លើយតបបាន។ ដោយឡែក អង្គជំនុំជម្រះក៏ក្តាប់បាននូវបង្ហាញនុំងយ៉ាងជាក់ច្បាស់ ដោយពីលំដាប់ ពីបញ្ហាមួយ បរិបទមួយទៅបរិបទមួយទៀត។

[០៩:៤៤:៣៣]

ដូច្នេះនៅក្នុងកិច្ចដំណើរការដេញដោលនេះ គឺសូមភាគីមានការផ្ចិតផ្តង់នូវគំនិតបញ្ញាស្មារតីរបស់ខ្លួន ដើម្បីរៀបចំនូវការតាំងសំណួរឲ្យបានត្រឹមត្រូវតាមអ្វីដែលអង្គជំនុំជម្រះបានណែនាំរួចហើយ។

បញ្ហាទីពីរ គឺបញ្ហាខ្លះភាគីចូលលម្អិតជ្រៅទៅដល់អ្វីដែលវាអាចគិតថាមិនមានការពាក់ព័ន្ធ ប៉ុន្តែចំណុចខ្លះក៏ជាការមានប្រយោជន៍ ដែលពាក់ព័ន្ធទៅនឹងអង្គហេតុនេះដែរ។ ដូច្នេះការវិភាគ ការបកស្រាយវាអាស្រ័យទៅលើភាគី ហើយនិងអង្គជំនុំជម្រះប្រឹងប្រែង ដើម្បីអាចធ្វើការជំទាស់ដើម្បីអង្គជំនុំជម្រះពិចារណាទៅលើការជំទាស់ និងការសួរសំណួរណាមួយដែលក្រៅអង្គហេតុ ហើយអង្គជំនុំជម្រះក៏ដូចគ្នា ដើម្បីប្រឹងប្រែងក្នុងការពិនិត្យពិចារណាទៅលើបញ្ហានេះថា តើវាស្ថិតនៅក្នុងវិសាលភាពនៃការចោទប្រកាន់ដែរឬទេ?

[០៩:៤៥:៤៤]

ទោះបីយ៉ាងណាក៏ដោយបញ្ហា គឺវាជាការលំបាកមួយ មិនមែនជាការងាយស្រួលទេ ដោយសារអង្គហេតុដែលចោទប្រកាន់នៅក្នុងសំណុំរឿងក្តីនេះ វាមានវិសាលភាពនៅក្នុងក្របខ័ណ្ឌទូទាំងប្រទេស។ ហើយនៅក្នុងក្របខ័ណ្ឌនៃអំឡុងពេលច្រើនឆ្នាំ ការបង្ហាញនេះគឺតាំងមានពេលអំឡុង ទសវត្សរ៍ឆ្នាំ៥០-៦០ រហូតមកដល់ឆ្នាំ១៩៧៩។ ដូចជាប្រវត្តិបក្សកុម្មុយនីស្តដែលយើងបានធ្វើសវនាការរួចហើយ គឺមានកំណើតតាំងពីអំឡុងទសវត្សរ៍ឆ្នាំ៥០ ឯណោះ។ អ៊ីចឹងហើយអាចវិសាលភាពនៃការដេញដោលក៏វាអាចមានបញ្ហាខ្លះនៅក្នុងការដំណើរការសវនាការ។ អ៊ីចឹងហើយបានជាអង្គជំនុំជម្រះបានកំណត់ម្តងហើយម្តងទៀត ហើយសុំឱ្យភាគីមានការប្រឹងប្រែង ផ្តិតផ្តង់នូវគំនិតយោបល់របស់-- គំនិត បញ្ញា ស្មារតីរបស់ខ្លួននៅក្នុងការតាំងសំណួរឲ្យចំបញ្ហា ចំព្រឹត្តិការណ៍ដែលពាក់ព័ន្ធនឹងអង្គហេតុដែលបានចោទប្រកាន់នៅក្នុងឯកសារសំណុំរឿង០០២/០១។ ហើយដើម្បីជាការបញ្ជាក់បន្ថែមឲ្យកាន់តែច្បាស់សូមប្រគល់វេទិកាជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីមានមតិយោបល់បន្ថែម។ សូមអញ្ជើញ!

[០៩:៤៧:០៨]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ លោកប្រធានបានលើកឡើងអំពីវិធីសាស្ត្រទូទៅដែលតុលាការនឹងអនុវត្តទាក់ទងទៅនឹងសវនាការនាពេលបច្ចុប្បន្ន ជាពិសេសពាក់ព័ន្ធទៅនឹងការជំទាស់តវ៉ា។ តុលាការយល់ឃើញថាសំណួរដែលសួរចំពោះសាក្សីរូបនេះពាក់ព័ន្ធទៅនឹងបញ្ហាដែលមិនកំណត់បញ្ហាចំពោះប្រវត្តិសាវតារ គឺថាត្រូវសួរតែទាក់ទងទៅនឹងរចនាសម្ព័ន្ធ ការប្រាស្រ័យទាក់ទង ក៏ប៉ុន្តែកុំចូលទៅដល់ខ្លឹមសារនៃបញ្ហាទាំងអស់នេះ ដែលយើងនឹងត្រូវលើកយកនូវដំណាក់កាលសវនាការនាពេលបន្តបន្ទាប់។ ដូច្នេះ អង្គជំនុំជម្រះសូមរំឭកដល់មេធាវីការពារក្តីថា នេះគឺជាចំណុចសំខាន់ណាស់ ដែលមេធាវីការពារ

ក្ដីមិនសួរសួរសំណួរទាំងឡាយណាដែលនាំឲ្យគាត់ឈានចូលទៅដល់ខ្លឹមសារ ឬក៏ជំរុញទឹកចិត្ត អូសទាញគាត់ឲ្យនិយាយទៅដល់ខ្លឹមសារ ឬក៏មិនអនុញ្ញាតឲ្យសួរសំណួរនាំមុខ ដោយប្រភេទណាមួយឡើយ។

[០៩:៤៨:៣៨]

ប៉ុន្ដែដោយសារតាមតែចំណេះដឹងរបស់សាក្សី គឺថា-- ហើយដោយការយល់ដឹងរបស់គាត់ក្នុងរយៈពេលដ៏យូរនេះ គឺយើងចង់ឲ្យវត្តមានរបស់គាត់នេះគ្របដណ្ដប់ទៅលើបញ្ហាទាំងនោះ។ ដូច្នេះលោក កាណាវាស ខ្ញុំគិតថាខ្ញុំបញ្ជាក់ច្បាស់លាស់ចំពោះលោកហើយ ៗអង្គជំនុំជម្រះខិតខំប្រឹងប្រែងគ្រប់គ្រងទៅលើការចោទសួរទាំងឡាយតាមដែលខ្លួនធ្វើទៅបាន ដើម្បីចៀសវាងការជំទាស់តវ៉ារបស់មេធាវីការពារក្ដី ដែលវាអាចនាំឲ្យមានការពិបាកដោះស្រាយ។ ហើយសហព្រះរាជអាជ្ញាសូមចងចាំថាសូមចងចាំនូវមតិយោបល់ទាំងអស់នេះ ហើយអង្គជំនុំជម្រះក៏ខិតខំប្រឹងប្រែងគ្រប់គ្រងចំពោះបញ្ហាទាំងអស់នេះដែរ។ ហើយមេធាវីការពារក្ដីស្នើសុំឲ្យមានការត្រួតពិនិត្យ គ្រប់គ្រងទៅលើភាគីទាំងអស់ ហើយមេធាវីការពារក្ដីនេះ គឺមានបំណង-- គឺតាមឥរិយាបថធម្មតាមួយ គឺថាអនុញ្ញាតឲ្យមេធាវីការពារក្ដីសួរសំណួរណាដែលដើម្បីចៀសវាងកុំឲ្យធ្វើការប៉ះពាល់ទៅដល់សំណួររបស់សហព្រះរាជអាជ្ញាក៏ដូចជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ ប្រសិនណាជាសំណួរទាំងអស់នេះ វាចេញក្រៅពីរង្វង់នៃសវនាការ គឺមិនអនុញ្ញាត។ គឺសូមអរគុណច្រើន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីចៅក្រម។ ជាបន្តមន្ត្រីតុលាការអញ្ជើញសាក្សីចូលមកកាន់ទីកន្លែងផ្ដល់សក្សីកម្ម។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:៥១:៣៨]

**ប្រធានអង្គជំនុំ៖**

សួស្ដី លោកស្រី ប្រាក់ យុត។ នៅថ្ងៃនេះ អង្គជំនុំជម្រះបន្តស្ដាប់សក្ខីកម្មរបស់លោកស្រីជាបន្តទៀត ហើយមុននឹងផ្ដល់វេទិកាទៅសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសូមជម្រាបជូនទៅសាក្សី ហើយនិងសហព្រះរាជអាជ្ញាដែលនឹងឡើងធ្វើការតាំងសំណួរ សូមមានការប្រុងប្រយ័ត្នក្នុងការប្រើប្រាស់មីក្រូហ្វូនទាំងការបើកមុននឹងនិយាយ ហើយទាំងការដកឃ្លាបន្តិចមុននឹងតាំងសំណួរបន្ត។ បានន័យថាបង្អង់ ផ្អាកបង្អាក់បន្ដិចទៅ ដើម្បីឲ្យការបកប្រែភាសាបានប្រព្រឹត្តិទៅបានចប់ចុងចប់ដើម ដើម្បីមានការស្ដាប់អ្នក

ដែលចូលរួមកិច្ចដំណើរការសវនាការទាំងអស់គ្នា ទាំងជាតិ ទាំងអន្តរជាតិហ្នឹងអាចស្តាប់បាននូវខ្លឹមសារទាំងស្រុងនៃពាក្យពេចន៍នៃពាក្យសម្តីដែលភាគីបានតាំងសំណួរចំពោះសាក្សី ក៏ដូចជាសម្តីរបស់សាក្សីដែលបានឆ្លើយតបទៅនឹងសំណួរ។

ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាទៅសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[០៩:៥៣:៥៣]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** អរុណសួស្តីលោកស្រី។ ខ្ញុំនឹងបន្តសំណួរតាំងពីម្សិលមិញតទៀត។ នៅមុនថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ តើនៅពេលនោះអ្នកស្រីរស់នៅកន្លែងណា? ហើយអ្នកស្រីធ្វើអ្វីដែរ?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំកាលនោះនៅព្រំដែន។ ១៧ អេ្ហ? មុន១៧ អេ្ហះ? ខ្ញុំកាលហ្នឹងនៅ ខ្ញុំភ្លេចដែរ ដឹងនៅឯណាទេនេះ? ភ្លេច មិនដឹងថានៅទីកន្លែងណា។ ខ្ញុំដូចថាវាយូរពេក មិនបានចាត់អារម្មណ៍ទុក កាលមុន១៧។

**ស៖** បាទ អរគុណ។ តើលោកស្រីនៅតាកែវ ឬក៏នៅកំពត នៅពេលនោះ? តើលោកស្រីអាចចាំទេ?

**ឆ៖** មុននឹង១៧ មេសា ខ្ញុំភ្លេច មិនដឹងតាកែវ ឬនៅកំពត វាមិនបានច្បាស់លាស់បញ្ហាហ្នឹង។

**ស៖** ចុះបន្ទាប់ពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ហ្នឹង កន្លែងអ្នកស្រីរស់នៅហ្នឹង តើមានចំនួនប្រជាជនកើនឡើងដែរទេ?

**ឆ៖** មុននឹងថ្ងៃ១៧ មេសា ប្រជាជននៅកន្លែងខ្ញុំដូចមិនមានកើនអី នៅធម្មតា។

**ស៖** អ៊ីចេះ ខ្ញុំចង់បញ្ជាក់ថា មុន១៧ មេសា លោកស្រីរស់នៅកន្លែងណាមួយអ៊ីចឹង ដល់ពេលបន្ទាប់ពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥នោះ តើលោកស្រីបានអង្កេតឃើញថាមានប្រជាជនកន្លែងលោកស្រីរស់នៅហ្នឹងមានការកើនឡើងដែរទេ បន្ទាប់?

**ឆ៖** នៅថ្ងៃ១៧ មេសា ការរស់នៅរបស់ខ្ញុំ អង្កាល់នោះក៏ខ្ញុំមិនបានធ្វើស្ថិតិថាប្រជាជនកើន ឬមិនកើន ហើយក៏ប្រជាជននឹងមានចំណូចចូលក៏ខ្ញុំវាអត់បានចាប់អារម្មណ៍ទុកដែរ។

**សៈ** អ៊ីចឹងតើលោកស្រីមានឃើញអ្នកណាប្លែកដែលចូលមកកន្លែងលោកស្រីទេ? ប្រជាជនថ្មីប្រជាជនដែលមិនធ្លាប់រស់នៅកន្លែងលោកស្រីរស់នៅហ្នឹង?

[០៩:៥៦:៣០]

**ឆ៖** អង្កាល់ហ្នឹងខ្ញុំរស់នៅ ដូចមិនមានប្រជាជនប្លែកទេ អង្កាល់នុ៎ងខ្ញុំរស់នៅក្នុងភូមិដែរ ប៉ុន្តែដូចប្រជាជនរស់នៅជាប់ខ្ញុំហ្នឹងដូចមិនមានឃើញប្លែកអី ឃើញប្រជាជនខ្ញុំធ្លាប់ស្គាល់ហ្នឹង គឺគាត់នៅហ្នឹង អត់ឃើញមានប្រជាជនអីប្លែកផង។

**សៈ** អ៊ីចឹងអ្នកស្រីអាចជម្រាបបានទេថា នៅកន្លែងអ្នកស្រីរស់នៅនុ៎ងមានប្រជាជនរស់នៅមានប្រជាជនដែលហៅថា ១៧មេសា ឬក៏ប្រជាជនថ្មីអីទេ នៅកន្លែងនុ៎ង?

**ឆ៖** អត់។ ខ្ញុំអង្កាល់នុ៎ងរស់នៅដូចមិនទាន់ឮថា ប្រជាជន១៧មេសា ដប់អីខ្វ ដូចប្រជាជនរស់នៅជាមួយខ្ញុំ ខ្ញុំមិនទាន់បានដឹងដែរ។ ខ្ញុំអត់មានឃើញ ឮគេនិយាយអីដែរ។ ខ្ញុំមិនបានចាប់អារម្មណ៍និយាយទៅ មិនមែននិយាយថាក្នុងនេះ ខ្ញុំដោះសាទេ គឺការពិតគឺអ៊ីចឹង។ ខ្ញុំវាអត់មានដឹងថា ចេញមកកន្លែងណា? នៅកន្លែងណា? ខ្ញុំអត់ច្បាស់លាស់ដែរ ប៉ុន្តែនៅកន្លែងខ្ញុំរស់នៅ គឺអត់មានថា ១៧មេសាដប់អីអត់មានឃើញ។ អត់មានឮ ដឹងត្រង់ហ្នឹង ខ្ញុំដូចមិនសូវចាប់អារម្មណ៍បញ្ហាហ្នឹង។

[០៩:៥៧:៥៨]

**សៈ** លោកស្រីអត់ចាប់អារម្មណ៍ថា មានប្រជាជន១៧មេសា ឬក៏អត់អីចូលមកកន្លែងលោកស្រីទេ។ តើ អ៊ីចឹងថាតើលោកស្រីមានធ្លាប់ឮទេ ឈ្មោះដែលប្រជាជន ១៧មេសាហ្នឹង?

**ឆ៖** អត់ឮទេ ធ្លាប់ឮដែរតើ។

**សៈ** នៅពេលណាដែលលោកស្រីឮថាមានប្រជាជន១៧មេសានុ៎ង?

**ឆ៖** ៧៦ ចិតអីហ្នឹង។

**សៈ** ចុះនៅក្នុងកងចល័តដែលអ្នកស្រីគ្រប់គ្រង ដែលអ្នកស្រីបានបញ្ជាក់ជូនអង្គសវនាការពីម្សិលមិញថា លោកស្រីគ្រប់គ្រងកងចល័តហ្នឹងប្រហែលជាពីរ-បីរយនាក់។ នៅក្នុងកងចល័តនុ៎ងតើលោកស្រីដែលមានប្រជាជន ១៧មេសា ឬក៏ហៅប្រជាជនថ្មីហ្នឹងដែរឬទេ នៅក្នុងនុ៎ង?

**ឆ៖** នៅការគ្រប់គ្រងរបស់ខ្ញុំ នៅក្នុងពីរ-បីរយនាក់ហ្នឹង គឺក្រោយមកមានប្រជាជនថ្មីខ្លះដែរ។

[០៩:៥៩:២០]

**ស៖** បាទ សូមអរគុណ។ តើលោកស្រីដឹងទេ ថាប្រជាជនថ្មីខ្លះដែលនៅក្នុងក្រុមចល័តរបស់លោកស្រីហ្នឹងគេមកពីខាងណាដែរ?

**ឆ៖** អង្គាល់មកនៅជាមួយខ្ញុំក្នុងកងចល័ត បើតាមភូមិគាត់ឲ្យមក មកពីខាងភូមិៗឲ្យមកនៅជាមួយខ្ញុំហ្នឹង ភូមិនៅក្នុងហ្នឹងមានពីរបីភូមិដែរ ប៉ុន្តែភាគច្រើនគឺនៅរួមគ្នានៅជាមួយខ្ញុំហ្នឹង ប៉ុន្តែតាមភូមិបញ្ជូនឲ្យ។ មិនដឹងភូមិណាជាភូមិណាខ្លះទេ ខ្ញុំក៏មិនបានគិតគូរបញ្ហាហ្នឹងដែរ។

**ស៖** តើលោកស្រីបានដឹងទេថា មានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ឬក៏ពីទីប្រជុំជនផ្សេងៗ តើលោកស្រីបានដឹងបញ្ហានេះទេ?

**ឆ៖** បញ្ហាហ្នឹងខ្ញុំដឹងដែរ ប៉ុន្តែឮថាជម្លៀសប្រជាជនចេញពីក្រុង តែខ្ញុំនឹកឃើញថា រឿងនេះមិនមែនរឿងខ្ញុំទេ គឺខាងលើ។ អ៊ីចឹងខ្ញុំក៏ គ្រាន់ឮថាជម្លៀសៗ ខ្ញុំក៏មិនមានការចាប់អារម្មណ៍អីដែរ។ ព្រោះខាងលើអ្នកជម្លៀស ខ្ញុំនៅខាងក្រោម ខ្ញុំតាមតែឮគេថាជម្លៀសប្រជាជន ខ្ញុំក៏ឃើញប្រជាជននៅក្នុងហ្នឹងមានប្រជាជនមែន។ អាហ្នឹងប៉ុន្តែខាងខ្ញុំគឺអត់មានការចាប់អារម្មណ៍អីទេ ដោយខាងលើគាត់អ្នកធ្វើផែនការហ្នឹងណា៎។

**ស៖** តើលោកស្រីដឹងទេថា ថ្នាក់លើដែលធ្វើហ្នឹងធ្វើយ៉ាងម៉េចខ្លះទៅ?

**ឆ៖** មិនដឹងធ្វើយ៉ាងម៉េចខ្លះ ខ្ញុំក៏មិនបានដឹង។

[១០:០១:៣៦]

**លោក ម៉ៃខល កាណាវាស៖**

លោក លោកស្រីចៅក្រម មុនពេលដែលខ្ញុំលើកឡើង ហើយមុនពេលដែលសួរអំពីថ្នាក់លើនេះគួរសហព្រះរាជអាជ្ញា គួរតែបង្ហាញជាមូលដ្ឋានទៅ ថាតើថ្នាក់លើនេះគឺយ៉ាងម៉េចដែរ? ហើយនរណាគេដែរ? ហើយជាជាងធ្វើការសន្និដ្ឋាន និងធ្វើសម្មតិកម្មទៅលើបញ្ហាថ្នាក់លើនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។ ពាក្យដែលថាថ្នាក់លើនេះគឺតំណាងសហព្រះរាជអាជ្ញាបានទទួលចម្លើយពីសាក្សី ដែលបញ្ជាក់ថា មានថ្នាក់លើបញ្ជាឲ្យធ្វើយ៉ាងដូច្នេះ។ ហើយចម្លើយដែលថ្នាក់លើ

នេះ គឺសំណួរមិនទាន់បានសួរទៅដល់ថាយ៉ាងណាទេ។ ទើបតែឆ្លើយតបទៅនឹងចម្លើយរបស់សាក្សីតែប៉ុណ្ណោះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី!

[១០:០២:៤៤]

**លោក ម៉ៃខល កាណាវាស៖**

តាមការកត់សម្គាល់កាលពីម្សិលមិញ ទោះបីជាមាននៅក្នុងចម្លើយក៏ដោយ ក៏មិនមែនថា មានសិទ្ធិក្នុងការបង្កើតជាមូលដ្ឋានសម្រាប់យកមកសួរនោះទេ។ ដូច្នេះហើយ ខាងសហព្រះរាជអាជ្ញាគួរតែសួរថា តើគាត់ធ្វើការទាក់ទងជាមួយនរណាគេ? ហើយថ្នាក់លើហ្នឹងគឺថ្នាក់លើយ៉ាងម៉េច? កម្រិតណា? នៅពេលដែលប្រើថ ថ្នាក់លើនេះ គឺប្រហែលជាគាត់ជាការស្នើសុំពីខាងសហព្រះរាជអាជ្ញាឲ្យប្រើពាក្យអ៊ីចឹងនោះទេ។ ដូច្នេះហើយគួរថា គួរតែបង្កើតជាមូលដ្ឋានទៅ ថាតើថ្នាក់លើហ្នឹង គាត់ជូនដំណឹងទាក់ទងត្រឹមកម្រិតណា? ថ្នាក់លើត្រឹមកម្រិតណា? ហើយប្រសិនបើគាត់ថា ថ្នាក់លើនោះគឺរួមទាំងអស់នោះ គឺគាត់គួរតែកំណត់លក្ខខណ្ឌឲ្យបានច្បាស់លាស់។ ដូច្នេះហើយគាត់គួរតែបញ្ជាក់។

អង្គជំនុំជម្រះយើងគិតថា យើងក៏មិនគួរធ្វើការសន្មតថា ថ្នាក់លើ ហ្នឹង គឺអ្នកដែលលើកំពូលផុតលេខនោះទេ ដើម្បីជាកំណត់ត្រាឲ្យបានត្រឹមត្រូវ ចម្លើយទាំងឡាយគឺគួរតែឆ្លើយពីសាក្សី ជាជាងការដកស្រង់ចេញពីចម្លើយយកមកសួរឲ្យសាក្សីឆ្លើយ។ ហើយយើងក៏មិនសួរសំណួរស្រដៀងៗដូចគ្នានេះដែរ។ សាក្សីមិនគួរលើកឡើងពាក្យជាក់លាក់ ហើយឲ្យសាក្សីនិយាយនោះឡើយ។ សហព្រះរាជអាជ្ញាគួរតែសួរថា សំណួរបើកចំហថាហេតុអ្វី? នរណាគេ? នៅពេលណា? ឬក៏ជាអ្វី? ដើម្បីឲ្យបានសាក្សីបានឆ្លើយ។ សូមអរគុណ។

[១០:០៤:២៤]

**ប្រធានអង្គជំនុំ៖**

ជំទាស់គ្មានប្រសិទ្ធភាព។ សហព្រះរាជអាជ្ញាអាចបន្តសំណួរបែបនេះបាន!

**លោក សេង ប៊ុនឃាង៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** តើលោកស្រីនៅចាំសំណួរដែរទេ? ខាងថ្នាក់លើហ្នឹងគាត់បញ្ជាឲ្យធ្វើអ្វី? យ៉ាងម៉េចខ្លះដែរទៅ?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំមិនសូវចាំសំណួរដែរ។ ថ្នាក់លើ ខ្ញុំដឹងថា ព្រោះខ្ញុំនៅខាងក្រោម ហើយខាងការជម្លៀសប្រជាជនមកពីក្នុងមកពីភ្នំពេញ មកពីតាមក្រុង ក៏ខ្ញុំមិនដឹងថាជម្លៀស ខ្ញុំអត់ដឹងដែរ អាហ្នឹងជារឿងការពិត។ ព្រោះខ្ញុំឆ្លើយ មិនមែនដោះសាដើម្បីខ្លួនខ្ញុំ តែខ្ញុំវាអត់ដឹងមែន។ មិនដឹងថា ជម្លៀសខាងលើហ្នឹងរបស់គាត់ គាត់ពិភាក្សាគ្នាទៅ ខ្ញុំវាអត់ដឹងមែន។ អាហ្នឹង ខ្ញុំនិយាយដោយការស្មោះត្រង់ទេនេះ ព្រោះការជម្លៀសមកនេះ ខ្ញុំគ្រាន់តែឃើញប្រជាជនមែន តែមិនដឹងខាងណាជម្លៀស ខ្ញុំវាមិនបានដឹងដែរ។ អានេះ ខ្ញុំសូមជម្រាបលោកដោយស្មោះត្រង់។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹង តើលោកស្រីដឹងទេ ថាគេជម្លៀសហ្នឹងធ្វើយ៉ាងម៉េច ដែលការយល់ដឹងរបស់លោកស្រីពេលនុ៎ង?

[១០:០៥:៥០]

**ឆ៖** ដឹងៗថា មកតាមថ្នល់អ៊ីចឹង តែនៅទីក្រុង ខ្ញុំមិនបានតាមដានទៅមើលអីទេ មិនដឹងថាដោះស្រាយឲ្យប្រជាជនចេញយ៉ាងម៉េច ខ្ញុំអត់ដឹងដែរ បើនៅខាងគាត់ដើរមកហូរហែអ៊ីចឹងៗ ខ្ញុំដឹងតែឲ្យខ្ញុំតាមដាននៅតាមក្រុង តាមអី ខ្ញុំអត់ដឹងទេ មិនដឹងថាចេញមកយ៉ាងម៉េច អ្នកជម្លៀសហ្នឹង អ្នកណា គឺខ្ញុំអត់ច្បាស់លាស់ទេ។ នេះ ខ្ញុំសូមជម្រាប អាហ្នឹង មិនមែននិយាយដោះសាទេ ខ្ញុំនិយាយពីរឿងការពិត ព្រោះខ្ញុំឃើញតែជម្លៀសមក ខ្ញុំចេះ-- អាហ្នឹង ធម្មតាខាងក្រោមចេះមាន ការថាជម្លៀសប្រជាជនមកហើយអ៊ីចឹង តែឲ្យដឹងផែនការខាងលើ ខ្ញុំអត់ដឹង។ នេះ សូមជម្រាបលោក។

[១០:០៦:៤៩]

**ស៖** បាទ សូមអរគុណលោកស្រី។ លោកស្រីបានថា បានដឹងមានការធ្វើដំណើរតាមផ្លូវរបស់ដែលជម្លៀសហ្នឹង តើលោកស្រីដឹងទេ ថាការធ្វើដំណើរតាមផ្លូវហ្នឹង វាមានការលំបាក ឬការងាយស្រួលអ្វីខ្លះទៅ?

**ឆ៖** ការហ្នឹង? មានការលំបាក មានការស្រួលអាហ្នឹង ឧទាហរណ៍ចេញមកហើយ ដូចថាវាធម្មតា មានការលំបាកខ្លះហើយ វាមិនដែលស្រួលទាំងអស់ទេ។

**ស៖** បាទ សូមអរគុណ។ តើលោកស្រីអាចដឹងទេ ថាលំបាកហ្នឹង លំបាកយ៉ាងម៉េចខ្លះ?

**ឆ៖** ការលំបាក ខ្ញុំឃើញ ធម្មតាមានកូនតូច កូនតាចអ៊ីចឹង ដើរមក វាមានក្តៅ មានត្រជាក់ តែប៉ុណ្ណឹង ខ្ញុំឃើញប៉ុណ្ណឹង។

**ស៖** តើការធ្វើដំណើរតាមផ្លូវហ្នឹង គេធ្វើដោយមធ្យោបាយអី ដើរ ឬក៏មានរថយន្ត ឬមានម៉ូតូ មានកង់? មានអីដែរទេ?

**ឆ៖** ការដើររបស់គាត់មានមធ្យោបាយរបស់គាត់ គាត់មានកង់ មានម៉ូតូ គាត់ជិះតាមហ្នឹងទៅ បើអត់ទេ គាត់ដើរ។

**ស៖** បាទ អរគុណ។ តើលោកស្រីដឹងទេ ថាការធ្វើដំណើរការតាមផ្លូវនោះ មានកម្លាំងណាមកតាមដើរអមដើម្បីឲ្យដើរខុសទិសដៅអីទេ?

**ឆ៖** ខ្ញុំកាលនោះ មិនបានតាមដានបញ្ហាហ្នឹងទេ។ ដឹងគាត់ដើរហ្នឹង មានកងពារ មានអី ខ្ញុំកាលហ្នឹង ខ្ញុំធ្វើការ ដូចថាមិនមែនការងារខ្លួនឯង ខ្ញុំមិនបានចាប់អារម្មណ៍ទេ មិនដឹងថាគាត់ដើរមានអ្នកណាជូន អ្នកណាអត់ ខ្ញុំមិនបានចាប់អារម្មណ៍ទុក។ អ៊ីចឹង ខ្ញុំការងារខ្ញុំផ្សេង ដូចថាខ្ញុំ ដូចថាជាប់ស្ទូងជាមួយប្រជាជនអ៊ីចឹង កាលហ្នឹង ខ្ញុំធ្វើស្រែធ្វើអីជាមួយប្រជាជនដែរហ្នឹង។ ហើយក៏មិនបានគិតគូបញ្ហាហ្នឹងដែរ។ មិនដឹងគាត់នាំហ្នឹងមក មានមនុស្សមានអី ម៉េចខ្លះ ក៏ខ្ញុំអត់បានចាប់អារម្មណ៍ ព្រោះខ្ញុំចាប់ធ្វើការជាមួយប្រជាជន ដូចថាខ្ញុំជាប់ស្ទូងស្រែ ស្ទូងអីដែរកាលនុ៎ង ឬមួយក៏ធ្វើអីផ្សេងៗទៀតទៅ។

[១០:១០:០៣]

**ស៖** តើលោកស្រីមានដឹងទេថា ប្រជាជនទាំងអស់នុ៎ង គាត់ចង់ចាកចេញទេ ឬក៏យ៉ាងម៉េចដែរ?

**ឆ៖** មិនដឹងថា គាត់ចង់ចាក មិនចង់ចាកចេញ បើគាត់-- ខ្ញុំមិនបានទៅជម្លៀស បញ្ហាដែលប្រជាជនផង។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ប្រសិនបើខ្ញុំសូមលើកឡើងដោយសង្ខេប គឺយើងខ្ញុំគិតថា មិនគួរសួរសំណួរឲ្យធ្វើកាន់ប៉ាន់ស្មានថា តើលោកស្រីគិតថាអ្នកផ្សេងហ្នឹងយល់យ៉ាងម៉េច? គិតយ៉ាងម៉េច? យើងមិនគួរធ្វើឧបមានសំណួរ សួរសំណួរឧបមានវិធីបែបនេះទេ។ ដូច្នេះសហព្រះរាជអាជ្ញាគួរតែជ្រាបពីបញ្ហានេះ។

[១០:១០:៥១]

**ប្រធានអង្គជំនុំ៖**

បាទ ជំទាស់មានប្រសិទ្ធិភាព សហព្រះរាជអាជ្ញាគប្បីប្រើសំណួរឲ្យបានត្រឹមត្រូវតាមនីតិវិធី។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** បាទ សូមអរគុណ។ នៅអំឡុងពេលដែលអ្នកស្រីធ្វើការនៅស្រុកកំពតនោះ តើលោកស្រីមានដឹងទេថា មានប្រជាជននៅស្រុកកំពតហ្នឹងមានត្រូវបានជម្លៀសចេញណាផ្សេងទៀតដែរទេ?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំនៅធ្វើការស្រុកកំពត តែការជម្លៀសប្រជាជនចេញទៅណាមកណា ខ្ញុំក៏អត់បានដឹងដែរ ព្រោះអាហ្នឹងលេខាគាត់អ្នកចាត់ចែង ហើយខ្ញុំគ្រាន់ជំនួយការទេ ការពិតខ្ញុំអត់មានទៅចាត់ចែងជំនួសគាត់ទេ។ ហើយមិនដឹងថា ប្រជាជននៅស្រុកកំពតហ្នឹង នៅខេត្តកំពតហ្នឹង ជម្លៀសទៅណាខ្លះក៏ខ្ញុំអត់បានដឹងទេ។ ព្រោះខ្ញុំនៅស្រុកកំពតមែន តែបើឲ្យខ្ញុំដឹងថាប្រជាជនហ្នឹងគេជម្លៀសថ្ងៃណា ខែណា? ខ្ញុំអត់ដឹង។ នេះនិយាយដោរឿងពិត មិនមែនកុហកទេ គឺខ្ញុំនិយាយដោយស្មោះត្រង់ ព្រោះខ្ញុំនៅកន្លែងហ្នឹងមែន តែគាត់មានលេខាស្រុក ខ្ញុំអម ដូចថាខ្ញុំជំនួយការ។ ហេតុនេះការចាត់ចែងរបស់គាត់មិនដឹងថាគាត់រៀបរយយ៉ាងម៉េច? គាត់ជួនកាលគាត់និយាយជាមួយខ្ញុំ ជួនកាលគាត់មិនបាននិយាយជាមួយខ្ញុំ។ ខ្ញុំអត់ដឹងដែរ។

**ស៖** លោកស្រីបានបញ្ជាក់ថា លោកស្រីមិនដឹងថា មានការជម្លៀសចេញពីថ្ងៃណា ខែណា លោកស្រីមិនដឹងទេ។ ប៉ុន្តែតើលោកស្រីដឹងថាមានទេ ការជម្លៀសចេញ?

[១០:១២:៤៩]

**ឆ៖** ចាស មានជម្លៀសចេញតើ!

**ស៖** បាទ អរគុណ។ តើពេលនោះនៅស្រុកកំពតរបស់លោកហ្នឹងមានការបង្កើតឲ្យមានសហករណ៍អីទេ?

**ឆ៖** មានបង្កើតសហករណ៍តើ!

**ស៖** បាទ សូមអរគុណ។ តើនៅពេលណាដែលគេចាប់ផ្ដើមបង្កើតសហករណ៍ដំបូងគេ? លោកស្រីនៅចាំបានទេ?

**ឆ៖** ខ្ញុំចាំអត់បានដែរក្នុងពេលបង្កើតសហករន៍មុនគេ។ វាភ្លេចដែរ វាយូរពេកហើយ មិនដឹងថ្ងៃណា ខែណា ឆ្នាំណាទៀត។ ខ្ញុំភ្លេច វាអត់បានកត់ត្រាទុក ហើយយូរពេកខ្ញុំក៏មិនដែលបានរំឭកពីកើត

សហករណ៍ កើតអីហ្នឹងមិនដឹងខែណា ឆ្នាំណា។ ហើយម្យ៉ាងទៀតក៏ពេលនេះ ខ្ញុំក៏វាចាស់ទៅ ការចងចាំក៏ភ្លេចដែរ។ មិនដឹងថ្ងៃណា ខែណា។

**ស៖** បាទ អរគុណ។ លោកស្រីមិនដឹងថ្ងៃណា ខែណា ប៉ុន្តែតើនៅពេលដែលអំឡុងពេលដែលលោកស្រីនៅក្នុងខេត្តកំពតហ្នឹងមែនទេ?

**ឆ៖** ខ្ញុំនៅ មិនដឹងថ្ងៃខែមែន តែខ្ញុំនៅខេត្តកំពតហ្នឹងឯង អ្ហ៎! នៅស្រុកកំពត មិនមែនខេត្តកំពតទេ។

**ស៖** តើលោកស្រីដឹងទេថា អ្នកណាជាអ្នកបញ្ជាឲ្យបង្កើតសហករណ៍នេះ?

[១០:១៥:០០]

**ឆ៖** ដឹង ខ្ញុំសូមជម្រាបថា កាលហ្នឹងដឹងអ្នកណាបង្កើតទេ ប៉ុន្តែយើងចេះតែធ្វើទៅព្រោះ ដូចថាខ្ញុំនៅក្នុងស្រុកកំពតអ៊ីចឹង។ ដូចថាមេស្រុកហ្នឹង គេហៅមកប្រជុំអ៊ីចឹងទៅ ប្រាប់ថាឥឡូវយើងបង្កើតធ្វើបាយសហករណ៍អ៊ីចឹងទៅ យើងធ្វើតាមមេស្រុកដែរ មិនដឹងថាគាត់យកផែនការមកឲ្យយើងធ្វើ មិនដឹងនៅ និងកន្លែងណា ខ្ញុំមិនបានដឹងដែរ ព្រោះខ្ញុំក្រោមការដឹកនាំរបស់គាត់ដែរ ហើយគាត់បង្កើត ក៏គាត់ហៅខ្ញុំមកប្រាប់ ថាឥឡូវនៅក្នុងស្រុកយើងត្រូវបង្កើតសហករណ៍។ គាត់និយាយទៅ យើងចេះតែធ្វើតាមគាត់។

**ស៖** បាទ សូមអរគុណលោកស្រី។ លោកប្រធាន ខ្ញុំអត់សំណួរហើយ ហើយជាបន្តសូមឲ្យសហការីរបស់ខ្ញុំបន្តសំណួរទៀត។ សូមអរគុណ។

[១៥:១៥:៥៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

អរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

អរុណសួស្តីលោកស្រីសាក្សី មុនពេលខ្ញុំសួរទៅលើចំណុចសំខាន់ៗ ខ្ញុំចង់សួរថា តើលោកស្រីមានចាំទេ ថាលោកស្រីបានផ្តល់ចម្លើយនៅក្នុងការសម្ភាសមួយចំនួន ដែលអ្នកពីមន្ត្រីតុលាការនេះបានសួរលោកស្រីនៅឆ្នាំ២០០៩ តើមានទេ?

**ឆ៖** គាត់បានសង្កេត ខ្ញុំហ្នឹងអ្វេះ? គាត់បានទៅសម្ភាសខ្ញុំតើ។

**ស៖** ចាតើលោកស្រីចាំថា មានផ្តល់ចម្លើយទៅអ្នកស៊ើបអង្កេតពីការិល័យសហព្រះរាជអាជ្ញាសហចៅក្រមស៊ើបអង្កេតនៅក្នុងឆ្នាំ២០០៩ ដែរឬទេ?

**ឆ៖** ខ្ញុំបានផ្តល់មតិការស៊ើបអង្កេតទៅដល់លោកអង្កេតហ្នឹងដែរតើ។

**ស៖** តើនៅពេលដែលផ្តល់ចម្លើយឲ្យអ្នកស៊ើបហ្នឹង តើលោកស្រីនិយាយដោយស្មោះត្រង់ដែរឬទេ?

**ឆ៖** អង្កាល់ដែលខ្ញុំផ្តល់សំណួរ-- ចម្លើយហ្នឹង ខ្ញុំនិយាយដោយស្មោះត្រង់តើ។

[១០:១៧:៣៨]

**ស៖** ចាតើនៅពេលនោះ គេសួរលោកស្រីហ្នឹងគឺប្អូនដង មែនដែរឬទេ?

**ឆ៖** គេសួរប្អូនដង។

**ស៖** ពេលសម្ភាសម្តងៗ ពេលគេសួរម្តងៗនោះ តើគេឲ្យលោកស្រីមើលកំណត់ហេតុហ្នឹងឡើងវិញទេ អាកំណត់ហេតុដែលគេកត់ត្រាចម្លើយរបស់លោកស្រីហ្នឹង?

**ឆ៖** គាត់មើលឲ្យខ្ញុំស្តាប់តើ។ ខ្ញុំអត់បានមើលខ្លួនឯង ព្រោះខ្ញុំអក្សរអត់សូវចេះ។

**ស៖** ដូច្នេះ អ្នកស៊ើបអង្កេតហ្នឹងគឺអានចម្លើយរបស់លោកស្រីនៅពេលសម្ភាសហ្នឹង ជូនលោកស្រីស្តាប់ មែនដែរឬទេ?

**ឆ៖** ចាស ពេលខ្ញុំសម្ភាសហើយ គាត់បានអានឲ្យខ្ញុំស្តាប់។

**ស៖** តើលោកស្រីមានផ្តិតមេដៃនៅលើកំណត់ហេតុនៃការសម្ភាសនោះ ដើម្បីបញ្ជាក់ថាអ្វីដែលបានកត់ត្រាហ្នឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** ចាស ខ្ញុំបានផ្តិតមេដៃ កត់ត្រាបានត្រឹមត្រូវ។

**ស៖** នៅពេលថ្មីៗនេះ តើលោកស្រី តើគេមានអានកំណត់ហេតុនេះសាជាថ្មីឲ្យលោកស្រីស្តាប់ទេនានាពេលថ្មីៗមុនពេលលោកស្រីផ្តល់ចម្លើយនៅតុលាការនេះ?

**ឆ៖** ខ្ញុំ ពេលថ្មីៗនេះ គាត់បានអានសំណួរឲ្យខ្ញុំស្តាប់ដែរ ប៉ុន្តែសំណួរខ្លះក៏ខ្ញុំចាំ សំណួរខ្លះក៏ខ្ញុំវាភ្លេចការចងចាំដែរ ខ្ញុំមិនចាំបានទាំងអស់ ប៉ុនគាត់បានអានឲ្យខ្ញុំស្តាប់ដែរ។

[១០:២០:០៦]

**ស៖** គេអានឲ្យស្តាប់នៅក្នុងអាទិត្យនេះ ឬក៏នៅក្នុងខែធ្នូ នៅពេលលោកស្រីបានមកផ្តល់ចម្លើយ

កាលពីចុងឆ្នាំ ខែធ្នូនោះ?

**ធ៖** កាលអាទិត្យមុន។

**ស៖** នៅពេលដែលគេអានឲ្យស្តាប់នោះ ថាតើលោកស្រីមានស្តាប់ថាមានព័ត៌មានណាមួយមិនត្រឹមត្រូវដែរឬទេ?

**ធ៖** ខ្ញុំបានស្តាប់តាមសំណួរដែលខ្ញុំឆ្លើយ គឺត្រឹមត្រូវតើ ខ្ញុំមើល អ៎!គាត់អានមក ខ្ញុំពិនិត្យមើលគឺត្រឹមត្រូវ។

**ស៖** ខ្ញុំចង់សុំសួរដើម្បីឲ្យលោកស្រីបំភ្លឺឡើងវិញ ថាតើលោកស្រីរស់នៅទីណាដែរ តាំងពីពេលដែលលោកស្រីចូលរួមបដិវត្តន៍តាំងពីឆ្នាំ៧០ រហូតមកដល់របបកម្ពុជាប្រជាធិបតេយ្យ ហើយមានតួនាទីអ្វីដែរ? នៅកាលពីម្សិលមិញ លោកស្រីបានលើកឡើងថា លោកស្រីបានចូលបដិវត្តន៍នៅក្នុងឆ្នាំ១៩៧០ ហើយតើលោកស្រីរស់នៅទីណាដែរ នៅក្នុងពេលដែលចូលបដិវត្តន៍នោះ?

[១០:២១:៣៩]

**ធ៖** ខ្ញុំសូមជម្រាបថា ខ្ញុំចូលបដិវត្តន៍ឆ្នាំ៧០ មក ខ្ញុំនៅកំពត ហើយតាកែវ។ តែពីរខេត្តហ្នឹង។ ហើយដល់ឆ្នាំ៧៧ នេះ ខ្ញុំទៅនៅខេត្ត នៅភូមិភាគកណ្តាល នៅតំបន់៤១ នៅបានតែពីរខែទេ។ ក៏មានសភាពការណ៍ទៅ ចាប់ប្តីចាប់អី ខ្ញុំក៏បកមកវិញ។ ប៉ុននៅទីហ្នឹង គឺខ្ញុំមិនបាននៅតាកែវ តែចូលពី៧០ ខ្ញុំអត់បានធ្វើអីទេ នៅតាកែវ គឺគ្រាន់តែនៅធម្មតា។ តែបានទៅនៅខេត្តកំពតហ្នឹង ខ្ញុំបានកាន់កងចល័តកងអីទៅ យូរៗទៅ ខ្ញុំបានឡើងទៅជាសមាជិកតំបន់ទី៦។ ហើយនេះនៅបានពី៧៥ ខ្ញុំបានកាន់ឡើងសមា-- កិច្ចការនារីហ្នឹង គឺខ្ញុំធ្វើនៅកិច្ចការនារីតំបន់កំពតហ្នឹងបានឆ្នាំ៧៥។ ហើយក្រោយមក ខ្ញុំនៅខេត្តកំពត ពី៧៥, ៧៦, ៧៧ ហ្នឹង ក៏ខ្ញុំឡើងទៅនៅកំពង់ចាមបានតែពីរខែទេ។ ក៏មានសភាពការណ៍ ក៏ខ្ញុំបកមកវិញ។ សូមជម្រាបប៉ុណ្ណឹង។

[១០:២៣:៤៧]

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំចង់សួរអំពីកន្លែងនីមួយៗដែលលោកស្រីរស់នៅនោះ។ សួរម្តងមួយៗ។ នៅពេលដែលលោកស្រីចូលបដិវត្តន៍ឆ្នាំ៧០ ខ្ញុំស្តាប់ឮថាលោកស្រីរស់នៅខេត្តតាកែវ នៅពេលចូលបដិវត្តន៍ឆ្នាំ៧០ នោះ តើមែនដែរឬទេ?

**ធ៖** ចាស មែន។

**ស៖** ថាតើលោកស្រីនៅតែរស់នៅក្នុងត្រាំកក់ដដែល នៅដែលជាទីកន្លែងលោកស្រីកើតនោះ

មែនដែរឬទេ នៅក្នុងឆ្នាំនុ៎ង?

**ធ៖** ចាស រស់នៅកន្លែងទីកន្លែងកើតហ្នឹង។

**ស៖** តើលោកស្រីស្គាល់ទេ នរណាគេដែលជា តាម៉ុក ហ្នឹង?

**ធ៖** ខ្ញុំអត់ស្គាល់ដែរ គ្រាន់ឮ តាម៉ុកៗ ស្គាល់តែមុខគាត់។ នៅដូចថាជិតគ្នា ជួបជុំគ្នា គាត់ធ្វើការហ្នឹង ខ្ញុំស្គាល់។ តែស្រុកកំណើតគាត់ជា ខ្ញុំអត់ស្គាល់ទេ។

**ស៖** តើលោកស្រីដឹងថា តាម៉ុក នោះធ្វើអីដែរ នៅពេលលោកស្រីចូលបដិវត្តន៍ឆ្នាំ៧០ នៅត្រាំកក់នុ៎ង?

**ធ៖** ខ្ញុំមិនដឹងគាត់ធ្វើអី ខ្ញុំគ្រាន់ចូលមកនៅជាមួយ មិនមែននៅជាមួយ តាម៉ុក ណា ខ្ញុំនៅជាមួយអ្នកផ្សេង ដូចថាអ្នកធ្វើដូចគ្នា ប៉ុន្តែខ្ញុំចូលមក ខ្ញុំមិនដឹងថា តាម៉ុក គាត់នៅឯណា? ធ្វើអី? ខ្ញុំអត់ដឹងដែរ។

**ស៖** ចាតើលោកស្រីដឹងថា តាម៉ុក ហ្នឹងមកពីស្រុកជាមួយលោកស្រីដែរឬទេ?

**ធ៖** ខ្ញុំអត់ដឹង អត់ដឹងថា តាម៉ុក ហ្នឹងមកពីស្រុកជាមួយខ្ញុំទេ ខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំនៅជាងទងឯស្រុកត្រាំកក់ជាមួយគ្នាមែន តែខ្ញុំនៅឃុំខុសគ្នា ដឹងគាត់នៅឃុំណា? ខ្ញុំអត់ដឹងដែរ អត់ច្បាស់ដែរ។

[១០:២៦:០២]

**ស៖** តើនរណាគេ លោកស្រីនិយាយម្សិលមិញថា លោកស្រីផ្លាស់ទីលំនៅទៅកំពត ហើយបានចូលរួមជាសមាជិកតំបន់៣៥ នៅក្នុងឆ្នាំ១៩៧៤។ ខ្ញុំចង់ដឹងថា តើនរណាគេដែលជាអ្នកចាត់តាំងលោកស្រីចេញពីត្រាំកក់ ទៅតំបន់៣៥នុ៎ង?

**ធ៖** អង្កាល់ហ្នឹងមានណាទេអង្កាល់ហ្នឹង មិនមែន តាម៉ុក ឲ្យខ្ញុំទៅ មានតាណាទេ ដូចស្លាប់បាត់ហើយតាហ្នឹង គាត់ឲ្យខ្ញុំទៅកំពត។ ខ្ញុំអត់ច្បាស់ដែរ ឈ្មោះតាឲ្យខ្ញុំទៅហ្នឹង ធ្វើតំបន់កំពត ហ្នឹងមិនដឹងតាមួយណា បើគាត់ស្លាប់អស់ហើយ តាអស់ហ្នឹង។ មិនដឹងជាតាហ្នឹងឈ្មោះអីទេនេះ គាត់ស្លាប់បាត់ហើយហើយមិនដឹងឈ្មោះគាត់ទៀត។ ដូច តាថន អ៊ីចេះមិនដឹងទេ? ប៉ុន្តែឥឡូវគាត់ស្លាប់បាត់ហើយ។ គាត់ឲ្យខ្ញុំទៅនៅកំពត ឈ្មោះ តាថន អ៊ីចឹងហើយ គាត់ឲ្យខ្ញុំទៅនៅកំពត គឺឈ្មោះតាថន។ តែឥឡូវគាត់ស្លាប់តាំងពីយូរហើយ។

[១០:២៧:៤២]

**ស៖** លោកស្រីបានផ្តល់ចម្លើយថា លោកស្រីចូលបដិវត្តន៍ឆ្នាំ៧០ បានន័យថា នៅក្នុងឆ្នាំនុ៎ងលោកស្រីក្លាយជាសមាជិកនៃបក្សកុម្មុយនីស្តកម្ពុជាដែរ នៅក្នុងឆ្នាំ៧០នោះ ឬក៏ក្លាយជាសមាជិកបក្ស

នោះក្រោយឆ្នាំ៧០?

**ឆ៖** ខ្ញុំសមាជិកបក្ស មិនដឹងក្រោយឆ្នាំ៧០ អីមុនឆ្នាំ៧០ ទេនេះ ខ្ញុំវាមិនបានចាំដែរ។ វាយូរពេក មិនដឹងមុនឆ្នាំ៧០ អីក្រោយ។ ខ្ញុំដូចជានឹកអត់ឃើញដែរ មិនដឹងក្រោយឬមុនទេនេះ។

**ស៖** លោកស្រីបានឆ្លើយប្រាប់សហព្រះរាជអាជ្ញាជាតិថា លោកស្រីអត់ចាំអ្នកដែលខន្ទេសនាម នាំលោកស្រីចូលបក្សនោះទេ។ ក៏ប៉ុន្តែនៅពេលដែលអ្នកស៊ើបអង្កេតសួរលោកស្រី អ្នកស៊ើបអង្កេតពីការិយាល័យចៅក្រមស៊ើបអង្កេតទៅសួរសម្ភាសលោកស្រីនោះ គឺលោកស្រីបានឆ្លើយថា បងប្អូនជីដូនមួយរបស់លោកស្រីបានណែនាំលោកស្រីឲ្យចូលបក្សគឺលោក ហែម។ ថាតើនៅពេលដែលឆ្លើយនោះ ដែលថាបងប្អូនជីដូនមួយជាអ្នកណែនាំចូលបក្សនោះ តើពេលឆ្លើយការនុ៎ង គឺឆ្លើយការពិតដែរឬទេ?

[១០:២៩:១៨]

**ឆ៖** ខ្ញុំភ្លេចអ៊ីចឹង ខ្ញុំសូមអត់ទោស។ មាន តាហែម ហ្នឹងមែន ខ្ញុំវាច្រឡំបងប្អូនខ្ញុំជីដូនមួយគាត់ស្លាប់បាត់ហើយហ្នឹង។ ស្លាប់តាំងពីយូរ គាត់នាំខ្ញុំចូលហ្នឹងគឺ ប៉ុន្តែក្រោយមកគាត់ស្លាប់។ ប្រពន្ធគាត់ឈ្មោះយាយ គន់ កូនគាត់នៅរាល់ថ្ងៃ តែចំពោះគាត់ គាត់ស្លាប់ដោយជំងឺ។ ខ្ញុំសូមមានមតិប៉ុណ្ណឹង។

**ស៖** ថាតើ ហែម នុ៎ងធ្វើអ្វីដែរ? មានតួនាទីអ្វីដែរនៅពេលដែលគាត់ណែនាំលោកស្រីឲ្យចូលបក្សនុ៎ង?

**ឆ៖** គាត់អត់មាននាទីអីទេ គាត់គ្រាន់ថានៅក្នុងភូមិហ្នឹង គាត់មាននាទីដឹកនាំប្រជាជនមួយភូមិបន្តិចហ្នឹង តែគាត់ធ្វើប្រធានភូមិហ្នឹង។ អ៊ីចឹងខ្ញុំក៏ទៅនៅជាមួយគាត់។ ទៅនៅជាមួយគាត់អ៊ីចឹង គាត់នឹកឃើញក្មួយ។ ហើយការចូលបក្សខ្ញុំក៏មិនដឹងអី ខ្ញុំនៅតូចដែរអាយុបីបួនដណ្តប់ហ្នឹង មិនដឹងចូលយ៉ាងម៉េចដែរ ខ្ញុំចេះតែតាមគាត់ទៅ ម្យ៉ាងគាត់ប្រធានភូមិ។ អ៊ំខ្ញុំហ្នឹងណា។ ខ្ញុំអត់មានដឹងទេ។ មិនដឹងថាចូលបក្សហ្នឹងយ៉ាងម៉េចទេ។ ឥឡូវគាត់ស្លាប់អស់ហើយទាំងប្តីទាំងប្រពន្ធ នៅសល់តែកូនគាត់ទេ។

[១០:៣០:៥៤]

**ស៖** ខ្ញុំសូមអរគុណដែលលោកស្រីបញ្ជាក់លោក ហែម នេះ ដោយសារតែម្សិលមិញលោកស្រីថា លោកស្រីនៅក្មេងណាស់ នៅពេលដែលចូលបដិវត្តន៍។ លោកស្រីបានជម្រាបយើងខ្ញុំថា លោកស្រីនៅពេលនេះ គឺមានអាយុ ៦៧ឆ្នាំមកហើយ ហើយនៅពេលដែលលោកស្រីចូលបដិវត្តន៍នោះប្រហែលជាលោកស្រីមានអាយុ២៥ឆ្នាំ។ ថាតើនៅពេលលោកស្រីចូលបក្ស ខ្ញុំចង់ដឹងថា លោកស្រីមានអាយុ១៤, ១៥ឆ្នាំ ឬក៏ប្រហែល២៥ឆ្នាំ?

**ឆ៖** ខ្ញុំចាំមិនអស់ទេ មិនដឹងអាយុប៉ុន្មានដែរ។ ខ្ញុំសូមជម្រាបថា ខ្ញុំមិនចាំអស់ទេ ព្រោះវាយូរពេក មិនដឹងថាអាយុប៉ុន្មានអីប៉ុន្មានទេ កាលនោះ ខ្ញុំមិនដឹងថាអាយុខ្លួនឯងប៉ុន្មានទេ ចូលហ្នឹងខ្ញុំអត់ច្បាស់លាស់ខ្លួនឯងដែរ។ ហើយក៏វាយូរពេកហើយ ចេះតែភ្លេចទៅ ខ្ញុំមិនបានចាប់អារម្មណ៍យកមកទុកក្នុងខ្លួនទេ អាងតែហើយៗហើយ មានអីចាប់អារម្មណ៍ទៀត។ ហើយក៏មិនបានថា ខ្លួនឯងកាលនោះអាយុប៉ុន្មាន។ ដឹងអាយុប៉ុន្មានក៏អត់ចាំដែរ។

**ស៖** លោកស្រីបានប្រាប់អ្នកស៊ើបអង្កេតដែលទៅពីតុលាការថា លោកស្រីកើតនៅឆ្នាំ១៩៤៧ តើកើតនៅក្នុងឆ្នាំហ្នឹងមែនដែរឬទេ?

**ឆ៖** បើខ្ញុំដាក់ក្នុងហ្នឹងថា ៤៧ ៗហើយ ខ្ញុំមិនចាំអស់ដែរ។ ប្រហែលជាឆ្នាំ៤៧ ហ្នឹងដឹង។

**ស៖** លោកស្រីបានប្រាប់សហព្រះរាជអាជ្ញាជាតិផងដែរថា លោកស្រីមិនដែលគេឲ្យឯកសារឲ្យសិក្សាអំពីគោលនយោបាយរបស់បក្សនោះទេ។ ក៏ប៉ុន្តែនៅពេលដែលលោកស្រីឆ្លើយប្រាប់អ្នកស៊ើបអង្កេតតុលាការ លោកស្រីឆ្លើយថា សូមដកស្រង់សម្តី៖ "សំណួរ ថាតើមានការធ្វើទុក្ខបុកម្នេញ គេមានចែកសៀវភៅដែរឬទេ? ហើយនៅពេលនោះ ឆ្លើយនៅពេលនោះគឺ៖ មានគេចែកសៀវភៅ ហើយអត់មានសង្ឃ ព្រះសង្ឃនោះទេ"។ ឯកសារនេះគឺមានលេខឯកសារ D234/4 ឯកសារនេះមានលេខ ERN 00364084 ខ្មែរគឺ 00357514 បារាំងគឺ 00403127 លោកស្រីបានឆ្លើយនាពេលមុននោះថា បានទទួលសៀវភៅ។ តើលោកស្រីមានធ្លាប់បានទទួលសៀវភៅដែលនិយាយអំពីវត្ត អំពីព្រះសង្ឃដែរឬទេ?

[១០:៣៤:២៨]

**ឆ៖** កាលនោះខ្ញុំបានទទួលសៀវភៅឯកសារអំពីវត្ត ព្រះសង្ឃហ្នឹង គឺយើងអត់ទាន់មាន ហើយខ្ញុំក៏យកមកមើល គឺពិនិត្យតាមឯកសារ គឺអត់ឲ្យមាន មិនដឹងថាយ៉ាងម៉េច ខ្ញុំក៏មិនដឹងដែរ ថាមិនឲ្យមានវត្ត មានអីអ៊ីចឹង។ ហើយខ្ញុំក៏អត់មានថាចាប់អារម្មណ៍យ៉ាងម៉េចទេ គ្រាន់តែដឹងថា អត់ឲ្យមានវត្តមានអីហ្នឹង។ ខ្ញុំនឹកចិត្តថាមិនដឹងនិយាយថាម៉េចទៅ មិនឲ្យមាន ក៏មិនឲ្យទៅ។ ខ្ញុំអត់មានថា នឹកឃើញអ្វីទៅទៀតអត់ ដឹងថាមិន មានឯកសារមែន តែវាដូចថា ខ្ញុំថា បើខាងលើបើមិនឲ្យមានហើយ ខ្ញុំក៏មិនអាកាត់បាន អាហ្នឹងអ៊ីចឹង។ នេះសូមជម្រាប។

[១០:៣៥:២៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំយល់ឃើញថា ដល់ពេលឈប់សម្រាកហើយ ក៏ប៉ុន្តែខ្ញុំសូមឱ្យបញ្ជាក់បំភ្លឺចំនួនពីរដង។ នៅពេលនេះពីរដងហើយ ដែលខាងសហព្រះរាជអាជ្ញាបានយោងទៅលើចម្លើយដែលសាក្សីបានផ្តល់បានចម្លើយ។ ដូច្នេះ ខ្ញុំយល់ថា ចម្លើយដែលផ្តល់ជូនទៅដល់អ្នកស៊ើបអង្កេតនោះ គឺមិនមែនជាសក្ខីកម្មជាក់លាក់នោះទេ គ្រាន់តែជាការប្រកាសតែប៉ុណ្ណោះ។

ដូច្នេះហើយ ខ្ញុំសូមធ្វើការណែនាំ ថាតើសេចក្តីប្រកាសសាក្សីនេះ គឺជាសក្ខីកម្ម ឬក៏យ៉ាងម៉េច? ហើយនៅពេលដែលខ្ញុំបញ្ជាក់ដូច្នេះ ដើម្បីកុំឱ្យច្រឡំអំពីសក្ខីកម្មនៃសេចក្តីប្រកាសរបស់សាក្សី និងលក្ខណៈនៃឯកសារនោះផ្ទាល់។ ចំពោះពាក្យថា "*តេស្តស្ទីមុនី*" សក្ខីកម្មចម្លើយនោះ គឺថាផ្តល់ជូនចេញពីតុលាការនៅចំពោះមុខតុលាការ។ ដូច្នេះហើយអ្វីដែលលើកឡើងនៅក្នុងឯកសារនោះ គឺជាសេចក្តីប្រកាសនោះទេ ហើយអ្វីដែលធ្វើឡើងក្នុងសេចក្តីប្រកាសនោះ គឺមិនមានការធ្វើសម្បថនោះឡើយ។

[១០:៣៦:៤១]

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតធ្វើការឆ្លើយតប នៅពេលដែលគាត់ សាក្សីធ្វើការប្រកាសនោះ គឺក៏សាក្សីក៏បានធ្វើសម្បថនោះផងដែរ។ ហើយចំណុចដែលលើកឡើងដោយមេធាវីការពារក្តី គឺមិនត្រឹមត្រូវនោះទេ ដែលថាសាក្សីធ្វើសេចក្តីប្រកាសដោយមិនមានការធ្វើសម្បថនោះ។ នៅពេលដែលធ្វើសេចក្តីប្រកាសនៅក្នុងកំណត់ហេតុ គឺបានសម្បថយ៉ាងត្រឹមត្រូវ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី-- សហមេធាវីនាំមុខ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន គ្រាន់តែចង់បញ្ជាក់មួយ គឺថាគឺជាកំណត់ហេតុដែលធ្វើដោយសហចៅក្រមស៊ើបអង្កេតដែលជា-- ដែលមាននៅក្នុងសំណុំរឿង-- ដែលមាននៅដីកាដំណោះស្រាយ អ៊ីចឹងគឺថាយើងៗអាចរៀបរាប់ពីកំណត់ហេតុនេះ អ៊ីចឹងគឺថាជាផ្តល់សក្ខីកម្មដែលរបស់គាត់ ដែលគាត់បានធ្វើពេលមកចូលនៅទីនេះអ៊ីចឹង គឺថាមានតម្លៃយកជាការបាន។

**ប្រធានអង្គជំនុំ៖**

មានបញ្ហាអីចង់តបចុងក្រោយទេ លោក កាណាវាស!

**លោក ម៉ែខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមកែតម្រូវសេចក្តីប្រកាសអម្បាញ់មិញហ្នឹង គឺបានសម្បថមែន ក៏ប៉ុន្តែខ្ញុំនៅតែបញ្ជាក់ជំហរដដែល ថាវាជា “*ស្តេតមិន*” ជាសេចក្តីប្រកាស វាមិនមែនជាសក្ខីកម្មនោះទេ ដូច្នេះខ្ញុំនៅតែរក្សាជំហររបស់ខ្ញុំត្រង់ចំណុចនេះដដែល។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ម្ភៃនាទីចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីតុលាការជួយសម្របសម្រួលរកកន្លែងសម្រាកសមរម្យសម្រាប់សាក្សីរូបនេះ ហើយនិងឲ្យអញ្ជើញគាត់មកកាន់ទីកន្លែងដែលគាត់ត្រូវផ្តល់សក្ខីកម្មហ្នឹង ឲ្យបានមុនអង្គជំនុំជម្រះចូលមកកាន់អាសនៈ។

សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា!

[១០:៣៩:១៣]

**លោក ម៉ែខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ កូនក្តីរបស់ខ្ញុំគឺអស់កម្លាំង ដូច្នេះស្នើសុំឲ្យអង្គជំនុំជម្រះបង្គាប់ឲ្យគាត់នេះ ចូលទៅបន្ទប់រង់ចាំខាងក្រោម ហើយតាមដាននីតិវិធីពីខាងក្រោម។ ហើយខ្ញុំនឹងផ្តល់ជូនលិខិតបោះបង់សិទ្ធិចូលរួមដោយផ្ទាល់នៅទីនេះ ជូនអង្គជំនុំជម្រះនៅពេលក្រោយ ក្នុងពេលឆាប់ៗនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីជាតិការពារក្តី អៀង សារី!

[១០:៣៩:៤៨]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន ដោយសាមូលហេតុសុខភាព ជាពិសេសទាក់ទងនឹងជំងឺចង្កេះលោក អៀង សារី មិនអាចទ្រាំអង្គុយនៅទីនេះបាន។ លោកសូមតុលាការមេត្តាអនុញ្ញាត ហើយក៏សុំបោះបង់សិទ្ធិចូលរួមដោយផ្ទាល់ក្នុងសវនាការនេះ តែសូមចូលរួមសវនាការនេះ នៅបន្ទប់រង់ចាំខាងក្រោម។ ហើយយើងសូមអនុវត្តសិទ្ធិនេះ សម្រាប់រយៈពេលមួយថ្ងៃនេះតែម្តង។ សូមលោកប្រធានមេត្តាអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា និង អៀង សារី ដែលធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់ខ្លួន សុំមិនចូលរួមនៅក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយដកថយទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍នៅបន្ទប់ខាងក្រោម ដោយមូលហេតុបញ្ហាសុខភាព។

[១០:៤០:៥០]

អង្គជំនុំជម្រះយល់ព្រមអនុញ្ញាតតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី និងនួន ជា ដែលបានស្នើសុំតាមរយៈមេធាវីរបស់ខ្លួន សុំលះបង់សិទ្ធិមិនចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ ដោយទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ នៅឯបន្ទប់ឃុំខ្លួន នៅខាងក្រោមបន្ទប់សវនាការនេះ ដែលមានឧបករណ៍សោតទស្សន៍។ ក្រុមមេធាវីការពារក្តីទាំងពីរក្រុម ត្រូវប្រគល់ឲ្យអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិក្នុងចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការសម្រាប់ថ្ងៃនេះ សម្រាប់ជនជាប់ចោទទាំងពីរ ដោយមានចុះហត្ថលេខា និងផ្តិតម្រាមដៃជាក់លាក់ពីជនជាប់ចោទ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទអាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់ជនជាប់ចោទទាំងពីរនាក់នេះ ក្នុងអំឡុងសម្រាប់ថ្ងៃនេះតែម្តង។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទ នួន ជា និង អៀង សារី ទៅកាន់បន្ទប់ខាងក្រោមដែលមានរៀបចំជាមុននូវឧបករណ៍សោតទស្សន៍សម្រាប់ជនជាប់ចោទអាចចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង១០:៤១ នាទី ដល់ម៉ោង ១១:០៨ នាទី)*

[១១:០៨:០៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តសំណួរចំពោះសាក្សី។ អង្គជំនុំជម្រះសូមអញ្ជើញលោក កាណាវាស ឡើង

ក្រោកឈរ ដើម្បីស្តាប់នូវការសម្រេចរបស់អង្គជំនុំជម្រះចំពោះការជំទាស់ ដែលលោកបានធ្វើមុនពេលឈប់សម្រាក។

អង្គជំនុំជម្រះ-- ការជំទាស់របស់មេធាវីអន្តរជាតិការពារក្តីឲ្យលោក អៀង សារី ទៅនឹងការតាំងសំណួររបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ មុនពេលឈប់សម្រាកអម្បាញ់មិញនេះ គ្មានប្រសិទ្ធភាព។ សេចក្តីថ្លែងការណ៍របស់សាក្សីនៅដំណាក់កាលស៊ើបអង្កេត ក៏ជាសេចក្តីថ្លែងការណ៍ធ្វើឡើងដោយក្រោយពីសាក្សីបានធ្វើសម្បថដែរ។ ជាបច្ចេកទេស សេចក្តីថ្លែងការណ៍របស់សាក្សីនៅដំណាក់កាលស៊ើបអង្កេតក៏ជាសក្ខីកម្មដែរ។ ដើម្បីឲ្យកាន់តែច្បាស់ថែមទៀត ហើយជាដំណោះស្រាយបញ្ហានេះដែលកើតម្តងហើយ ម្តងទៀត ខ្ញុំសូមផ្តល់ភារៈទៅលោកស្រី ស៊ីលវៀ ខាតវ៉ាយថ៍ ដែលប្រើប្រាស់ភាសាអង់គ្លេសដូចគ្នានឹងលោក កាណាវាស ដែរ ដើម្បីបញ្ជាក់បញ្ហានេះបន្ថែមឲ្យកាន់តែច្បាស់ថែមទៀត។

បាទ សូមអញ្ជើញលោកស្រី!

[១១:០៩:៤៧]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ លោក កាណាវាស លោកប្រធានបានលើកឡើងបញ្ជាក់យ៉ាងច្បាស់រួចហើយ ហើយលោកក៏ប្រាកដជាយល់ដែរ។ ប្រព័ន្ធច្បាប់ដែលយើងកំពុងតែអនុវត្តនៅទីនេះ វាពាក់ព័ន្ធទៅនឹងនីតិវិធីជាសារវន្ត លោកបានយល់រួចហើយដែលថា សេចក្តីថ្លែងការណ៍ធ្វើនៅចំពោះមុខអ្នកស៊ើបអង្កេតក៏បានធ្វើសម្បថផងដែរ។ ដូច្នេះហើយវាក៏ជាសក្ខីកម្ម ហេតុដូច្នេះគឺ ជំទាស់របស់លោកគ្មានប្រសិទ្ធភាព។

[១១:១០:១៧]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ សូមអរគុណលោកស្រីចៅក្រម។

**ប្រធានអង្គជំនុំ៖**

សូមផ្តល់វេទិកាទៅសហព្រះរាជអាជ្ញា-- តំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរចំពោះសាក្សី។ សូមអញ្ជើញ!

**សួរដោយលោក ខេល លីសាក់៖**

**ស៖** សូមអរគុណលោកប្រធាន។ មុនពេលឈប់សម្រាកអម្បាញ់មិញលោកបានរៀបរាប់អំពីសៀវភៅដែលលោកស្រីបានទទួល។ សូមលោកស្រីយល់ថា នៅក្នុងសវនាការនេះ គឺខ្ញុំមិនចង់សួរលោកស្រីស៊ីជម្រៅទៅលើគោលនយោបាយនៃរបបនោះទេ។ អ្វីដែលខ្ញុំចង់សួរនោះថាតើលោកស្រីបានទទួលសៀវភៅនេះនៅពេលណាដែរ? ដែលសៀវភៅនេះនិយាយអំពីវត្តអារាម និងព្រះសង្ឃ លោកស្រីចាំឆ្នាំទេ? ថាតើទទួលបាននៅឆ្នាំណាដែរ? ឬក៏បើសិនមិនចាំឆ្នាំទេ គឺនៅពេលដែលលោកស្រីទៅធ្វើជាសមាជិកនៅក្នុងតំបន់៣៥ ឬក៏ក្រោយពេលហ្នឹង? សូមលោកស្រីបញ្ជាក់។

[១១:១១:៣២]

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំសូមបញ្ជាក់ ការទទួលសៀវភៅនេះ ខ្ញុំដូចជាក្រោយ-- ខ្ញុំមិនបានចាំដែរ សូមជម្រាប។ មិនដឹងក្រោយ ឬក៏មុននៅតំបន់៣៥។ និយាយរួមកាលនោះ ខ្ញុំសូមជម្រាបថា ការធ្វើដូចជាមិនមានជាតួលេខច្បាស់លាស់ ដូចថាចេះតែធ្វើ វាអត់បានគម្រោងទុកអីអ៊ីចឹងណ៎ា អ៊ីចឹងខ្ញុំវាអត់ចាំ។ មិនដឹងថាក្រោយនៅខេត្តកំពត ឬក៏នៅក្នុងខេត្តតាកែវ ខ្ញុំអត់ចាំទេលោក។ ខ្ញុំសូមជម្រាបត្រង់ហើយនេះ។ មិនដឹងថា ថ្ងៃណាខែណាទៀត ព្រោះខ្ញុំមិនបានកត់សម្គាល់ទុក។ ដល់អត់កត់សម្គាល់ទុក ហើយវាយូរយារមកហើយតាំងពីឆ្នាំនោះ មកដល់ឆ្នាំនេះខ្ញុំភ្លេចហើយ។ វាអត់ចាំ មិនដឹងថា ឆ្នាំ ថ្ងៃប៉ុន្មានខែប៉ុន្មាន ថ្ងៃទីប៉ុន្មាន វាអត់ចាំ។ អ៊ីចឹង ខ្ញុំសូមជម្រាបលោកប្រធានថា ដូចជាមិន-- វាអត់ច្បាស់និយាយឆ្លើយទៅដូចថាខ្ញុំថាឆ្នាំនេះក្រែងខុសពីគម្រោងដែលខ្ញុំបានពិនិត្យហើយ ឬក៏បានធ្វើហើយនោះ។ អ៊ីចឹងខ្ញុំនិយាយទៅវាតែងតែខុសត្រូវក្នុង-- លោកមេធាវីទាំងអស់ នាំឱ្យចាប់អារម្មណ៍ថាខ្ញុំហ្នឹងម៉េច-- អ៊ីចឹងខ្ញុំលើកទៅវានាំឱ្យខុសឆ្នាំខែហ្នឹងវាអត់ចាំ។ អ៊ីចឹង សូមអស់។

[១១:១៣:២៨]

**ប្រធានអង្គជំនុំ៖**

លោកស្រី ប្រាក់ យុត នៅឆ្លើយតបនឹងសំណួរនៅពេលក្រោយៗទៀត ប្រសិនបើលោកស្រីមិនចាំនូវកាលបរិច្ឆេទពេលវេលាជាក់លាក់នោះទេ លោកស្រីឆ្លើយតែមួយម៉ាត់ទៅថា លោកស្រីមិនចាំទេ។ កាលណាលោកស្រីរៀបរាប់បញ្ហាមិនចាំហ្នឹង ច្រើនលើកច្រើនសាដដែលហ្នឹងទៅ គឺវានាំឱ្យខាត-- បាត់បង់ពេលវេលា ហើយពាក់ព័ន្ធនឹងការកត់ត្រាកំណត់ហេតុ នៃកិច្ចដំណើរការពិភាក្សាផង។

សូមអញ្ជើញបន្តសំណួរ។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** សូមអរគុណដែលលោកស្រីបានបញ្ជាក់បំភ្លឺ។ តើលោកស្រីចាំទេ នរណាគេដែរដែលបានផ្តល់សៀវភៅនេះជូនលោកស្រី?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំអត់បានចាំ។ មិនដឹងឈ្មោះអី។

**ស៖** តើអ្នកដែលនៅក្នុងបក្សជាសមាជិកបក្សផ្តល់ជូនលោកស្រី ឬក៏មិនមែនទេ?

**ឆ៖** នៅក្នុងការផ្តល់ជូនបក្ស-- ជូនមតិដល់ខ្ញុំ គឺនៅក្នុងសមាជិកបក្ស។

[១១:១៥:០៤]

**ស៖** ក្នុងពេលដែលលោកស្រីជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា តើលោកស្រីធ្លាប់ទទួលបានទង់បដិវត្ត ទស្សនាវដ្តីទង់បដិវត្តដែរឬទេ?

**ឆ៖** ខ្ញុំសមាជិកបក្សកម្ពុជា សម័យនោះ ខ្ញុំអត់បានទទួលដែរ អត់សូវ ព្រោះខ្ញុំអត់សូវចេះអក្សរ ហើយអ៊ីចឹងអត់សូវបានយកមកទុកមើលអីទេ។ ខ្ញុំចេះដែរ ប៉ុន្តែតិចមើលអត់សូវរួច។ អ៊ីចឹងនៅឯកសារទាំងឡាយ ខ្ញុំមិនសូវបានយកទុកដាក់ដែរ។ ព្រោះខ្ញុំអត់ចេះ អត់សូវចេះៗវាតិចតួច។ សូមមានមតិប៉ុណ្ណឹង។

**ស៖** ខ្ញុំយល់អំពីលោកស្រីមិនសូវចេះអាន មិនសូវចាំ តើលោកស្រីចាំសៀវភៅមួយក្បាលដែលជាទង់-- ទស្សនាវដ្តីទង់បដិវត្តនៅក្របខាងមុខ មានទង់ពណ៌ក្រហម ដែលគេបានចែកជូនទៅដល់តំបន់ទៅដល់ស្រុកដែរឬទេ?

[១១:១៦:២៥]

**ឆ៖** មិនដឹងទង់ ឯកសារមួយណាទេ ខ្ញុំក៏មិនបានពិនិត្យពិច័យដែរ។ ខ្ញុំមិនបានពិនិត្យពិច័យឯកសារទង់ក្រហមហ្នឹងមួយណា គឺអត់ច្បាស់ដែរ។ អត់ចាំ និយាយរួមគឺអត់ចាំ។ សូមអស់។

**ស៖** អ្វីដែលខ្ញុំដង់ដឹងនេះ ទោះបីជាលោកស្រីមិនចេះអាន មិនសូវចេះអក្សរក៏ដោយ តើលោកស្រីធ្លាប់ឃើញសៀវភៅដែលគេដាក់ថា ទង់បដិវត្តដែរឬទេ ក្នុងពេលដែលលោកស្រីជាសមាជិកបក្សនុំុង?

**ឆ៖** ខ្ញុំធ្លាប់បានឃើញ។ ខ្ញុំធ្លាប់បានឃើញ ព្រោះខ្ញុំសមាជិកបក្ស តែខ្ញុំគ្រាន់តែបានឃើញ តែការមើលអី ខ្ញុំអត់សូវបានមើល។ អ៊ីចឹងសូមមានមតិប៉ុណ្ណឹង។ បានឃើញសៀវភៅហ្នឹង តែការអានគឺខ្ញុំ

អត់សូវចេះ។

**ស៖** ចាតើលោកស្រីឃើញសៀវភៅទង់បដិវត្តនេះនៅទីណាដែរ? ដែលថាពណ៌ក្រហម សៀវភៅទង់ពណ៌ក្រហមហ្នឹង?

[១១:១៨:០៣]

**ឆ៖** កាលហ្នឹងខ្ញុំនៅខេត្តកំពត ខ្ញុំឃើញនៅខេត្តកំពត។

**ស៖** ចាតើនៅកន្លែងណាជាក់លាក់នៅក្នុងខេត្តកំពតដែរឬទេ? នៅមន្ទីរណាមួយនៅក្នុងខេត្តកំពតឲ្យលោកស្រីជួយបញ្ជាក់បន្តិចមើល?

**ឆ៖** ខ្ញុំសូមបញ្ជាក់ ឯកសារហ្នឹង កាលហ្នឹងទង់បក្សហ្នឹងគឺនៅកន្លែង កង ចាប តែខ្ញុំទៅឃើញនៅកន្លែងគាត់។ ខ្ញុំក៏បាន គ្រាន់តែមើលមួយសន្លឹកពីរសន្លឹក ខ្ញុំមើលអត់សូវរួច ក៏ខ្ញុំឈប់មើល គាត់ទុកនៅកន្លែងគាត់ហ្នឹងណ៎ា។ កន្លែង កង ចាប នៅខេត្តកំពត។ តែគាត់ស្លាប់ហើយ និយាយមិនកើត។ ហើយមិនដឹងគាត់យកទៅណាទៅណើ ក៏ខ្ញុំអត់ដឹងដែរ។

**ស៖** ចាតើកន្លែង កង ចាប នៅណាដែរ នៅក្នុងខេត្តកំពតហ្នឹង នៅត្រង់កន្លែងណាដែរ?

**ឆ៖** គាត់នៅ កាលនេះ ជំនាន់ហ្នឹងគាត់នៅសាលាខេត្ត ខេត្តកំពតចាស់។

[១១:២០:០០]

**ស៖** បានន័យថាកន្លែងសាលាខេត្តចាស់នោះគឺជាតំបន់៣៥ហ្នឹងមែនដែរឬទេ ដែលជាមន្ទីរមួយនៃតំបន៣៥នោះ?

**ឆ៖** ចាស កន្លែងមន្ទីរ។

**ស៖** ខ្ញុំចង់សួរត្រឡប់ថយក្រោយបន្តិច ដើម្បីឲ្យស្រីជួយបញ្ជាក់បំភ្លឺអំពីទីកន្លែង និងតួនាទីដែលលោកស្រីមានតំណែងតាំងពីមុនមក។ ក្រោយពីលោកស្រីបានក្លាយទៅជាសមាជិកតំបន់៣៥ នៅក្នុងឆ្នាំ៧៣ និង ៧៤ លោកស្រីនៅទីនោះគឺបីឬក៏បួនឆ្នាំ មុនពេលគេបញ្ជូនលោកស្រីមកខេត្តកំពង់ចាម។ តើលោកស្រីចាំខែ ឬក៏ឆ្នាំដែរឬទេ នៅពេលដែលគេផ្លាស់លោកស្រីមកស្រុកកំពង់សៀមឲ្យធ្វើជាលេខានោះ?

**ឆ៖** ខ្ញុំនៅកំពតឆ្នាំ៧៣, ៧៤, ៧៥ នៅបីឆ្នាំ-- នៅបួនឆ្នាំ ៧៦ មួយទៀត។ ដល់៧៧ ខ្ញុំទៅនៅកំពង់ចាម។ ពី ៧៣, ៧៤ មក ៧៥, ៧៦ ខ្ញុំនៅខេត្តកំពត។

**ស៖** តើចាំទេនៅខែណាដែរ ឬក៏ឆ្នាំណាដែរ ដែលគេផ្លាស់លោកស្រីមកកំពង់ចាមនៅក្នុងឆ្នាំ ១៩៧៧ នោះ?

**ឆ៖** អត់ចាំទេ។ ខ្ញុំអត់ចាំដែរថ្ងៃផ្លាស់មក។ មិនដឹងថ្ងៃណា ខែណា មិនចាំ អត់បានចាំ។

[១១:២២:២៣]

**ស៖** ខ្ញុំសាកមើល ប្រសិនបើសួរទៅអាចឲ្យលោកស្រីចាំឡើងវិញ នៅពេលដែលគេស៊ើបអង្កេតទៅសង្កេតលោកស្រីលើកទីមួយ លោកស្រីបានលើកឡើងថា គេផ្លាស់លោកស្រីពីតំបន់៣៥ ទៅកំពង់សៀមនៅខែមីនា ឆ្នាំ១៩៧៧ ឯកសារ D234/4។ នៅក្រោយការសម្ភាសមកឯកសារលេខ D234/15 លោកស្រីបាននិយាយថា លោក កង ចាប ជាអ្នកបញ្ជូនលោកស្រីទៅកំពង់សៀម នៅក្នុងខែកុម្ភៈ ឆ្នាំ ១៩៧៧ តើវាពិតជាត្រឹមត្រូវដែរឬទេ ដែលគេផ្លាស់លោកស្រីពីកំពតទៅកំពង់សៀម នៅក្នុងខែនុ៎ង?

**ឆ៖** ការពិត ត្រឹមត្រូវ។ ខ្ញុំអត់ចាំ គឺវាពិតហើយ ត្រឹមត្រូវហើយ។ ព្រោះខ្ញុំចាំវាអត់អស់។

**ស៖** ដូច្នេះបានន័យថា ថាគេផ្លាស់លោកស្រីទៅកំពង់សៀមហ្នឹងនៅចន្លោះខែកុម្ភៈ និងខែមេសា ឆ្នាំ១៩៧៧ តើត្រឹមត្រូវដែរទេ?

**ឆ៖** ចាស ត្រឹមត្រូវហើយ។

**ស៖** ចាតើលោកស្រីធ្វើជាលេខាកំពង់សៀមនោះរយៈពេលប៉ុន្មានដែរ?

**ឆ៖** ខ្ញុំធ្វើលេខានៅស្រុកកំពង់សៀមបានតែពីរខែ ប្ដីចាប់ទៅ ខ្ញុំក៏បកមកវិញ។

**ស៖** តើលោកស្រីត្រឡប់មកវិញហ្នឹង គឺទៅណាដែរក្រោយពីត្រឡប់ពីកំពង់សៀមនុ៎ង?

**ឆ៖** ខ្ញុំត្រឡប់ពីកំពង់សៀមមកនៅពាយ័ព្យ ឆ្នាំ៧៨ ខ្ញុំមកពាយ័ព្យ។

[១១:២៥:០០]

**ស៖** ពាយ័ព្យហ្នឹង នៅត្រង់ម្ដុំណាដែរ នៅក្នុងឆ្នាំ១៩៧៨ ដែលលោកស្រីផ្លាស់មកពាយ័ព្យហ្នឹង?

**ឆ៖** ខ្ញុំផ្លាស់មកនៅពាយ័ព្យ ខ្ញុំមកនៅសាលាខេត្តបាត់ដំបង ដោយសារគេចាប់ប្ដី គេដកភារកិច្ចខ្ញុំមកនៅហ្នឹង ខ្ញុំអត់មានធ្វើអីទៀតទេ។ ដកមកនៅសាលាខេត្តបាត់ដំបង ហើយក្រោយមក-- ហើយឲ្យខ្ញុំទៅនៅចម្ការកប្បាស នៅជីប៉ាង នៅស្ពៅ ព្រោះខ្ញុំអស់មានប្ដី ក៏ដកមកយកទៅចម្ការកប្បាស ប៉ុន្តែខ្ញុំនៅដេកនៅសាលាខេត្តបានបីយប់។

**ស៖** ចាតើផ្កាកប្បាសនេះ នៅក្នុងស្រុកណាដែរ? បានន័យថា នៅក្នុងខេត្តបាត់ដំបងហ្នឹង ឬក៏នៅម្ដុំណា?

**ធ៖** នៅខេត្តបាត់ដំបង ប៉ុន្តែនៅស្រុករតនមណ្ឌល អ្ហេស់! ស្រុកសំឡូត ប៉ុន្តែខ្ញុំមិនច្បាស់លាស់ដែរ ព្រោះខ្ញុំមិនបានរស់នៅខេត្តបាត់ដំបងហ្នឹង ខាងម៉ុហ្នឹងខ្ញុំអត់ស្គាល់ដែរ ប៉ុន្តែកាលនោះ មិនដឹងនៅស្រុកសំឡូត ឬក៏នៅក្នុងស្រុកណាទេ ប៉ុន្តែខ្ញុំទៅនៅហ្នឹង នៅបៀត-- មិនដឹងក្នុងស្រុកសំឡូតឬអី។

**ស៖** ថាតើវាកន្លែងដែលគេនៅដាំកប្បាសនៅជីប៉ាង ហ្នឹងមែនដែរឬទេ?

**ធ៖** ចាស នៅជីប៉ាងហ្នឹង។

**ស៖** ថាតើនៅចម្ការនុំង លោកស្រីមានតួនាទីអ្វីដែរ? គេឲ្យធ្វើអីដែរ?

**ធ៖** កាលហ្នឹង ខ្ញុំដកមកពីកំពង់ចាម ខ្ញុំនៅពាយ័ព្យ ដល់តាម៉ុក គាត់ថាខ្ញុំអស់ភារកិច្ចអីទាំងអស់ អ៊ីចឹងឲ្យខ្ញុំនឹងទៅធ្វើ-- ឲ្យខ្ញុំទៅចម្ការកប្បាស អង្គាល់ហ្នឹងគាត់នៅបាត់ដំបងដែរ ដល់ខ្ញុំទៅនៅចម្ការកប្បាស អត់ឲ្យធ្វើទេអ្ហែងនោះ ធ្វើចាំចម្ការកប្បាសទៅ ព្រោះប្តីអ្ហែងគេចាប់ហើយ។ ខ្ញុំក៏ទៅ មាននាទីអីទេ ខ្ញុំគ្រាន់តែទៅ ដូចថាទៅនៅកន្លែងហ្នឹង ឲ្យធ្វើចម្ការហ្នឹងតែម្តង ខ្ញុំអត់មានតួនាទីអីផង ព្រោះប្តីចាប់គេលែងទុកចិត្តហើយ។ ខ្ញុំសូមមានមតិប៉ុណ្ណឹង។ សូមអស់។

[១១:២៧:៥៩]

**ស៖** តើលោកស្រីចាំទេ នៅក្នុងខែណា ឆ្នាំ១៩៧៨ហ្នឹង នៅពេលដែលទៅដល់បាត់ដំបង នៅក្នុងខែណាដែរ ក្នុងឆ្នាំ៧៨?

**ធ៖** នៅក្នុងប៉ុន្មានទេ ខែ-- ខ្ញុំមិនចាំដែរ ព្រោះ-- អត់ចាំ មិនដឹងខែប៉ុន្មាន។

**ស៖** ខ្ញុំព្យាយាមរំឭកឡើងវិញ នៅក្នុងពេលដែលអ្នកស៊ើបអង្កេត ពីតុលាការចុះទៅស៊ើបអង្កេតលោកស្រីលើកទីមួយហ្នឹង លោកស្រីលើកឡើងថា ខ្ញុំទៅដល់បាត់ដំបងប្រហែលជាម៉ោងប្រាំបួន ខែតុលា ឆ្នាំ១៩៧៨ តើលោកស្រីចាំទេ វាត្រឹមត្រូវទេ ដែលថាលោកស្រីបានទៅដល់ខែ-- ទៅដល់ខេត្តបាត់ដំបងនៅក្នុងខែតុលា ឆ្នាំ១៩៧៨?

**ធ៖** ចាស ត្រឹមត្រូវ គ្រាន់ខ្ញុំវាអត់ចាំ។

**ស៖** ថាតើលោកស្រីធ្វើការនៅចម្ការកប្បាសក្នុងខេត្តបាត់ដំបងហ្នឹង ប៉ុន្មានខែដែរ?

**ធ៖** ធ្វើបានខែ៨, ខែ៩ ហ្នឹង ធ្វើបានពីរខែ ដល់ហើយយួន-- អ៎ កាលហ្នឹង មានព្រឹត្តិការណ៍កប៉ាល់ហោះទម្លាក់នៅបាត់ដំបង ក៏មានការរត់ទៅ អត់បានធ្វើតទៅទៀតទេ។ ហើយដឹងម៉េច បើខ្ញុំអត់ដឹង ខ្ញុំធ្វើនៅតែចម្ការកប្បាសហ្នឹង ទើបតែធ្វើបាន ធ្វើមិនទាន់បានកប្បាសត្រឹមត្រូវផង ខាងហ្នឹងគាត់ឲ្យទៅធ្វើ។

[១១:៣០:០០]

**ស៖** សូមអរគុណដែលលោកស្រីបានបញ្ជាក់ពេលវេលាយ៉ាងច្បាស់។ មុនពេលដែលខ្ញុំសួរទៅដល់ចំណុចមួយទៀត កាលពីម្សិលមិញលោកស្រីបានឆ្លើយថា នៅពេលដែលគេផ្លាស់លោកស្រីពីកំពតទៅកំពង់ចាម-- សូមអភ័យទោសខ្ញុំនិយាយម្ដងទៀត កាលពីម្សិលមិញលោកស្រីនិយាយថា គេផ្លាស់លោកស្រីពីកំពតទៅកំពង់ចាម ក្រោយពី កង ចាប នេះអប់រំលោកស្រី។ តើលោកស្រីអាចបញ្ជាក់ទេថា តើគេអប់រំលោកស្រី កង ចាប អប់រំលោកស្រីនៅកំពតហ្នឹង នៅម្តុំណាដែរ? នៅត្រង់ណាដែរ? សូមលោកស្រីបញ្ជាក់។

**ឆ៖** កាលមុនខ្ញុំចេញទៅកំពង់ចាម តា កង ចាប ហៅខ្ញុំទៅជួបនៅមន្ទីរគាត់ ផ្ទះគាត់។ អប់រំខ្ញុំថា ឲ្យខ្ញុំចេញទៅនៅកំពង់ចាម គាត់អប់រំនៅនឹងផ្ទះគាត់ហ្នឹង មន្ទីរ ផ្ទះគាត់។ នៅមន្ទីរគាត់ហ្នឹងតែម្ដងកន្លែងគាត់នៅ។

[១១:៣១:២៦]

**ស៖** តើឲ្យទៅជួបគាត់ហ្នឹងរយៈពេលប៉ុន្មានដែរ នៅមន្ទីរគាត់ហ្នឹង?

**ឆ៖** គាត់ហៅទៅម៉ោងបួនល្ងាច គាត់និយាយខ្ញុំពីរម៉ោង ឲ្យខ្ញុំតែទៅនៅកំពង់ចាម ហើយខ្ញុំក៏អត់មានទំនាស់អីដែរ គាត់ឲ្យទៅហើយ ខ្ញុំចេះតែទៅ ព្រោះគាត់ប្រធានខ្ញុំហើយ។ គាត់ឲ្យខ្ញុំទៅ។ គាត់និយាយជាមួយខ្ញុំ អប់រំខ្ញុំថា យើងទៅនៅកំពង់ចាមទាំងអស់គ្នា។ ខ្ញុំថា ខ្ញុំអត់មានទាស់អីទេ ឲ្យតែខាងលើចាត់តាំង គឺខ្ញុំទៅ។ ខ្ញុំនិយាយអ៊ីចឹង គាត់ថា អើ! អ៊ីចឹងក៏បានដែរទៅ ខ្ញុំក៏ទៅដែរ ខ្ញុំទៅនៅសៀមរាប។ ខ្ញុំនេះ គាត់នែ៎ គាត់ថាឲ្យនៅស្រុកកំពង់សៀម ហើយគាត់នៅខាងសៀមរាប។ គាត់និយាយតែប៉ុណ្ណឹងអត់មាននិយាយអីច្រើនផង។

**ស៖** នៅពេលដែលលោកស្រីនិយាយថា គាត់ទៅសៀមរាបហ្នឹង គឺកង ចាប ហ្នឹងដែលទៅសៀមរាប?

**ឆ៖** ចាស។

**ស៖** នៅពេលដែលលោកស្រីជួប កង ចាប ពីរម៉ោងនោះ។ តើលោក កង ចាប មានពន្យល់ទេថាហេតុអីបានជាគេឲ្យបញ្ជូនលោកស្រីទៅកំពង់សៀម?

**ឆ៖** គាត់អត់មានពន្យល់អី គាត់គ្រាន់តែថា យើងត្រូវទៅនៅ-- ខ្ញុំត្រូវទៅនៅសៀមរាប ហើយគាត់ថា ខ្ញុំហ្នឹងត្រូវទៅនៅកំពង់ចាម គាត់អត់មាននិយាយពីរឿងហេតុផលអីផង។ អត់ប្រាប់ខ្ញុំថា ឥឡូវ

អ៊ីចេះមួយអ៊ីចេះពីរ គាត់អត់មាននិយាយទេ។ គាត់គ្រាន់តែប្រាប់អ៊ីចឹង ខ្ញុំក៏អត់មានទំនាស់អីទេ ព្រោះគាត់អ្នកខាងលើហើយ ខ្ញុំអត់មានគិតអីទេ ឲ្យទៅណា គឺខ្ញុំទៅហ្នឹង អត់មានទំនាស់អីសោះ។ អាហ្នឹងអ៊ីចឹង ព្រោះគាត់អ្នកប្រាប់ខ្ញុំ។

[១១:៣៣:៤៣]

**ស៖** ខ្ញុំសូមសួរសំណួរពាក់ព័ន្ធចំណុចមួយទៀត ដែលវាពាក់ព័ន្ធពេលដែលលោកស្រីនៅក្នុងគណៈកម្មាធិការតំបន់៣៥។ ថាតើនៅពេលនោះមានការបែងចែកការទទួលខុសត្រូវភូមិភាគ តំបន់ ស្រុក យ៉ាងម៉េចដែរ? ឬក៏គេទាក់ទងគ្នាហ្នឹងយ៉ាងម៉េច? សេចក្ដីសម្រេច ការណែនាំ និងការរាយការណ៍ទៅក្រោមហ្នឹងធ្វើតាមរបៀបណា? ហើយពីខាងឃុំហ្នឹង គឺរាយការណ៍ទៅខាងលើហ្នឹងដោយយ៉ាងម៉េចដែរ?

ចំណុចមួយទៀត ដែលខ្ញុំចង់ធ្វើការបញ្ជាក់ នៅពេលដែលលោកស្រីជាសមាជិកតំបន់៣៥ ថាតើលោកស្រីធ្វើនៅក្នុងមន្ទីរណាមួយ? មន្ទីរហ្នឹងនៅកន្លែងណា?

[១១:៣៤:៣៦]

**ឆ៖** ខ្ញុំសូមជម្រាប ការក្នុងគណៈកម្មាធិការតំបន់ បានរៀបរយសម័យនោះ គឺបានចែកភារកិច្ចគ្នា ឧទាហរណ៍ថា ខ្ញុំខាងនៅស្រុកកំពតអ៊ីចឹងទៅ អ្នំ តា សៀន, លោក សៀន នៅខាងកំពង់ត្រាច លោក ផន នៅទូកមាស, លោក ទី នៅខាងឈូក, អឺ! លោក ឈុំ ហ្នឹងនៅខាងកោះស្លាអីអ៊ីចឹងទៅ។ ហេតុអីបានចែកភារកិច្ចគ្នាដាច់ៗ គឺបានអនុវត្តតាមភូមិឃុំទាំងអស់គ្នា។ ការរាយការណ៍ គឺឧទាហរណ៍ថា ពេលបីខែ ឬក៏មួយខែ យើងប្រជុំពីការងារម្ដងអ៊ីចឹងទៅ អំពីដាក់ផែនការ ដូចឧទាហរណ៍លើកទំនប់ ជីកប្រឡាយអីអ៊ីចឹង យើងពិនិត្យផែនការហ្នឹងទៅ យើងហៅមកប្រជុំគ្នា អាហ្នឹងទីមួយ។ ទីពីរទៀត បីខែយើងប្រជុំពិនិត្យអំពីការងារយើងក្នុងឃុំមួយៗ វារីកចម្រើន ឬក៏វាម៉េចអាហ្នឹងពិនិត្យទាំងអស់គ្នា។ ហើយនៅក្នុងគណៈកម្មាធិការ គឺតាចាប ហ្នឹងគាត់ទទួលបន្ទុកនៅមន្ទីរ។ ខាងពួកខ្ញុំ នៅតាមស្រុកមួយៗ ចែកគ្នាច្បាស់លាស់ធ្វើ។ អាហ្នឹងសូមមានមតិប៉ុណ្ណឹង។

[១១:៣៦:០៣]

**ស៖** ខ្ញុំត្រឡប់ទៅក្រោយ ប៉ុន្តែខ្ញុំចង់បញ្ជាក់ឡើងវិញថា លោកស្រីថា សមាជិកនៃគណៈកម្មាធិការតំបន់ គឺទទួលខុសត្រូវសម្រាប់ស្រុកនីមួយៗ។ ហើយលោកស្រីទទួលនៅស្រុកកំពតតាមដែលខ្ញុំស្ដាប់លោកស្រី គឺថាលោកស្រីទទួលខុសត្រូវនៅស្រុកកំពតមែនទេ?

**ផ៖** ចាស! ខ្ញុំនៅទទួលនៅស្រុកកំពត។

**ស៖** នៅស្រុកកំពតហ្នឹង លោកស្រីមានកន្លែងធ្វើការ មានការិយាល័យធ្វើការនៅទីនោះដែរឬទេ?

**ផ៖** មានតើ។

**ស៖** តើការិយាល័យនេះ ជាការិយាល័យធ្វើការរួមគ្នាជាមួយនឹងការិយាល័យរបស់តំបន់ ឬក៏ជាការិយាល័យមួយដាច់ដោយឡែក?

**ផ៖** ចាស របស់ស្រុកមួយដោយឡែក តំបន់ផ្សេងទេ ស្រុកផ្សេង ដោយឡែកៗពីគ្នា។

[១១:៣៧:២៨]

**ស៖** តើនៅការិយាល័យថ្នាក់តំបន់នៅស្រុកកំពតហ្នឹង របស់លោកស្រីហ្នឹង តើមានគ្នាប៉ុន្មាននាក់ដែរ? មានសមាជិកប៉ុន្មាននាក់ដែរ?

**ផ៖** ដូចខ្ញុំរាប់រៀបខាងលើថាមាន តាផន មានអ៊ី គាត់ស្លាប់អស់ហើយ។ មានប្រាំនាក់ ប្រាំមួយនាក់។ មួយ តាផន, ពីរ តាសៀន, បី តាទី, បួននែ៎! តាកុត, ប្រាំខ្ញុំ, ប្រាំមួយ តាចាប ប៉ុន្តែស្លាប់អស់ហើយ។ ប្រាំ-ប្រាំមួយនាក់ហ្នឹងស្លាប់អស់ហើយ។

**ស៖** អ្នកដែលលោកស្រីទើបរៀបរាប់អម្បាញ់មិញហ្នឹង គឺជាសមាជិកតំបន់។ ខ្ញុំនិយាយអំពីសមាជិកធ្វើការនៅការិយាល័យនៅស្រុកកំពត មិនមែនសមាជិករបស់តំបន់ទេ។ លោកស្រីយល់សំណួរខ្ញុំទេ?

[១១:៣៨:៣១]

**ផ៖** នៅស្រុកកំពត សមាជិកនៅស្រុកកំពត គណៈកម្មការគាត់មានបួននាក់ តែឥឡូវនៅក្នុងស្រុកហ្នឹង វាចែកការងារដូចនៅតំបន់ដែរ។ តែឥឡូវហ្នឹងនៅស្រុកកំពត ក៏គ្មានមនុស្សនៅដែរ ស្លាប់អស់ហើយ។ មានប្រាំនាក់ហ្នឹង ធ្វើការពិភាក្សាគ្នាក្នុងស្រុកហ្នឹង។ ក្នុងនុ៎ងមានខ្ញុំមួយចូលរួមជាជំនួយការក្នុងគណៈកម្មការគាត់ គាត់មានបួននាក់អ៊ីចឹងទៅ។ ក្នុងគណៈកម្មការស្រុក។

**ស៖** ពាក់ព័ន្ធទៅនឹងការរាយការណ៍ តើលេខាស្រុករាយការណ៍មកឲ្យលោកស្រី ហើយលោកស្រីរាយការណ៍ជូន កង ចាប ជាលេខាតំបន់ នេះជារបៀបរបបរាយការណ៍មែនទេ?

**ផ៖** របៀបរបបរាយការណ៍ គឺខ្ញុំ ហើយតាណយ គឺរាយជុំគ្នា រាយឲ្យ កង ចាប តែម្តង ព្រោះខ្ញុំវាជំនួយការក្នុងស្រុកហ្នឹងហើយ ទាល់យើងរាយជុំគ្នា ខ្ញុំមិនអាចរាយផ្សេងទេ។ ព្រោះគាត់ហ្នឹង

ការងារជុំគ្នាក្នុងស្រុក យើងដឹងផែនការអស់ហើយក្នុងស្រុកហ្នឹង។ ហេតុនេះ យើងនិយាយទៅដូចថា ត្រូវគ្នារាយការណ៍តែមួយសន្លឹកហ្នឹង ជូនឲ្យតា កង ចាប តែម្តង។ អត់មានខ្ញុំផ្សេង តាណយ ផ្សេងទេ កន្លងទៅ។

[១១:៤០:១៥]

**ស៖** អ្នកដែលលោកស្រីរាប់ តាណយ គាត់ជាលេខាស្រុកកំពត ឬក៏មិនមែនទេ?

**ឆ៖** លេខាស្រុកកំពត តែខ្ញុំជំនួយការ ជួយគាត់ព្រោះគាត់មិនសូវចេះអ៊ីចឹង ខ្ញុំចេះតែជួយគាត់ការងារក្នុងស្រុកហ្នឹង។ អ៊ីចឹងយើងធ្វើការងារកន្លងទៅ ធ្វើការងារហ្នឹងគាត់អត់សូវចេះយើងមកពិភាក្សាគណៈកម្មការហ្នឹងយើងរាយការណ៍ទាំងអស់គ្នា ទាំងគាត់ ទាំងខ្ញុំអីហ្នឹងរាយការណ៍ឲ្យតំបន់តែមួយសន្លឹកទេ អត់មានច្រើនសន្លឹកទេ។ ព្រោះ តាណយ ហ្នឹងគាត់មិនសូវចេះ អ៊ីចឹងយើងពិភាក្សាគ្នារាយការណ៍តែមួយសន្លឹកទេ ឲ្យទៅតា កង ចាប។

[១១:៤១:០៥]

**ស៖** ហេតុផលដែលខ្ញុំសួរលោកស្រីនេះ ដោយសារនៅក្នុងកិច្ចសម្ភាសន៍របស់លោកស្រីជាមួយឯកសារហ្នឹង គឺ D34/4, D234/4 គឺតាណយ លេខាស្រុកបានរាយការណ៍មកឲ្យខ្ញុំ ហើយខ្ញុំរាយការណ៍ទៅឲ្យ កង ចាប ដែលជាលេខាតំបន់។ នេះគឺជា ERN ជាភាសាអង់គ្លេស 00364779 ហើយជាខ្មែរ 00357508 ជាភាសាបារាំង 00403123 នៅពេលផ្តល់សក្ខីកម្មនៅទីនេះ គឺលោកស្រីហាក់បីដូចជាស្ទាក់ស្ទើរ ប៉ុន្តែនៅពេលសម្ភាសជាមួយសហចៅក្រមស៊ើបអង្កេតលោកស្រីថា លេខាស្រុករាយការណ៍ជូនលោកស្រី ហើយលោកស្រីរាយការណ៍ជូនទៅឲ្យ កង ចាប ជាលេខាតំបន់។ តើនេះត្រឹមត្រូវទេ?

**ឆ៖** ត្រូវ។ និយាយទៅខ្ញុំមិនចាំទាំងអស់ទេ។ អត់សួរតាមសំណួរ បើសួរតាមសំណួរនៅចាំ។

**ស៖** ដូច្នេះចម្លើយមួយដែលត្រឹមត្រូវ គឺចម្លើយដែលលោកស្រីបានផ្តល់ទៅឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលថា តាណយ រាយការណ៍ជូនលោកស្រី ហើយលោកស្រីរាយការណ៍ទៅឲ្យ កង ចាប តើអ៊ីចឹងមែនទេ?

**ឆ៖** ត្រឹមត្រូវ។

**ស៖** ចំណុចមួយទៀត ដែលខ្ញុំចង់សួរនោះ គឺនៅចំពោះមុខតុលាការនេះគឺតំបន់៣៥ នេះគឺប្រជុំរៀងរាល់បីខែម្តង។ ក៏ប៉ុន្តែនៅក្នុងចម្លើយរបស់លោកស្រីឆ្លើយជូនសហចៅក្រមស៊ើបអង្កេតលោកស្រី

បញ្ជាក់ថា កិច្ចប្រជុំរបស់តំបន់៣៥ នេះ គឺប្រជុំរៀរាល់ខែ។ តើការប្រជុំនោះ គឺនៅថ្នាក់តំបន់នោះ រៀងរាល់ខែ ឬក៏បីខែម្តង?

[១១:៤៣:៤៣]

**ផ៖** ការប្រជុំនោះ បើខ្ញុំឆ្លើយក្នុងការស៊ើបសួរអង្កេតតែបីខែ ឬក៏មួយខែក៏ខ្ញុំឯកភាពតាម បានការស៊ើបអង្កេតដែរ។ ខ្ញុំមិនឲ្យខុសហ្នឹង បើថាតំបន់៣៥ ប្រជុំបីខែ ខ្ញុំយកអាបីខែហ្នឹងទៅ កុំឲ្យវាខុស។ បើថាមួយខែ ឲ្យយកមួយខែហ្នឹងទៅ។

**ស៖** ខ្ញុំសូមអានចម្លើយរបស់លោកស្រីនៅពេលសម្ភាសលើកទីមួយ ដោយសហចៅក្រមស៊ើបអង្កេត គឺឯកសារ D234/4 ខ្ញុំសូមអានពី ERN ជាភាសាអង់គ្លេស 00364080 ERN ជាភាសាខ្មែរ 00357506 ហើយERN ជាភាសាបារាំង 00403124។ សូមដកស្រង់សម្តី៖ "តើកិច្ចប្រជុំរបស់ថ្នាក់តំបន់ធ្វើឡើងដោយរបៀបណា? កិច្ចប្រជុំជាទៀងទាត់មួយខែម្តង ដូចប្រជុំនៅថ្នាក់ស្រុកដែរ។ តើនេះត្រឹមត្រូវទេដែលថា កិច្ចប្រជុំរបស់ថ្នាក់តំបន់ហ្នឹង គឺប្រជុំរៀងរាល់ខែនោះ?"។

**ផ៖** ត្រឹមត្រូវ។

**ស៖** កម្មវត្ថុមួយដែលលោកស្រី បានបង្ហាញជូនម្សិលមិញ គឺថាកិច្ចប្រជុំរបស់ថ្នាក់តំបន់ គឺប្រជុំជាញឹកញាប់។ សំណួររបស់ខ្ញុំគឺថា តើគណៈកម្មាធិការស្រុកមានអំណាចសម្រេចអ្វី ដែលត្រូវធ្វើចំពោះអ្នកដែលប្រព្រឹត្តខុសទេ ដូចជាអ្នកប្រព្រឹត្តខុសសីលធម៌ ឬក៏ត្រូវតែរាយការណ៍ជូនថ្នាក់តំបន់? ថាតើអ្នកណាជាអ្នកមានសិទ្ធិអំណាចសម្រេចទៅលើអ្នកទាំងឡាយណាដែលប្រព្រឹត្តខុសនោះ?

[១១:៤៦:៣១]

**ផ៖** អ្នកមានប្រព្រឹត្តខុស ក្នុងគណៈស្រុកទាំងអស់គឺអត់មានសិទ្ធិសម្រេចទេ ហេតុនេះមុននឹងយើងធ្វើអី ទាល់តែយើងសួរមតិខាងគណៈតំបន់ បើខាងក្រោមអត់មានសិទ្ធិធ្វើទេ គ្រាន់តែបានប្រជុំមែនតែអត់មានបានធ្វើអីទាំងអស់។ ព្រោះដល់តំបន់ថា ឥឡូវអ្នកហ្នឹងខុសខ្លាំងអីខ្លាំង អាហ្នឹងយើងបញ្ជូនឲ្យគាត់អត់មានសិទ្ធិទេ ខាងក្រោមអត់បានធ្វើទេ។ ហ្នឹងតាមខ្ញុំពិនិត្យផ្ទាល់នៅកន្លែងខេត្តកំពតកន្លងទៅអីចឹង។ វាអត់មានបញ្ហាទេ ទាល់តែតំបន់ហ្នឹង យើងដូចថា ខុសស្អីរឿងអីខុសទៅអាហ្នឹងអត់បានសម្រេចទេខាងក្រោម ទាល់តែរាយការណ៍ឲ្យតា កង ចាប ហ្នឹងគាត់សម្រេចយ៉ាងម៉េច បញ្ជូនឲ្យគាត់អប់រំ។ នេះ ខ្ញុំសូមលើកប៉ុណ្ណឹង។

**ស៖** ទាក់ទងទៅនឹងនីតិវិធី គឺរបៀបរបបដែលលោកស្រីរាយការណ៍ទៅឲ្យ កង ចាប តើលោកស្រីរាយការណ៍ តែនៅក្នុងពេលប្រជុំ ឬក៏លោកស្រីរាយការណ៍តាមរយៈលិខិតស្នាមផ្សេងៗទៀតដែរ?

**ឆ៖** រាយការណ៍ឲ្យ កង ចាប អត់មានធ្វើតាមលិខិតស្នាមទេ គឺរាយការណ៍នឹងមាត់ជាមួយនឹងគណៈស្រុកហ្នឹង ឲ្យច្បាស់លាស់សិន។ មុននឹងយើងរាយការណ៍មិនមែនចេះតែរាយទេ ព្រោះមនុស្សនេះយើងថាមិនល្អ តែយើងរាយការណ៍ទៅ វាអាចប៉ះពាល់ដល់គេ។ អ៊ីចឹងយើងប្រជុំគ្នាពិភាក្សាគ្នាល្អិតល្អន់ដែរ មុននឹងរាយការណ៍ឲ្យ កង ចាប។ នេះ សូមជម្រាបប៉ុណ្ណឹង។

[១១:៤៨:៣០]

**ស៖** ការបកប្រែបញ្ជាក់ថា លោកស្រីរាយការណ៍ទៅឲ្យ កង ចាប តើវាជាការរាយការណ៍លាយលក្ខណ៍អក្សរ ឬក៏ជាការរាយការណ៍ដោយផ្ទាល់មាត់ក្នុងពេលប្រជុំ?

**ឆ៖** លាយលក្ខណ៍អក្សរ។ ខ្ញុំសូមជម្រាបថា លាយលក្ខណ៍អក្សរ មិនមែនរាយការណ៍មាត់ទទេទេ។

**ស៖** ហើយអ្នកណាជាអ្នកមានសិទ្ធិអំណាចរាយការណ៍ទៅឲ្យលេខតំបន់ហ្នឹង?

**ឆ៖** គ្មានសិទ្ធិទេ គឺទាំងអស់គ្នា គឺយើងយកមតិទាំងអស់គ្នារាយការណ៍តែម្តង អត់មានអ្នកណាមានសិទ្ធិរាយការណ៍ម្នាក់ឯងទេ គឺនៅក្នុងគណៈស្រុកហ្នឹង គឺយើងនិយាយយកជាមូលមតិគ្នាហើយយើងរាយការណ៍ទៅ អត់មានអ្នកណាសម្រេចម្នាក់ទេ។ សម្រេចទាំងអស់គ្នា។

[១១:៤៩:៤៥]

**ស៖** តើរបាយការណ៍ជាលាយលក្ខណ៍អក្សរហ្នឹងធ្វើតាមរបៀបជាសារទូរលេខ ឬក៏ធ្វើតាមរយៈនីរសារ ដើម្បីយកទៅរាយការណ៍ជូនលេខាតំបន់ហ្នឹង?

**ឆ៖** តាមរយៈនីរសារឲ្យយកទៅ អត់មានតាមទូរលេខទេ ឲ្យយកទៅគាត់ទៅ។

**ស៖** តើតំបន់៣៥ មានការិយាល័យសារទូរលេខហ្នឹងដែរទេ?

**ឆ៖** គណៈតំបន់គាត់ចាត់ចែង ខ្ញុំអត់ដឹងដែរ ការងារគាត់។

**ស៖** ចាតើត្រូវទទួលសិទ្ធិអំណាចពីអ្នកណា ដែលដើម្បីសម្រេចសម្លាប់អ្នកណាម្នាក់ ឬក៏ត្រូវតែទទួលសិទ្ធិ ឬក៏ការអនុញ្ញាតពីថ្នាក់តំបន់?

**ឆ៖** កាលនោះ ខ្ញុំជាគណៈតំបន់មែន តែការសិទ្ធិសម្រេចសម្លាប់មនុស្សអី ខ្ញុំអត់បានដឹងទេ ព្រោះខ្ញុំជាសមាជិកទី៦ឯណោះ ហើយខ្ញុំនៅជាមួយប្រជាជនពលរដ្ឋនៅក្រោមនេះ ខ្ញុំធ្វើស្រែចម្ការ

ហើយគណៈកម្មការទាំងអស់ មិនដឹងជាគាត់សម្រេចជាមួយអ្នកណាខ្លះ ខ្ញុំអត់បានដឹងដែរ ព្រោះការសម្រេចសម្លាប់មនុស្សអី ខ្ញុំមិនបានចូលរួមទេ។ កាលនោះ គឺគាត់សម្រេច ដូចជាគណៈកម្មការគាត់ប៉ុន្មាន ប្រាំប្រាំមួយនាក់ហ្នឹង មិនដឹងគាត់សម្រេចយ៉ាងម៉េច ខ្ញុំអត់បានដឹងដែរ ហ្នឹងខ្ញុំសូមជម្រាបត្រង់ហើយ ព្រោះខ្ញុំក្នុងគណៈកម្មការតំបន់មែន តែខ្ញុំមិនបានចូលរួមការសម្រេចសម្លាប់មនុស្សអី ខ្ញុំមិនបានចូល។ សូមជម្រាបត្រង់តែម្តង។

[១១:៥២:០២]

**ស៖** តើកិច្ចប្រជុំរបស់ថ្នាក់តំបន់៣៥ ហ្នឹង គេមានរក្សាកំណត់ហេតុប្រជុំដែរឬទេ?

**ឆ៖** កាលហ្នឹង គាត់លេខា គាត់អ្នកកំណត់ហេតុខ្លួនគាត់។ គាត់កំណត់ហេតុ គាត់លើកពីបញ្ហាប្រជុំហ្នឹង គាត់មានកំណត់ហេតុគាត់ តែជួនកាល ខ្ញុំក៏មិនបានកត់ទុក គាត់កត់នេះ គាត់និយាយមកយើងស្តាប់ទៅ តែឲ្យខ្ញុំកត់ទុកអី ខ្ញុំមិនបានកត់ទុកទេ ព្រោះកំណត់ហេតុគាត់មាន។ តែមិនដឹងគាត់--ធ្វើខ្លួនគាត់ គាត់អ្នកប្រជុំ ព្រោះគាត់លេខា។

**ស៖** តើលោកស្រីដឹងថា កំណត់ហេតុប្រជុំរបស់តំបន់៣៥ ហ្នឹង គេយកទៅធ្វើរបៀបម៉េចដែរ គេមានចែកចាយឲ្យដឹងឮដែរឬទេ?

**ឆ៖** អត់ទេ គាត់ច្រើនតែសរសេរកូនសៀវភៅគាត់។ គាត់សរសេរម្នាក់គាត់ហ្នឹង គាត់លើកប្រជុំតែម្តង។ អានេះ យើងអត់បានទៅ-- យើងក៏អត់បានដឹងថាគាត់លើកពីអី គ្រាន់តែខទ្វេសនាមតាមការសរសេររបស់គាត់ យើងស្តាប់គាត់ទៅ តែគាត់មិនបានឲ្យយើងសរសេរទេ អ៊ីចឹង។

**ស៖** ក្នុងពេលដែលលោកស្រីជាសមាជិករបស់គណៈកម្មាធិការតំបន់៣៥ តើលោកស្រីបានចូលរួមប្រជុំជាមួយនឹងគណៈកម្មាធិការស្រុកកំពតដែរឬទេ?

**ឆ៖** ខ្ញុំជាគណៈកម្មការតំបន់៣៥។ ខ្ញុំទិសដៅខ្លួនខ្ញុំ គឺជំនួយការរបស់ស្រុកកំពត។ អ៊ីចឹង ខ្ញុំត្រូវតែចូលប្រជុំ កន្លងទៅ ខ្ញុំរៀបរយបញ្ហាប្រជុំជាមួយលេខាស្រុក។ បញ្ហាដាក់ផែនការអី គឺមានខ្ញុំក្នុងហ្នឹងដែរ អ៊ីចឹងខ្ញុំចូលប្រជុំ។ ខ្ញុំមិនដែលខានទេ ឲ្យតែលេខាគាត់ប្រជុំ ខ្ញុំប្រជុំដែរ។ ប៉ុន្តែការប្រជុំនេះ ក៏អត់មាននិយាយពីអីដែរ យើងនិយាយពីទិសដៅសំខាន់ គឺកសាងទំនប់ កសាងប្រឡាយទឹក លើកស្រែប្រព័ន្ធភ្លឺអីអ៊ីចឹង អត់មានធ្វើអី ហើយឲ្យប្រជាជនធ្វើតែប៉ុណ្ណឹង អត់មាននិយាយពីអីទេ ពិសេសប្រឡាយទឹកអីភ្លឺអី ប៉ុណ្ណឹង។ ខ្ញុំបានចូលរួមប្រជុំជាមួយលេខាស្រុកហ្នឹង ព្រោះធ្វើអីទាំងអស់ បើយើងមិនបានប្រជុំ យើងមកនៅជំនួយការគាត់ម៉េចបាន។ នេះ ខ្ញុំសូមលើកប៉ុណ្ណឹង។

[១១:៥៥:០០]

**ស៖** តើគណៈកម្មាធិការស្រុកហ្នឹងប្រជុំញឹកញាប់ប៉ុន្មានដងដែរ?

**ឆ៖** គណៈកម្មាធិការស្រុកហ្នឹងមានពេលវេលាដូចថា ការងារណាចាំបាច់យើងប្រជុំជាប់ទៅពេលណានេះ ដូចថា បីខែ ឬក៏មួយខែម្តងអីអ៊ីចឹងទៅ ដើម្បីពិនិត្យផែនការដែលយើងដាក់ចុះ ហើយយកមកមើលអ្នកណាធ្វើបានអីៗ អ៊ីចឹងទៅ យើងពិនិត្យទាំងអស់គ្នា។ អាហ្នឹងមួយខែ ឬក៏បីខែយើងប្រជុំម្តង ឬក៏មួយខែប្រជុំម្តង។ អាហ្នឹងមានការចាំបាច់ យើងប្រជុំទៅ បើអត់ទេ ក៏អត់ទៅ។

**ស៖** តើគណៈកម្មាធិការស្រុកទទួលបានរបាយការណ៍ ជាលាយលក្ខណ៍អក្សរពីឃុំនីមួយៗដែលស្ថិតនៅក្នុងស្រុកហ្នឹងដែរឬទេ?

**ឆ៖** គណៈកម្មាធិការស្រុកទទួលបានពីឃុំ ព្រោះឃុំត្រូវរាយការណ៍មួយខែម្តង ទទួលបានជាប់រាល់ខែហ្នឹង។

**ស៖** តើកម្មវត្ថុ ឬក៏ការរាយការណ៍ជារួមទូទៅរៀងរាល់ខែហ្នឹង គឺឃុំរាយការណ៍មកស្រុកហ្នឹងរាយការណ៍អ្វីដែរ?

**ឆ៖** រាយការណ៍អំពីការធ្វើ ដូចថាយើងពេលនៅខែវស្សាអ៊ីចឹង យើងត្រូវការស្ទូង ដកស្ទូង ហើយនៅ ឃុំណានៅ ឃុំណាស្ទូងហើយ ឃុំណាមិនទាន់ហើយ យើងរាយការណ៍ពីការជាក់ស្តែងអំពីការធ្វើរបស់ប្រជាជន។ ដូចជាឥឡូវយើងដាក់ផែនការ ឬស្រុកគាត់ដាក់ផែនការឲ្យធ្វើទំនប់មួយ ទំនប់ភូមិណាមួយ ឥឡូវទំនប់ហ្នឹងហើយនៅ នៅសល់ប៉ុន្មានទៀតមិនទាន់ហើយ។ អ៊ីចឹងទៅរាយការណ៍តាមផែនការដែលយើងដាក់ចុះ។

[១១:៥៧:១១]

**ស៖** *(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

អត់មានការបកប្រែជាភាសាខ្មែរផង។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** គឺថាតើកម្មវត្ថុទូទៅ ដែលឃុំរាយការណ៍ជាទៀងទាត់មកឲ្យគណៈកម្មាធិការស្រុកហ្នឹង តើមានរាយការណ៍ អំពីអ្នកដែលប្រព្រឹត្តកំហុសសីលធម៌ កំហុសផ្សេងៗ ឬក៏រាយការណ៍ពីអ្នកដែលជាខ្មាំងរបស់បក្ស តើនេះជាកម្មវត្ថុនៃការរាយការណ៍ទូទៅ ពីឃុំមកស្រុក ឬយ៉ាងណាដែរ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី នួន ជា!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាយើងត្រូវការការណែនាំពី-- គោលការណ៍ណែនាំពីអង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងសំណួរទៅនឹងរចនាសម្ព័ន្ធ និងការប្រាស្រ័យទាក់ទង-- សាក្សីត្រូវឆ្លើយសំណួរនេះ ប៉ុន្តែសំណួរទាក់ទងក្រៅពីនេះមិនគួរត្រូវបានអនុញ្ញាតទេ។ ខ្ញុំគិតថា សំណួរបែបនេះគឺថា មិនស្ថិតនៅក្នុងវិសាលភាពនៃសវនាការក្នុងដំណាក់កាលដំបូងនេះទេ។ ដូច្នេះខ្ញុំសូមឲ្យមានការណែនាំពីអង្គជំនុំជម្រះ។

**លោក ដេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបទៅ ផ្នែកនៃដីកាជំនុំជម្រះ គឺជាផ្នែកមួយនៃសំណុំរឿងនេះ គឺនៅក្នុងកថាខណ្ឌ៧៦ និយាយអំពីថាតើថ្នាក់តំបន់ ថ្នាក់ស្រុក រាយការណ៍ទៅគណៈកម្មាធិការមជ្ឈិមអំពីការបង្កបង្កើនផល ការប្រមូលផលស្រូវ ការដឹកប្រឡាយ និងអំពីការរាយការណ៍ស្ថានភាពខ្មាំង។ នេះមិនមែនជាគោលបំណងរបស់យើងខ្ញុំ ដែលចង់បានចម្លើយជាក់លាក់នេះទេ។ បើមិនមានចម្លើយពាក់ព័ន្ធទៅនឹងបញ្ហាទូទៅនោះទេ។ ដូច្នេះ យើងមិនអាចទទួលបានចម្លើយពាក់ទៅនឹងបញ្ហាជាក់លាក់នោះទេ។

[១២:០០:០០]

**ប្រធានអង្គជំនុំ៖**

ជំទាស់របស់មេធាវីអន្តរជាតិការពារក្តី នួន ជា គ្មានប្រសិទ្ធភាពចំពោះសំណួរនេះ។ សាក្សីត្រូវឆ្លើយតបទៅនឹងសំណួរដែលសួរដោយសហព្រះរាជអាជ្ញាអម្បាញ់មិញនេះ ដោយអង្គជំនុំជម្រះក៏ត្រូវការស្តាប់នូវចម្លើយរបស់សាក្សីតបទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាដែរ។

**លោកស្រី ប្រាក់ យុត៖**

សូមសួរម្តងទៀត ខ្ញុំស្តាប់មិនបាន។

[១២:០០:៣៩]

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញាអន្តរជាតិសួរសំណួរអម្បាញ់មិញនេះម្តងទៀត ដោយគាត់ថាភ្លេចសំណួរដែលលោកចង់សួរគាត់ ដើម្បីឲ្យគាត់ស្តាប់បានអាចឆ្លើយតបទៅនឹងសំណួរដែលលោកសួរ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សំណួររបស់ខ្ញុំ គឺកម្មវត្ថុដែលត្រូវរាយការណ៍ពីឃុំមកឲ្យគណៈកម្មាធិការស្រុក គឺពាក់ព័ន្ធទៅនឹងអ្នកដែលប្រព្រឹត្តកំហុស ឬកំហុសសីលធម៌ ឬក៏ខ្មាំងដែលត្រូវបានរកឃើញ។ តើនេះ គឺជាកម្មវត្ថុរាយការណ៍ជាទូទៅពីថ្នាក់ឃុំមកថ្នាក់ស្រុក ឬក៏យ៉ាងណាដែរ?

[១២:០១:៣០]

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំសូមឆ្លើយ។ សំណួរនេះ គឺយើងបានរាយការណ៍អំពីថ្នាក់ស្រុកមកថ្នាក់-- ថ្នាក់ឃុំមកថ្នាក់ស្រុក។ រាយការណ៍អំពីផលិតផលដែលយើងកើតឡើងហើយ។ ហើយទីពីរ អំពីមានការខុសឆ្គងបងប្អូនខ្លះដែលមានការខុសឆ្គង ដូចបានសំណួរបានលើក គឺយើងលើកបញ្ហានេះមក ឃើញថាខ្ញុំឯកភាពត្រង់ថា មិនមែនចង់ឯកភាពថា ខ្មាំងអីទេ ប៉ុន្តែការខុស គឺធម្មតា ឃុំភូមិយើងត្រូវជួយមតិគ្នាអប់រំ មិនមែនយកមកជាចំណាប់ខ្មាំងវាយចោល ធ្វើបាបធ្វើឃាតអីទេ។ កន្លងទៅខ្ញុំក៏នៅទីហ្នឹងដែរ គឺនិយាយរួមដោយការស្មោះត្រង់ចំពោះលោកមេធាវី គឺខ្ញុំក៏មានអ្នកនេះដែរ គឺជួយដូចថា អ្នកខុស អ្នកអាក្រក់អ៊ីចឹង។ មិនមែនថា យើងថាខ្មាំងទាំងអស់ទេ វាមានអ្នកល្អអ្នកអាក្រក់ យើងជួយអប់រំ ក្នុងឃុំក្នុងអីក៏ចេះតែជួយអប់រំទៅ តិចតួចអ៊ីចឹង។ អាហ្នឹងខ្ញុំសូមជម្រាបប៉ុណ្ណឹង។ សូមអស់ចម្លើយហើយ។ បើមិនច្បាស់សូមឲ្យសួរទៀត។

[១២:០២:៥៦]

**ស៖** សូមអរគុណចំពោះចម្លើយនេះ។ សំណួរ តើមានកម្មវត្ថុណាផ្សេងទៀតដែលឃុំត្រូវរាយ-ការណ៍មកឲ្យគណៈកម្មាធិការស្រុក ហើយស្រុករាយការណ៍ទៅឲ្យគណៈកម្មាធិការតំបន់អំពីអ្នកដែលធ្វើការនៅតាមការដ្ឋាន ដូចជាការដ្ឋានលើកទំនប់ជាដើម? តើនេះគេត្រូវរាយការណ៍នៅក្នុងរបាយការណ៍នោះដែរឬទេ?

**ឆ៖** អាហ្នឹង ខ្ញុំសូមជម្រាប ទាំងអស់ត្រូវតែរាយការណ៍ របាយការណ៍ឲ្យស្រុក។ ស្រុក-- ឃុំឲ្យស្រុកៗ ឲ្យតំបន់ហើយ អំពីការធ្វើដែលយើងបានដាក់ផែនការចុះមក គឺបានរាយការណ៍ទាំងអស់ហ្នឹង ឲ្យតំបន់ជាលាយលក្ខណ៍អក្សរ ធ្វើតាមដែលយើងធ្វើបាន។ កន្លែងណាធ្វើបាន កន្លែងណាធ្វើមិនបាន

គឺរាយការណ៍តាមជាក់ស្តែង តាមលាយលក្ខណ៍អក្សរ។ នេះខ្ញុំសូមជម្រាបប៉ុណ្ណឹង។

[១២:០៤:០០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងសហព្រះរាជអាជ្ញា ហើយអរគុណសាក្សី។ ឥឡូវនេះដល់សមល្មមសម្រាកពិសាអាហារថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសដើម្បីពិសាអាហារថ្ងៃត្រង់ ហើយអង្គជំនុំជម្រះ--កិច្ចដំណើរការសវនាការនឹងចាប់ផ្តើមដំណើរការបន្តនៅរសៀលនេះម៉ោងមួយសាមសិបនាទី។

ហើយមន្ត្រីច្បាប់ជួយសម្របសម្រួលដល់សាក្សីរូបនេះ ដើម្បីឱ្យគាត់មានលទ្ធភាពអាចបង្ហាញខ្លួននៅក្នុងបន្ទប់សវនាការនេះបានតាមម៉ោងពេលកំណត់។ ហើយអនុរក្សមន្ទីរឃុំឃាំងឱ្យនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោម ហើយនិងឱ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញនៅរសៀលនេះឱ្យបានមុនម៉ោងមួយសាមសិបនាទីជាកំណត់។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:០៥ នាទី ដល់ម៉ោង ១៣:៣៦ នាទី)*

[១៣:៣៦:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាកិច្ចបន្តនេះ អង្គជំនុំជម្រះផ្តល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការបន្តសំណួរចំពោះសាក្សីរូបនេះ។ ហើយសហព្រះរាជអាជ្ញាមានពេលវេលាមួយម៉ោងទៀតនៅក្នុងការតាំងសំណួរ។

សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅពេលដែលយើងឈប់សម្រាកអាហារថ្ងៃត្រង់ យើងកំពុងតែលើកឡើងអំពីកម្មវត្ថុដែលរាយការណ៍ពីឃុំទៅដល់ស្រុក រហូតទៅដល់ថ្នាក់តំបន់។ ខ្ញុំចង់សុំសួរលោកស្រី ថាតើការរាយការណ៍ពី

ឃុំទៅដល់ស្រុកទៅដល់តំបន់នោះ គឺមានរាយការណ៍អំពីទុក្ខលំបាករបស់ខាងប្រជាជនដែរឬទេ? ឧទាហរណ៍ថា ការអត់ឃ្លាន និងបញ្ហាលំបាកៗផ្សេងៗ តើមានរាយការណ៍ទៅលើដែរឬទេ? ទៅស្រុកទៅតំបន់?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំសូមឆ្លើយ។ ការរាយការណ៍នេះ គឺមានការរាយការណ៍អំពីទុក្ខលំបាករបស់ប្រជាជនដែរ ការរស់នៅមានការស្រួល មានការលំបាករបស់ប្រជាជន គឺមានការរាយការណ៍ខ្លះដែរ។ រាយការណ៍ឲ្យស្រុក ស្រុករាយការណ៍ឲ្យតំបន់ដែរ។ ព្រោះការរស់នៅ វាមានការលំបាក មានការស្រួល។ សូមអស់ចម្លើយ។

[១៣:៣៨:២៧]

**ស៖** ថាតើស្រុកបានជូនដំណឹងទៅដល់តំបន់ថា អត់មានអាហារគ្រប់គ្រាន់ ហើយប្រជាជនកំពុងតែអត់ឃ្លានដែរឬទេ? ដាច់ពោះដែរឬទេ?

**ឆ៖** ស្រុកបានរាយការណ៍ឲ្យតំបន់ខ្លះដែរ ដូចជាកន្លែងខ្លះ ឧទាហរណ៍ដូចជាកន្លែងធ្វើប្រឡាយអីអ៊ីចឹង អត់បាយ អត់ទឹក គឺស្រុកបានរាយការណ៍ឲ្យតំបន់ដែរ ឲ្យគាត់ជួយដោះស្រាយបញ្ហានេះ។

*(មានបញ្ហាបច្ចេកទេស)*

[១៣:៣៩:៤៦]

**ស៖** សូមអរគុណដែលលោកស្រីបានឆ្លើយ។ ថាតើរបាយការណ៍ដែលបញ្ជូនទៅថ្នាក់តំបន់បានរាយការណ៍អំពីមនុស្ស ចំនួនមនុស្សឈឺ និងចំនួនមនុស្សស្លាប់នៅក្នុងស្រុកដែរឬទេ?

**ឆ៖** ខ្ញុំសូមឆ្លើយ។ ការរាយការណ៍ គឺស្រុកបានរាយការណ៍ឲ្យពីមានអ្នកជំងឺ មានអ្នកឈឺថ្កាត់អី គឺមានរាយការណ៍ដែរតើ ហើយអ្នកស្លាប់អីមិនសូវមានទេ សំខាន់គឺមានអ្នកជំងឺខ្លះ។ ខ្ញុំសូមអស់មតិ។

**ស៖** នៅពេលដែលអ្នកស៊ើបអង្កេតពីតុលាការទៅសួរលោកស្រី នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ ២០០៩ គឺឯកសារលេខ D234/15 ចម្លើយលេខ២៨ លោកស្រីបានឆ្លើយដូចតទៅថា "សំណួរ៖ តើលោកស្រីមានរាយការណ៍អំពីមនុស្សឈឺទៅថ្នាក់លើដែរឬទេ? និងអ្នកស្លាប់ទៅថ្នាក់លើដែរឬទេ? ចម្លើយ៖ គឺខ្ញុំរាយការណ៍ទៅថ្នាក់លើ អំពីមនុស្សដែលឈឺ ហើយក៏បានស្នើសុំឲ្យខាងលើជួយផងដែរ។ ខ្ញុំក៏បានរាយការណ៍ អំពីចំនួនមនុស្សស្លាប់ទៅថ្នាក់លើផងដែរ។" សូមបញ្ជាក់សម្តីលោកស្រីដែលបាន

ឆ្លើយ។ ថាតើចម្លើយរបស់លោកស្រី ដែលឆ្លើយជូនអ្នកស៊ើបអង្កេតនោះ ឆ្លើយដោយស្មោះត្រង់ដែរឬទេ? លោកស្រី ប្រាក់ យុត តើលោកស្រីបានរាយការណ៍ អំពីមនុស្សដែលស្លាប់ និងមនុស្សដែលឈឺទៅថ្នាក់លើថ្នាក់តំបន់នេះដែរឬទេ?

[១៣:៤១:៥០]

**ឆ៖** ចាស ខ្ញុំបានឆ្លើយរឿងពិត។ ខ្ញុំបានរាយការណ៍។

**ស៖** ចំពោះបញ្ហារាយការណ៍ទៅថ្នាក់ស្រុក និងថ្នាក់តំបន់ និងភូមិភាគ តើមេដឹកនាំស្រុក តំបន់ និងភូមិភាគ ត្រូវបានគេជូនដំណឹង អំពីការចាប់ខ្លួនកម្មាភិបាលនៅក្នុងស្រុកនីមួយៗដែរឬទេ? តើមានអ្នកដឹកនាំគេជម្រាបយើងអំពីផែនការចាប់មនុស្សដែរឬទេ?

**ឆ៖** អ្នកដឹកនាំគឺមិនបានប្រាប់ខ្ញុំ អំពីការចាប់មនុស្សទេ។ ខ្ញុំមិនបានដឹងទេរឿងហ្នឹង។

**ស៖** តើគេមានប្រាប់លោកស្រីឲ្យបានដឹងមុន អំពីការចាប់ខ្លួនប្ដីរបស់លោកស្រីដែរឬទេ?

**ឆ៖** ខ្ញុំសូមចម្លើយ។ មុននឹងចាប់ប្ដី គឺគាត់បានប្រាប់ខ្ញុំដែរ តាម៉ុក គាត់ថា ប្ដីខ្ញុំគេចាប់ ហើយខ្ញុំក៏បានទៅជួបគាត់ដែរ។ ចាប់មិនដឹងខែណាមិនដឹងថ្ងៃណាទេ ប៉ុនគាត់ប្រាប់ខ្ញុំតែប៉ុណ្ណឹង។

**ស៖** ប្រហែលជាមានចំណុចមួយចំនួន មានការបកប្រែមិនសូវត្រូវ។ ថាតើគេមានប្រាប់លោកស្រីមុនពេលដែលចាប់ខ្លួនប្ដីលោកស្រីហ្នឹង គេមានប្រាប់លោកស្រីមុនដែរឬទេ ថានឹងចាប់ខ្លួនប្ដីលោកស្រី?

**ឆ៖** មុននឹងចាប់ប្ដីខ្ញុំ គឺគាត់បានប្រាប់មុន បានប្រាប់មុន ខ្ញុំនិយាយអំមិញខុស។ បានប្រាប់មុនប្រហែលជាពីរបីថ្ងៃថា ប្ដីខ្ញុំត្រូវចាប់ តាម៉ុក គាត់បានប្រាប់។

[១៣:៤៤:២២]

**ស៖** ថាតើគេប្រាប់មុនរយៈពេលប៉ុន្មានដែរ ដែលតាម៉ុក ជូនដំណឹងថា គេនឹងចាប់ប្ដីរបស់លោកស្រីនោះ?

**ឆ៖** រយៈកាលបីថ្ងៃ។

**ស៖** តើគេមានព្រមាន-- ខាងអ្នកដែលនៅថ្នាក់តំបន់នោះ មានដែលព្រមាន និងជូនដំណឹងលោកស្រីមុន អំពីការចាប់ខ្លួនប្ដីលោកស្រីដែរឬទេ?

**ឆ៖** គណៈតំបន់អត់បានប្រាប់ខ្ញុំទេ គឺមានតែ តាម៉ុក ទេប្រាប់ខ្ញុំ។ តំបន់អត់បានហៅខ្ញុំទៅជួបរឿងចាប់ប្ដីហ្នឹងផង។

[១៣:៤៥:១៩]

**ស៖** ខ្ញុំសាកល្បងព្យាយាមរំឭក ប្រសិនបើលោកស្រីចងចាំ។ ចម្លើយដែលលោកស្រីបានផ្ដល់អ្នកស៊ើបអង្កេតនៅខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារលេខ D234/15 នៅក្នុងចម្លើយលេខ៣៤ លោកស្រីឆ្លើយថា វាមិនមែនលេខាតំបន់ដែលប្រាប់ខ្ញុំអំពីការចាប់ខ្លួន វាមិនត្រឹមតែលេខាតំបន់ដែលប្រាប់ខ្ញុំអំពីការចាប់ខ្លួនប្ដី តាម៉ុក ក៏ប្រាប់ខ្ញុំអំពីបញ្ហាចាប់ប្ដីរបស់ខ្ញុំនេះដែរ។ តើវាត្រឹមត្រូវដែរឬទេ ដែលថាលោកស្រីជម្រាបអ្នកស៊ើបអង្កេត ថាទាំងខាងលេខាស្រុក រួមទាំង តាម៉ុក នេះ បានប្រាប់លោកស្រីអំពីការចាប់ប្ដីរបស់លោកស្រីជាមុន?

**ឆ៖** ខ្ញុំសូមជម្រាបបញ្ហានេះ ខ្ញុំនិយាយក៏វាខុសដែរ តាមការសង្កេតរបស់លោក។ គឺបានស្រុកគឺតាណយ គាត់បានប្រាប់ខ្ញុំ ហើយនៅក្នុងហ្នឹងតំបន់ក៏បានប្រាប់ខ្ញុំ ហើយ តាម៉ុក ក៏បានប្រាប់ខ្ញុំ។ នេះជារឿងពិត ដូចខ្ញុំបានលើក។

**ស៖** តើលោកស្រីអាចជម្រាបអង្គជំនុំជម្រះដែរឬទេ ថាតើភូមិភាគ និងតំបន់រួមទាំងស្រុកនោះហេតុបានគេបានដឹងមុនអំពីការចាប់ខ្លួនប្ដីរបស់លោកស្រី តើលោកស្រីអាចជម្រាបបានទេ គេដឹងដោយរបៀបណា?

[១៣:៤៧:០៥]

**ឆ៖** ខ្ញុំមិនបានដឹងពីរឿងចាប់ប្ដីហ្នឹង ព្រោះភូមិភាគហើយនិងតំបន់ ឬស្រុក មិនដឹងគាត់ដឹងរឿងហ្នឹង ពីណា ស្រាប់ដល់-- ខ្ញុំអត់បានដឹងសោះពីមុន អត់មានដឹងពីរឿងចាប់ប្ដីហ្នឹងទេ។ ដល់តែថ្ងៃក្រោយឡើង បានឮ តាណយ ឮគណៈស្រុក គណៈតំបន់ហ្នឹងប្រាប់ខ្ញុំ ហើយ តាម៉ុក នឹងប្រាប់ខ្ញុំម្ដង។ ខ្ញុំមិនដែលបានដឹងអារឿងគេថា ចង់ចាប់ប្ដីហ្នឹង ដល់គេហៅប្រាប់ ខ្ញុំក៏មិនដឹងថាម៉េចដែរ បើគាត់ថាចាប់ហើយ។ ហើយអត់ដឹងពីមុនសោះ ដឹងអាពេលដែលគាត់ហៅទៅប្រាប់ហ្នឹង។

**ស៖** តើប្ដីរបស់លោកស្រីមានតួនាទីអ្វីដែរ? តើគាត់ធ្វើអ្វីដែរ នៅក្នុងអំឡុងពេលនុ៎ង?

**ឆ៖** ប្ដីខ្ញុំកាលពេលមុនចាប់ហ្នឹង អត់មានធ្វើអីទេ។ គាត់ឋានៈប្រធានមន្ទីរ តំបន់របស់ កងចាប។ គាត់ឋានៈប្រធានមន្ទីរ ហើយគាត់អត់មានធ្វើមេស្រុកអី មេអីទេ គឺគាត់ធ្វើប្រធានមន្ទីរ កង ចាប គាត់ជាស្មៀន។ គាត់អត់មានធ្វើអីទេ។

**ស៖** តើលោកស្រីបានជម្រាបទៅប្ដីជាមុនទេ ថាគេនឹងចាប់ខ្លួនគាត់ហើយ?

**ឆ៖** ខ្ញុំអត់មានប៊ានជម្រាបទេ ពេល តាម៉ុក ប្រាប់ខ្ញុំ។ ខ្ញុំអត់មានដែលនិយាយជាមួយគាត់ទេ

កាលនិយាយទៅ ក៏គាត់ណែនាំខ្ញុំថា បើសិនជាប្រាប់ប្ដីគឺមានរឿងដល់ខ្ញុំ។ អ៊ីចឹង ខ្ញុំអត់ប៉ាានប្រាប់។

[១៣:៤៩:០៦]

**ស៖** សូមអរគុណដែលលោកស្រីបានឆ្លើយសំណួរទាំងឡាយដែលខ្ញុំបានសួរ។ លោកស្រីបានឆ្លើយជាច្រើនដងរួចមកហើយ ដែលថាលោកស្រីបានទទួលណែនាំ និងបង្គាប់ទាំងឡាយដែលបានផ្ដល់ជូនមកលោកស្រី ដូចជា តាម៉ុក ជាដើម ដែលបានផ្ដល់ការបង្គាប់ ហើយថាតើលោកស្រីអាចរៀបរាប់ទេ ប្រសិនបើមិនស្ដាប់បង្គាប់ខាងថ្នាក់លើនោះ តើយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា គឺមានការណែនាំរបស់ខាងលើ ពេលចាប់ប្ដី។ ចាប់ប្ដី បើសិនជាខ្ញុំមានការប្រឆាំង ឬទំនាស់ គឺខ្ញុំមិនប៉ាានដែរ ព្រោះសម័យនោះ លោកក៏ដឹងដែរថា ខ្ញុំមិនប៉ាាននិយាយអីទាំងអស់ និយាយរួមគឺថាគេបញ្ជាម៉េចគឺធ្វើទៅតាមបញ្ជារបស់ថ្នាក់លើព្រោះខ្ញុំអត់ប៉ាាន។ នេះខ្ញុំសូមរាយ-ការណ៍ស្មោះត្រង់អ៊ីចឹងតែម្ដង ព្រោះខ្ញុំអត់ប៉ាាននិយាយអីទេ ព្រោះគាត់ប្រាប់មក ប្រាប់-- អត់ប៉ាាននិយាយជាមួយប្ដីផងហ្នឹង។ នេះខ្ញុំសូមជម្រាបដោយការស្មោះត្រង់ ព្រោះថាកាលនោះខ្ញុំក៏មិនប៉ាាននិយាយអីក្រៅពីផ្លូវការដែលគាត់ណែនាំទេ ព្រោះកាលណាគេណែនាំម៉េច គឺខ្ញុំធ្វើអ៊ីចឹង។ ហើយកាលណាខ្ញុំនិយាយទៅខុស ប្ដីរត់បាត់ ខ្ញុំមិនរឿង អ៊ីចឹងខ្ញុំអត់ប៉ាាននិយាយ នេះខ្ញុំសូមជម្រាបលោកប្រធានឲ្យបានច្បាស់ គឺអ៊ីចឹងកាលសម័យនោះ។

**ស៖** សូមអរគុណច្រើនលោកស្រី។ កាលពីម្សិលមិញគឺ គេសួរលោកអំពីមន្ទីរអប់រំនៅក្នុងស្រុកកំពត តាមរយៈការបកប្រែជាភាសាអង់គ្លេសលោកស្រីបានលើកឡើងថា មានប្រធានដែលគាត់ទទួលបន្ទុកការងារអប់រំ ហើយខ្ញុំមិនដឹងថាការបកប្រែនុ៎ងគឺយ៉ាងម៉េចនោះទេ។ ហើយខ្ញុំចង់ដឹងថា ប្រធានហ្នឹង តើនរណាគេដែរជាប្រធានគ្រប់គ្រងមន្ទីរអប់រំនៅស្រុកកំពត ប្រធានហ្នឹងជានរណាដែរ?

[១៣:៥១:៣៧]

**ឆ៖** ប្រធានកន្លែងមិនដឹងឈ្មោះអីទេ គាត់ស្លាប់បាត់ហើយ ភ្លេចឈ្មោះខ្ញុំ។ ប្រធានអប់រំ មន្ទីរអប់រំហ្នឹង គឺមានឈ្មោះអី ខ្ញុំវាភ្លេច ព្រោះយូរពេកភ្លេច មិនដឹងឈ្មោះអីទេ។ គាត់ប្រធានអប់រំជំនួសតាប្រធាន តាណយ ហ្នឹងដែរ ប៉ុន្តែខ្ញុំវាភ្លេចមិនដឹងឈ្មោះអីគាត់ស្លាប់យូរហើយ។ អ៊ីចឹងសូមអត់ទោសមិនដឹងគាត់ឈ្មោះអី។

**ស៖** ដើម្បីបញ្ជាក់បំភ្លឺលោកស្រីបានលើកឡើងថាប្រធាននុ៎ង គឺអត់ចាំឈ្មោះទេ ហើយប្រធានហ្នឹងគឺជាប្រធានមន្ទីរអប់រំនៅស្រុកកំពតហ្នឹង តើត្រឹមត្រូវដែរទេលោកស្រីនិយាយអ៊ីចឹងអំមិញ?

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** ខ្ញុំចង់សុំសួរលោកស្រីបន្តិចទៀតពាក់ព័ន្ធទៅនឹងពេលដែលលោកស្រីធ្វើជាលេខានៅស្រុកកំពង់សៀម។ ខ្ញុំសូមសួរបំភ្លឺមួយចំនួន ចំណុចមួយចំនួន លោកស្រីមុននេះនិយាយថា មុនពេលដែលខ្ញុំសួរនោះលោកស្រីនិយាយថា លោកស្រីនៅកំពង់សៀមប្រហែលជាពីរ ឬបីខែតែប៉ុណ្ណោះ។ ក៏ប៉ុន្តែផ្អែកតាមចម្លើយដែលលោកស្រីបានផ្តល់ និយាយនោះ លោកស្រីធ្វើជាលេខាស្រុកកំពង់សៀមនោះប្រហែលជាជាងមួយឆ្នាំណោះ។ តាំងពីពេលដែលលោកស្រីទៅដល់នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៨ រហូតទៅដល់ខែតុលា ឆ្នាំ១៩៧៨។ បានន័យថាអ៊ីចឹង តើកស្រីធ្វើជាលេខាហ្នឹងជាងមួយឆ្នាំពីខែកុម្ភៈ ឆ្នាំ៧៧ ដល់ខែតុលា ឆ្នាំ៧៨ មែនទេ?

[១៣:៥៣:៤៥]

**ឆ៖** ខ្ញុំធ្វើដូចមិនដល់មួយឆ្នាំផង ត្រឹមខែប្រាំបី។ មិនបានមួយឆ្នាំ ប៉ុនបើក្នុងគម្រោងដែល ខ្ញុំបាននិយាយក្នុងសង្កេតការណ៍ អាហ្នឹងខ្ញុំក៏ឆ្លើយថា រឿងហ្នឹងវាពិតទៅចុះ។

**ស៖** ពេលដែលលោកស្រីចេញទៅបាត់ដំបងនៅខាងសីហា គឺលោកស្រីបានទៅដល់កំពង់សៀមគឺនៅដើមឆ្នាំ១៩៧៧ ហើយបន្ទាប់មកនៅទីនោះរហូតទៅដល់ខែសីហា ឆ្នាំ១៩៧៨។ ដូច្នេះ តើត្រឹមត្រូវដែរឬទេ គឺលោកស្រីទៅនៅកំពង់សៀមមិនមែនតែពីរបីខែទេ ប្រហែលជាអាចជាងមួយឆ្នាំងណោះ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** អត់ត្រឹមត្រូវ។

[១៣:៥៥:១០]

**ស៖** ចាតើមន្ទីរស្រុកនុំងនៅទីណាដែរ?

**ឆ៖** មន្ទីរស្រុកកំពង់សៀម? នៅចន្លោះនៅខាងលិចភ្នំប្រុស ខាងលិចភ្នំប្រុសនៅជិតវត្តអង្គញដី។

**ស៖** ចាតើនៅឆ្ងាយពីភ្នំប្រុសនោះប៉ុន្មានដែរ? ប៉ុន្មានគីឡូតម៉ែត្រដែរ?

**ឆ៖** ខ្ញុំប៉ាន់គីឡូអត់ត្រូវ។ ដឹងប៉ុន្មានគីឡូ មិនដឹងថាប៉ុន្មានគីឡូទេ ខ្ញុំមិនដឹង អត់ដឹងថាពីហ្នឹងទៅស្រុកមកប៉ុន្មានគីឡូខ្ញុំអត់ប៉ាន់អត់ត្រូវដែរ។

[១៣:៥៦:២៥]

**ស៖** នៅពេលដែលគេសួរកាលពីម្សិលមិញ លោកស្រីបានលើកឡើងថា នៅស្រុកកំពង់សៀមមិនមានមន្ទីរសន្តិសុខនោះទេ។ ក៏ប៉ុន្តែនៅពេលដែលអ្នកស៊ើបអង្កេតបានសួរលោកស្រីដំបូងបំផុត នៅ

តាមឯកសារ D234/4 ត្រង់លេខអង់គ្លេស 00366083 ខ្មែរ 00357513 ហើយបារាំងគឺ 00403127។ លោកស្រីបានឆ្លើយថា គេសួរថាតើមានមន្ទីរសន្តិសុខនៅស្រុកកំពង់សៀមដែរឬទេ? លោកស្រីឆ្លើយថា នៅពេលនោះស្រុកកំពង់សៀម គឺមានមន្ទីរសន្តិសុខមួយ ក៏ប៉ុន្តែគេមិនឲ្យខ្ញុំបញ្ជូនមនុស្សទៅមន្ទីរនោះទេ។ ដូច្នេះខ្ញុំចង់សូមសួរលោកស្រីថា លោកស្រីបានឆ្លើយប្រាប់អ្នកស៊ើបអង្កេតលើកដំបូង តើវាត្រឹមត្រូវដែរឬទេ? តាមពិតទៅនៅស្រុកកំពង់សៀម គឺមានមន្ទីរសន្តិសុខមួយ តើពិតជាត្រឹមត្រូវដែរឬទេ?

[១៣:៥៧:៤០]

**ប្រធានអង្គជំនុំ៖**

សូមៗអញ្ជើញមេធាវីការពារក្ដី នួន ជា!

**លោក ម៉ៃខល ផេសមិន៖**

គឺជាចំណុចមួយចាប់អារម្មណ៍សម្រាប់សហព្រះរាជអាជ្ញា។ ក៏ប៉ុន្តែខ្ញុំមិនដឹងថា សំណួរហ្នឹងវាចូលទៅក្នុងវិសាលភាពដំណាក់កាលដំបូងយ៉ាងម៉េចទេ ទៅនឹងសវនាការនេះ? មន្ទីរសន្តិសុខមាន ឬក៏មិនមាននោះ គឺមិនដឹងថា វាពាក់ព័ន្ធយ៉ាងម៉េចទៅនឹងដំណាក់កាលដំបូងនៃសវនាការ។ ដូច្នេះ ខ្ញុំសូមធ្វើការជំទាស់ទៅនឹងសំណួរដែលបានចោទសួរ។ សូមអរគុណ។

[១៣:៥៨:២១]

**លោក ឌេល លីសាក់៖**

លោកប្រធាន បើអាចឲ្យខ្ញុំឆ្លើយតប។ នេះគឺជាសំណួរទូទៅមួយពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធនៅក្នុងស្រុក។ ថាតើនៅក្នុងស្រុកនោះមានមន្ទីរសន្តិសុខដែរឬទេ? ហើយមន្ទីរនុំងគេចែកចាយម្ហូបអាហារយ៉ាងម៉េច? ហើយគេមានថ្នាំសង្កូវដែរឬទេ? ខ្ញុំមិនសួរលម្អិតទៅលើមន្ទីរសន្តិសុខនោះទេ ក៏ប៉ុន្តែវាសំខាន់ដែលយើងក្នុងនាមជាសហព្រះរាជអាជ្ញា មានបន្ទុកក្នុងការបង្ហាញភស្តុតាង ជាពិសេសបង្ហាញអំពីរចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងរចនាសម្ព័ន្ធភូមិភាគ ស្រុក និងតំបន់។

ដូច្នេះហើយ ទើបយើងត្រូវការសួរព័ត៌មានបន្ថែមទៅលើចំណុចនេះ។ យើងខ្ញុំមិនសួរលម្អិតទៅលើមន្ទីរសន្តិសុខនោះទេ ថាអ្នកណាគេជាអ្នកបង្កើត? ហើយគ្រប់គ្រងដោយអ្នកណា...។ល។ ខ្ញុំអត់មានសួរអ៊ីចឹងទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ជំទាស់របស់មេធាវីការពារក្តី នួន ជា គ្មានប្រសិទ្ធភាព។ អង្គជំនុំជម្រះត្រូវការស្តាប់នូវចម្លើយសាក្សីតបទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា ដែលបានសួរសំណួរចុងក្រោយអម្បាញ់មិញនេះ។ សាក្សីបើនៅចងចាំនូវសំណួរអាចឆ្លើយតបបាន ប្រសិនបើមិនចងចាំទេ អាចស្នើសុំដើម្បីតំណាងសហព្រះរាជអាជ្ញាអន្តរជាតិតាំងសំណួរសាជាថ្មីម្តងទៀត។

[១៤:00:00]

**លោកស្រី ប្រាក់ យុត៖**

ខ្ញុំអត់--

**ប្រធានអង្គជំនុំ៖**

ប្រាក់ យុត ស្តាប់បានទេ? ឬចាំសំណួរទេ? ឥឡូវចាំស្តាប់ ឥឡូវសហព្រះរាជអាជ្ញាអន្តរជាតិសូមតាំងសំណួរចុងក្រោយអម្បាញ់មិញនេះ ដែលមានការជំទាស់នេះសាជាថ្មីម្តងទៀត ដើម្បីឲ្យគាត់ស្តាប់នឹងសំណួរឲ្យបានច្បាស់ ដើម្បីគាត់អាចឆ្លើយតបបាន។

**សួរដោយ លោក ឌេល លីសាក់៖**

**ស៖** សំណួរនោះគឺថា នៅពេលដែលឆ្លើយជូនអ្នកស៊ើបអង្កេតរបស់តុលាការនោះថា តើមានមន្ទីរសន្តិសុខ។ លោកស្រីបានឆ្លើយថា មានមន្ទីរសន្តិសុខនៅក្នុងស្រុកកំពង់សៀម ថាតើពិតជាត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំសូមឆ្លើយ មានមន្ទីរសន្តិសុខនៅក្នុងស្រុកកំពង់សៀម តែខ្ញុំសូមថារឿងពិតតែម្តង។

**ស៖** តើមន្ទីរសន្តិសុខនៅកន្លែងណាដែរក្នុងស្រុកនុ៎ង?

[១៤:០១:១៣]

**ឆ៖** កាលហ្នឹងដាក់នៅជាប់កន្លែងមន្ទីរស្រុក ចន្លោះភ្នំប្រុសហ្នឹង ហើយជាប់គ្នា។

**ស៖** មន្ទីរសន្តិសុខដែលនៅជាប់ភ្នំប្រុស វាជាមន្ទីរសន្តិសុខរបស់ស្រុក ក្រោមការគ្រប់គ្រងរបស់លោកស្រី ឬក៏ជាមន្ទីរសន្តិសុខដែលស្ថិតនៅក្នុងការគ្រប់គ្រងរបស់អ្នកផ្សេង អ្នកដែលនៅក្នុងតំបន់ អ្នកដែលនៅក្នុងភូមិភាគ?

**ឆ៖** មិនមែនរបស់ភាគ របស់តំបន់ទេ គឺដូចថាមន្ទីរអប់រំនៅក្នុងស្រុកកំពង់សៀម ដូចខ្ញុំហ្នឹងមានមន្ទីរអប់រំមួយ ដូចជាមនុស្សខិលខូច មនុស្សអីនៅក្នុងស្រុកហ្នឹង ខ្ញុំយកមកអប់រំនៅកន្លែងហ្នឹង។

អត់មាននៅក្នុងភូមិភាគ នៅក្នុងតំបន់ទេ។ នៅកន្លែងជាសាលា-- នៅជិតកន្លែងមន្ទីរស្រុកខ្ញុំហ្នឹង គឺខ្ញុំអប់រំខ្លួនឯង។ ការខុស ការត្រូវអី ខ្ញុំយកមកអប់រំកន្លែងហ្នឹង។

**ស៖** គឺខ្ញុំសូមសួរបន្តទៅមុខទៀត ដោយសារតែចំណុចនេះ យើងមិនអាចសួរលម្អិតស៊ីជ្រៅជាងនេះទៀតទេ។ សំណួររបស់ខ្ញុំសួរមួយនេះទៀត ពាក់ព័ន្ធទៅនឹងការរាយការណ៍នៅក្នុងស្រុកកំពង់សៀម តើលោកស្រីមានរៀបចំរបាយការណ៍ជាលាយលក្ខណ៍អក្សរនៅក្នុងពេលដែលលោកស្រីជាលេខាស្រុកកំពង់សៀមដែរឬទេ?

[១៤:០៣:១៥]

**ឆ៖** ខ្ញុំជាលេខាស្រុកកំពង់សៀម គឺខ្ញុំបានរាយការណ៍ឲ្យតំបន់ជាលាយលក្ខណ៍អក្សរ មួយខែម្ដង។ រាយការណ៍អនុវត្តការងារនៅក្នុងស្រុក នេះខ្ញុំបានរាយការណ៍ជាបន្តជាប់។ សភាពការណ៍អីកើតឡើងគឺខ្ញុំរាយការណ៍ឲ្យតំបន់។

**ស៖** វាជាការរាយការណ៍ជាលាយលក្ខណ៍អក្សរនោះ គឺគេផ្ញើទៅយ៉ាងម៉េច? តាមរយៈតេឡេក្រាម សារទូរលេខ ឬក៏នីរសារ?

**ឆ៖** តាមរយៈនីរសារ ដូចថានៅជាមួយខ្ញុំក្មេងៗអីប្រើគាត់យកឲ្យ មិនតាមទូរលេខ មិនតាមអីទេ។

**ស៖** ថាតើលេខាតំបន់ហ្នឹងនៅកន្លែងណាដែរ នៅពេលដែលលោកស្រីឲ្យគេយកសំបុត្ររាយការណ៍ទៅគាត់ហ្នឹង?

**ឆ៖** កាលនុ៎ងដឹងនៅកន្លែងណា ខ្ញុំមិនបានចាំដែរ។ ព្រោះខ្ញុំទៅនៅថ្មី វាមិនបានសាកសួរអាកន្លែងគេនៅ។ តំបន់ហ្នឹងដូចជានៅកន្លែងស្រុកណាទេ ខ្ញុំមិនបានចាំដែរលោក។ មិននៅទីកន្លែងទេ ខ្ញុំមិនស្គាល់ទីកន្លែងរស់នៅហ្នឹងទៀត មិនបានសួរ។

[១៤:០៥:០០]

**ស៖** លោកស្រីបានឆ្លើយកាលពីម្សិលមិញ ថាលោកស្រីបានចូលរួមនៅក្នុងការប្រជុំជាមួយនឹងលេខាភូមិភាគ កែ ពក។ តើមាននរណាគេទៀតដែលចូលរួមប្រជុំជាមួយនឹង កែ ពក នៅពេលដែលលោកស្រីចូលរួមប្រជុំដែរនោះ?

**ឆ៖** មានគណៈតំបន់ចូលរួម។ ព្រោះនៅតំបន់មួយៗ គាត់ហៅមកប្រជុំនៅកន្លែងហ្នឹង ដូចជាតំបន់៤១ តំបន់៤២ តែនៅហ្នឹងគាត់ប្រជុំ លោក កែ ពក គាត់ប្រធាន គាត់គណៈភូមិភាគ។ គាត់ប្រជុំ

ហ្នឹង គឺថាមានឈ្មោះ ខ្ញុំមិនស្គាល់អស់ដែរ មិនដឹងឈ្មោះអីខ្លះ។ វាភ្លេចអស់ខ្លះហើយ ឈ្មោះគាត់មកប្រជុំនៅគណៈភូមិភាគនេះ។

**ស៖** តើការប្រជុំនោះ គេធ្វើនៅកន្លែងណាដែរ?

**ផ៖** នៅកន្លែងក្រុងកំពង់ចាម។

[១៤:០៦:០៧]

**ស៖** តើការប្រជុំហ្នឹង គេធ្វើនៅមន្ទីរភូមិភាគ ឬក៏មិនមែនទេ?

**ផ៖** មន្ទីរភូមិភាគ។

**ស៖** ជាទូទៅ តើគេពិភាក្សាអំពីបញ្ហាអ្វីដែរនៅពេលប្រជុំនៅមន្ទីរភូមិភាគនោះ?

**ផ៖** ភាគច្រើន គឺពិភាក្សាអំពីការងារដែលប្រជាជនត្រូវធ្វើជាប់ ដូចថាធ្វើអីលើកទំនប់ ជីកប្រឡាយអីអីចឹងទៅ យើងហៅគ្នាពិភាក្សាបញ្ហាហ្នឹង។ ពិភាក្សាអំពីប្រជាជនយើងរស់នៅ មានការស្រួល ការលំបាកអីខ្លះ យើងលើកមកប្រជុំមកដើម្បីដោះស្រាយបញ្ហា ភូមិភាគគាត់អ្នកដោះស្រាយបញ្ហា។ យើងនៅរាយការណ៍ឲ្យគាត់ទៅ គាត់អ្នកដោះស្រាយ បញ្ហាគ្រប់មុខ។

**ស៖** តើមានការពិភាក្សាណាមួយពាក់ព័ន្ធទៅនឹងគោលនយោបាយ ឬក៏ការណែនាំដែលបានទទួលពីថ្នាក់ដឹកនាំនៅភ្នំពេញដែរឬទេ?

**ផ៖** ខ្ញុំមិនបានដឹងដែរ ព្រោះគាត់ភូមិភាគ គាត់អ្នកប្រជុំ មិនដឹងជាមានការទាក់ទងរវាងភ្នំពេញនិងគាត់។ ព្រោះគាត់ៗយកផែនការមកផ្សព្វផ្សាយឲ្យខាងខ្ញុំ ហើយខាងលើមិនដឹងគាត់ពិភាក្សាគ្នាម៉េចក៏ខ្ញុំអត់ដឹងដែរ។ គាត់មិនដឹងយកផែនការ គាត់ទៅពិភាក្សាជាមួយខាងលើយ៉ាងម៉េច។ អត់ដឹងដែរ ខ្ញុំដឹងថាតែគាត់ផ្សព្វផ្សាយ គឺខ្ញុំដឹងថាខាងក្រោម។

[១៤:០៨:០៥]

**ស៖** ថាតើមានការប្រកាសយ៉ាងម៉េចដែលនៅថ្នាក់មូលដ្ឋាន គេមានការប្រកាសប្រាប់យ៉ាងម៉េចដែរ? លោកស្រីប្រាប់ថា លោកស្រីបានរៀន មានការប្រកាសអំពីគោលនយោបាយនៅថ្នាក់មូលដ្ឋាន តើគេប្រកាសប្រាប់ដោយរបៀបម៉េចដែរ?

**ផ៖** គាត់គ្រាន់ណែនាំឲ្យយើង ណែនាំប្រជាជនឲ្យធ្វើទំនប់ ធ្វើប្រឡាយអីហ្នឹង គាត់អត់មានណែនាំអំពីអីផង ហើយឲ្យប្រជាជនយើងខំធ្វើប្រឡាយ ធ្វើទំនប់ ឲ្យប្រជាជនហ្នឹងចេះធ្វើតាមគម្រោងផែនការរបស់ដែលយើងដាក់។ គាត់បាននិយាយតែប៉ុណ្ណឹង គាត់មិននិយាយអីច្រើន។

**ស៖** ពាក្យដែលលោកស្រីថា “គាត់ហ្នឹង” តើគាត់ហ្នឹង ប្រុសហ្នឹង គាត់ហ្នឹងជាអ្នកណាដែរ?

**ឆ៖** គឺតា ពក ហ្នឹងគាត់អ្នកប្រជុំ។

**ស៖** តើត្រឹមត្រូវដែរឬទេ ដែលក្នុងពេលនោះលោកស្រីកំពុងតែនិយាយសំដៅទៅលេខាភូមិភាគ គឺ កែ ពក មែនទេ?

**ឆ៖** ចាស! ត្រឹមត្រូវ។

[១៤:០៩:៤៧]

**ស៖** ខ្ញុំត្រឡប់ចូលទៅនិយាយពីប្រធានបទផ្សេង។ សួរលោកស្រីទាក់ទងទៅនឹងសភាតំណាងប្រជាជនបដិវត្តន៍កម្ពុជានៅក្នុងឆ្នាំ១៩៧៦ លោកមានបានដឹងអំពីការកកើតនូវសភាតំណាងប្រជាជនដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាប ខ្ញុំនិយាយរួមសម័យនោះ ខ្ញុំក៏មិនដឹងថា តំណាងរាស្ត្រហ្នឹងជាតំណាងស្អីទេ ខ្ញុំមិនសូវដឹងដែរ។ តែក្នុងហ្នឹងគេបានប្រកាសដូចថា ឮតាម តាណយ តាអីគាត់ថា អ្អែងជិតបានធ្វើតំណាងរាស្ត្រប្រជាជនហើយ។ ខ្ញុំមិនស្គាល់ពាក្យតំណាងរាស្ត្រទៀតសម័យនោះ មិនមែនថាខ្ញុំ មិនដឹងតែម្តងថា តំណាងរាស្ត្រគឺស្អីទៀត តែក្នុងហ្នឹងគឺមានដល់យូរទៅ តាណយ គាត់និយាយអ៊ីចឹង ខ្ញុំឡើងទៅតំបន់ឮ តាចាប ថាយើងធ្វើតំណាងរាស្ត្រឲ្យប្រជាជន។ គ្រាន់ថាឮពាក្យតំណាងរាស្ត្រ ខ្ញុំក៏មិនបានឈរឈ្មោះអីត្រឹមត្រូវបានទៅប្រជុំអីត្រឹមត្រូវអត់ទេ។ គ្រាន់ថា តំណាងរាស្ត្រហ្នឹងខ្ញុំ មិនដឹងថាធ្វើអីទៀត។ វាអត់យល់បញ្ហា និយាយរួមគឺមិនដឹងធ្វើអីគេ។ នេះខ្ញុំបានធ្វើដែរ តែគ្រាន់ថាមានខ្លួនខ្ញុំហ្នឹងធ្វើ តែបានទៅប្រជុំទៅអីគឺអត់ទេ។ វាអត់ដឹង។ អត់ដឹងថា ប្រជុំហ្នឹងយ៉ាងម៉េច ធ្វើហ្នឹងយ៉ាងម៉េច គឺអត់ច្បាស់លាស់ ហើយគ្រាន់តែឮថា ពាក្យតំណាងរាស្ត្រក៏ខ្ញុំមិនច្បាស់លាស់ដែរ ខ្លួនឯងហ្នឹង។

[១៤:១១:៣២]

ខ្ញុំបានឈរឈ្មោះដែរ បញ្ហាពេលហ្នឹង មិនមែនអត់ទេ តែគ្រាន់ថា គ្រាន់តែឈរឈ្មោះ តែមិនដឹងថាខ្លួនហ្នឹងមានភារកិច្ចអីទេ ធ្វើអីទេ។ ហើយខាងតំបន់គ្រាន់និយាយប្រាប់ខ្ញុំដែរ គាត់មិនដែល គាត់មិនច្បាស់លាស់ដែរ ខាងស្រុកគ្រាន់និយាយថាៗ ធ្វើតំណាងរាស្ត្រតែប៉ុណ្ណឹង។ ខ្ញុំក៏មិនច្បាស់ខ្លួនឯង ខាងស្រុកក៏គាត់មិនច្បាស់។ ហើយសម័យនោះ ក៏យើងមិនទាន់យល់បញ្ហាអីទៀត។ នេះ ខ្ញុំសូមជម្រាបដោយការពិត។

**ស៖** ខ្ញុំសូមសួរសំណួរជាក់លាក់មួយចំនួនទៅលោកស្រី តាមលោកស្រីដឹង តើមានការបោះ

ឆ្នោតដោយប្រជាជននាំគ្នាទៅបោះឆ្នោត ហើយបោះឆ្នោតឲ្យលោកស្រីក្លាយទៅជាតំណាងសភាប្រជាជនដែរឬទេ?

**ឆ៖** ខ្ញុំអត់ដឹងបញ្ហាបោះឆ្នោត។

**ស៖** តើលោកស្រីដែលកត់សម្គាល់ឃើញមានប្រជាជនទៅបោះឆ្នោតនៅក្នុងខែមីនា ឆ្នាំ១៩៧៦ ឬក៏ក្នុងខែណាមួយក្នុងឆ្នាំ១៩៧៦ ដែរឬទេ?

**ឆ៖** ខ្ញុំអត់ដឹង។

[១៤:១៣:១៤]

**ស៖** នៅក្នុងថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦ លោកស្រីខ្លួនឯង ឬតើមានបានបោះឆ្នោតក្នុងជ្រើសរើសសភាតំណាងប្រជាជននេះដែរឬទេ?

**ឆ៖** អត់មាន។ ខ្ញុំអត់មានបោះឆ្នោត។

**ស៖** បើតាមចម្លើយរបស់លោកស្រីដែលខ្ញុំបានលើកឡើងប៉ុន្មាននាទីមុននេះ ខ្ញុំសូមសួរលោកស្រីតាមមធ្យោបាយនេះ ឥឡូវសូមលោកស្រីជម្រាបមកខ្ញុំវិញថា តើនៅពេលណាដែលលោកស្រីដឹងខ្លួនថាលោកស្រីត្រូវបានគេជ្រើសរើសឲ្យធ្វើជាសភាតំណាងប្រជាជននោះ? នៅពេលដែលគេជ្រើសរើសឈ្មោះលោកស្រីឲ្យធ្វើជាសភាតំណាងប្រជាជនដឹងទេ ថានៅពេលណាដែរ?

[១៤:១៤:០២]

**ឆ៖** អត់ចាំ មិនដឹងពេលណាអង្កាល់ហ្នឹង។ មិនដឹងឆ្នាំប៉ុន្មាន ខ្ញុំអត់ចាំផង។

**ស៖** ខ្ញុំសួរថា តើលោកស្រីត្រូវបានគេជ្រើសរើសឲ្យធ្វើតំណាងសភាប្រជាជនដោយរបៀបណា? តាមរយៈលេខាស្រុក លេខាតំបន់ កង ចាប នោះ គឺថាត្រូវបានចាត់តាំងលោកស្រីឲ្យធ្វើជាសភាតំណាងប្រជាជន នេះគឺជាលើកទីមួយដែលគេបានជ្រើសរើសលោកស្រីឲ្យធ្វើជាតំណាងសភាតំណាងប្រជាជនដែលលោកស្រីបានទទួលព័ត៌មាននេះ តាមរយៈលេខាស្រុក តាណយ និងលេខាតំបន់ កង ចាប ហ្នឹង នេះជាលើកទីមួយឬ?

[១៤:១៥:០០]

**ឆ៖** គាត់បានប្រាប់ខ្ញុំលើកទីមួយគឺ តែមិនបានប្រជុំបានអីត្រឹមត្រូវនៅក្នុងតំបន់ទេ គ្រាន់តែថាឲ្យយើងដឹងថា យើងជាប់ជាតំណាងប្រជាជននេះ-- អ៎ ជាប់ជាតំណាងប្រជាជនទេ តែឲ្យខ្ញុំបានគាត់ណែនាំអីច្បាស់លាស់ គឺអត់ទេ។

**ស៖** បញ្ហាប្រជុំ គឺជាសំណួររបស់ខ្ញុំបន្ទាប់ទៅទៀតនោះទេ។ ខ្ញុំសូមសួររបៀបនេះ តើលោកស្រីធ្លាប់បានគេអញ្ជើញឲ្យមកចូលរួមប្រជុំ នៅក្នុងកិច្ចប្រជុំរបស់សភាតំណាងប្រជាជនដែរឬទេ?

**ឆ៖** អត់ ខ្ញុំអត់បានមកផង។

**ស៖** តើគេមានបានជូនដំណឹងទៅលោកស្រី ដែលថាត្រូវដាក់ពិភាក្សា និងត្រូវអនុម័តនៅក្នុងកិច្ចប្រជុំសភាតំណាងប្រជាជនដែរឬទេ?

**ឆ៖** អត់។

**ស៖** ខ្ញុំដឹងថា លោកស្រីមិនដែលបានបោះឆ្នោតម្តងណាទេ នៅក្នុងកិច្ចប្រជុំសភាតំណាងប្រជាជននេះ មែនទេ?

**ឆ៖** ចាស! ខ្ញុំអត់ដែលបានបោះឆ្នោតប្រជុំ។

**ស៖** តើប្តីរបស់លោកស្រី ត្រូវបានគេជ្រើសរើសឲ្យធ្វើជាសភាតំណាងប្រជាជនដែរឬទេ?

**ឆ៖** ប្តីខ្ញុំបានធ្វើដែរតើ។

**ស៖** លោកស្រីអាចជម្រាបឈ្មោះប្តីលោកស្រី ជូនអង្គជំនុំជម្រះឲ្យបានជ្រាបផងបានទេ?

**ឆ៖** ខ្ញុំសូមជម្រាប ប្តីខ្ញុំគឺឈ្មោះ អាំ។

[១៤:១៧:០៩]

**ស៖** ឈ្មោះ អាំ នេះជាឈ្មោះ ហៅក្រៅរបស់គាត់ ឬក៏យ៉ាងណាដែរ?

**ឆ៖** ឈ្មោះហ្នឹង គឺហៅគាត់មកតាំងពីជួបគ្នាមក ហៅគាត់ឈ្មោះ អាំៗ អ៊ីចឹងតែម្តង។

**ស៖** តើឈ្មោះពេញរបស់គាត់ឈ្មោះ សំ ដាំ ឬក៏ មិនមែនទេ?

**ឆ៖** ឈ្មោះដើមរបស់គាត់ឈ្មោះ សំ ដាំ។ ឈ្មោះក្រោយក្នុងនេះ ឈ្មោះនៅក្រៅគឺឈ្មោះ អាំ។

**ស៖** តើប្តីរបស់លោកស្រី អញ្ជើញមកពីម្តុំខេត្តណាដែរ នៃប្រទេសកម្ពុជាយើងហ្នឹង?

**ឆ៖** គាត់នៅព្រៃវែង។ ខេត្តព្រៃវែង។

**ស៖** តើលោកស្រីដឹងថា ប្តីលោកស្រីហ្នឹងគាត់បានដឹងថា ខ្លួនគាត់ហ្នឹងត្រូវបានគេជ្រើសរើសឲ្យធ្វើជាតំណាងសភាប្រជាជនហ្នឹងពីពេលណាដែរ?

**ឆ៖** ខ្ញុំដឹងដែរ គេប្រាប់គាត់ដែរ ដឹងស្រករគ្នាហ្នឹង។ គាត់ដឹង ខ្ញុំក៏ដឹងគេជ្រើសរើសទាំងអស់គ្នា។

[១៤:១៨:៥៦]

**ស៖** ជនជាប់ចោទ នួន ជា នៅក្នុងរឿងនេះ គាត់បានអះអាងថា គាត់បានធ្វើការអំពីបញ្ហា

កិច្ចការនៅក្នុងរដ្ឋសភានៅក្នុងកម្ពុជាប្រជាធិបតេយ្យ ក្នុងឋានៈជាប្រធាននៅពេលដែលគាត់ជាប្រធាននៃសភាតំណាងប្រជាជននេះ។ តើលោកស្រីធ្លាប់បានធ្វើការជាមួយ នួន ជា ទៅលើកិច្ចការណាមួយទេចន្លោះពីថ្ងៃទី១៧ មេសា ៧៥ ដល់ ៦ មករា ៧៩ នោះ?

**ឆ៖** ខ្ញុំអត់មានទេ។

**ស៖** លោកស្រីធ្លាប់ដែលមានវត្តមានក្នុងពេលណាដែលលោក នួន ជា គាត់ថ្លែងសុន្ទរកថា ក្នុងនាមឲ្យសភាតំណាងប្រជាជនដែរឬទេ?

**ឆ៖** អត់។

[១៤:២០:០០]

**ស៖** នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង លោកស្រីធ្លាប់ដែលបានជួប នួន ជា ដែរឬទេ?

**ឆ៖** ខ្ញុំមិនដែលបានជួបផង។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំចង់សុំស្នើបង្ហាញនូវឯកសារមួយ ដើម្បីបង្ហាញជូនឯកសារនេះ គឺឯកសារ IS15.13។ ដើម្បីជាការកត់ត្រាឲ្យបានត្រឹមត្រូវគឺឯកសារនេះនិយាយអំពីថា "សភាតំណាងប្រជាជននៅកម្ពុជា ពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំមួយពាន់ប្រាំបួនរយ-- ។

**ប្រធានអង្គជំនុំ៖**

សូមបញ្ជាក់ម្តង អត្តសញ្ញាណឯកសារឲ្យច្បាស់លាស់ មិនមែននិយាយបកប្រែមួយពាន់ប្រាំបួនអីចឹង ហើយស្តាប់ម៉េចទៅ ហើយប្រតិចារឹកយ៉ាងម៉េចទៅ។ សូមបញ្ជាក់ម្តងទៀត ឲ្យបានយឺតៗ នូវចំណងជើងឯកសារ លេខឯកសារ ដែលលោកមានការប៉ុនប៉ងក្នុងការស្នើសុំ ដាក់បង្ហាញនៅលើកញ្ចក់អេក្រង់ទូរទស្សន៍ និងចំពោះមុខសាក្សីនាពេលនេះ។

[១៤:២២:០៤]

**លោក ឌេល លីសាក់៖**

ខ្ញុំចង់សូមបង្ហាញឯកសារនេះ គឺឯកសារ IS13.13។ ឯកសារនេះ មានចំណងជើងថា សុំដកស្រង់សម្តី៖ "ឯកសារ ស្តីអំពីកិច្ចប្រជុំរបស់សភាតំណាងប្រជាជនកម្ពុជា ចាប់ពីថ្ងៃទី១១ ទៅដល់ថ្ងៃទី១៣ ខែមេសា ១៩៧៦"។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ! ហើយមន្ត្រីតុលាការយកឯកសារ ពីសហព្រះរាជអាជ្ញាទៅជូនសាក្សីពិនិត្យ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំមិនស្នើសុំឱ្យលោកស្រីអានទេ ប៉ុន្តែមានរូបថតនៅក្នុងនេះដែរ។ សំណួររបស់ខ្ញុំដំបូង គឺ ថាតើលោកស្រីបានចូលរួមនៅក្នុងអង្គប្រជុំសន្និបាតសភាតំណាងប្រជាជនកម្ពុជា ចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៦ ដែរឬទេ?

**ឆ៖** ការចូលរួមប្រជុំសភានៅថ្ងៃទីប៉ុន្មានទេ ខ្ញុំក៏មិនបានចាំអស់ដែរ ហើយមិន-- បានប្រជុំ ឬក៏មិនបានប្រជុំ ខ្ញុំវាភ្លេច។ ខ្ញុំនិយាយដោយស្មោះត្រង់ហើយនេះ ដូចឆ្ងាយ វាវែងឆ្ងាយមកហើយ ខ្ញុំមិនបានចាំអស់ ហើយឯកសារនេះ ខ្ញុំឃើញសួរសាចុះសាឡើងដែរ ហើយការប្រជុំពីថ្ងៃប៉ុន្មានៗ ខ្ញុំក៏វាភ្លេច ឥឡូវបានយកឯកសារមកឱ្យខ្ញុំមើលជាលើកទីមួយ។ សន្និបាតលើកទីមួយ អ៊ីចឹង ខ្ញុំវាភ្លេចភ្លាំងអស់ដែរ ចាំមិនអស់ ការប្រជុំនៅកន្លែងសភាហ្នឹង។ នេះ ខ្ញុំសូមឆ្លើយប៉ុណ្ណឹង ដូចថា បើសួរហ្នឹងខ្ញុំចេះតែឆ្លើយ។

[១៤:២៤:៤៦]

**ស៖** ខ្ញុំសូមឱ្យលោកស្រីពិនិត្យមើលទំព័រ៤ នៃឯកសារជាភាសាខ្មែរ ERN ជាភាសាខ្មែរ 0005 3607។ ហើយលោកប្រធាន ក៏សូមស្នើឱ្យបង្ហាញរូបថតនៅលើអេក្រង់ផងដែរ។ ប៉ុន្តែអត់ឃើញមានទេ។ រូបថត គឺនៅបន្ទាប់ពីទំព័រទី៤ ជារូបថតរបស់តំណាងសភាតំណាងប្រជាជនកម្ពុជានៅខាងមុខអគារនៃសភាតំណាងប្រជាជនកម្ពុជា ពីនៅព្រឹកថ្ងៃទី១១ មេសា ៧៦។ ខ្ញុំសូមឱ្យលោកស្រីពិនិត្យមើលថាតើលោកស្រីអាចចងចាំបានថា លោកស្រីធ្លាប់មានវត្តមាននៅក្នុងអង្គប្រជុំរដ្ឋសភានេះដែរឬទេ?

**ឆ៖** ឥឡូវខ្ញុំសូមមានមតិ។ បើសិនជាលោកថាមានវត្តមាន មិនមានវត្តមាននៅក្នុងអង្គប្រជុំសភានេះ ខ្ញុំក៏លើកឱ្យអង្គប្រជុំ ឱ្យលោកប្រធានយល់ថា បើសិនជាការលើកមកអ៊ីចឹង ខ្ញុំក៏មិនអាចប្រកែកបានដែរ។ បើអ៊ីចឹងចូលមកអង្គប្រជុំហ្នឹង ប៉ុន្តែមិនដឹងថ្ងៃខែទេ។ ប៉ុន្តែចូលប្រជុំ បើលោកថា មិនមាននៅទីនេះ ប៉ុន្តែខ្ញុំកាលនុ៎ងខ្ញុំវាភ្លេចដែរ មិនដឹងជាបានចូល មិនបានចូល ខ្ញុំក៏វាមិនបានដូចថា អត់បានកត់ត្រាទុក។ អ៊ីចឹងខ្ញុំមិនមែនចេះតែនិយាយទៅមិនដឹងអីទេ។ តែបើមានឯកសារអីទៅ ខ្ញុំចេះតែចងចាំទៅ។ កាលនោះខ្ញុំនិយាយក្នុងការស៊ើបអង្កេតអ៊ីចឹងដែរ ថាកាលនោះខ្ញុំវាមិនបានចូលប្រជុំចូលអី គ្រាន់តែឮៗ ទេខ្ញុំមិនគិតទេ។ នេះខ្ញុំសូមជម្រាប។ ហើយក្នុងនេះក៏ខ្ញុំមិនបានចូលមករួមដែរ។ នេះសូមជម្រាប

ប៉ុណ្ណឹង។

**ស៖** ខ្ញុំមិនស្នើសុំសួរលោកចូលមិនចូលអីទេ គ្រាន់តែចង់ឲ្យលោកស្រីរំឭកមើល ថាតើលោកធ្លាប់មានវត្តមាននៅក្នុងអង្គប្រជុំរបស់សភាតំណាងប្រជាជននេះដែរឬទេ? ឥឡូវខ្ញុំសូមសួរលោកស្រីផ្សេងទៅវិញ អគារដែលលោកស្រីបានឃើញក្នុងរូបថតនេះ គឺជាអគារដ៏ល្បីឈ្មោះមួយនៅក្នុងទីក្រុងភ្នំពេញ ហៅថា "សាលចតុមុខ"។ លោកស្រីធ្លាប់បាននឹកឃើញថា ធ្លាប់មានចូលរួមប្រជុំនៅក្នុងអគារនេះ ក្នុងអំឡុងនៃកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

[១៤:២៨:០១]

**ឆ៖** ខ្ញុំដូចជាមិនបានចូលរួមទេ។ ខ្ញុំសូមឆ្លើយខ្លីប៉ុណ្ណឹង ព្រោះកាលនោះខ្ញុំក៏វា--

**ស៖** ចំណុចចុងក្រោយមួយ គឺខ្ញុំសូមសួរលោកស្រី ដើម្បីឲ្យលោកស្រីអាចនឹកឃើញឡើងវិញតាមដែលអាចខ្ញុំធ្វើទៅបាន។ ទាក់ទងទៅនឹងការចូលរួមរបស់លោកស្រីនេះ នៅទំព័រទី៣៥ ដល់៣៦នៃឯកសារជាភាសាខ្មែរ ERN 0053628 រហូតដល់ 53629 ERNជាភាសាអង់គ្លេស 00184063 ដល់ 184064 ជាភាសាបារាំង ERN 00301350។ នៅលើទំព័រទាំងនេះ លោកស្រីនឹងឃើញបញ្ជីស្ដីអំពីរបៀបវារៈទីប្រាំបួននៃកិច្ចប្រជុំរបស់សភាតំណាងប្រជាជនកម្ពុជានេះ។

ដូចដែលលោកស្រីបានបញ្ជាក់ហើយ គឺថាលោកស្រីមិនអាចអានបានទេ។ ឥឡូវខ្ញុំសូមអានជូនលោកស្រី និយាយអំពីរបៀបវារៈនៃកិច្ចប្រជុំនេះ ក្រែងលោលោកស្រីអាចនឹងនឹកឃើញឡើងវិញ។

[១៤:៣០:០០]

"ទីមួយ ពិនិត្យអំពីលទ្ធផលនៃការបោះឆ្នោតជាសកលនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦។ ទីពីររៀបចំរបៀបរបបធ្វើការងាររបស់សភាតំណាងរបស់ប្រជាជនកម្ពុជា រៀបចំចាត់តាំងគណៈកម្មាធិការអចិន្ត្រៃយ៍របស់សភា។ ហើយរបៀបវារទីបី ដូចខាងក្រោម៖ ពិនិត្យពិច័យ និងសម្រេចលើសេចក្ដី--ពិនិត្យពិច័យ និងសម្រេចនូវសេចក្ដីសុំចូលនិវត្តន៍របស់សម្ដេចនរោត្ដម សីហនុ តាមសេចក្ដីថ្លែងការណ៍របស់សម្ដេចផ្ទាល់ ចុះថ្ងៃទី០២ មេសា ១៩៧៦ និងសេចក្ដីថ្លែងការណ៍របស់រដ្ឋាភិបាលចុះថ្ងៃទី០៤ មេសា ១៩៧៦ ស្ដីអំពីការសុំចូលនិវត្តន៍របស់សម្ដេចនរោត្ដម សីហនុ ដែលរដ្ឋាភិបាលបានបញ្ជូនមកសភា"។

ខ្ញុំសូមឈប់ត្រឹមនេះ ហើយសុំសួរទៅលោកស្រីអំពីរបៀបវារនេះឲ្យជាក់លាក់ម្ដង។ លោកស្រីនៅចាំបាន ថាលោកស្រីធ្លាប់បានចូលរួមប្រជុំពាក់ព័ន្ធទៅនឹងសំណើសុំចូលនិវត្តន៍របស់សម្ដេចនរោត្ដម

សីហនុ ដែរឬទេ?

**ឆ៖** ខ្ញុំអត់ដែលពាក់ព័ន្ធជាមួយសម្តេចផង។ អត់ដឹងគាត់សុំ សម្តេចគាត់ចេញទៅណាក៏ខ្ញុំអត់ដឹង។ ខ្ញុំមិនបានលើកបញ្ហាហ្នឹងមករំឭកនៅក្នុងខ្លួនទេ ព្រោះខ្ញុំអត់ដឹងរឿង។ សម្តេចគាត់ទៅនៅអភិវឌ្ឍន៍អីក៏ខ្ញុំអត់ដឹងដែរ។

[១៤:៣១:៤៥]

**ស៖** សំណួររបស់ខ្ញុំលោកស្រីធ្លាប់ចាំទេ ថាលោកស្រីធ្លាប់មានបានចូលរួមប្រជុំពិភាក្សាសម្រេចទៅលើសំណើសុំចូលនិវត្តន៍របស់សម្តេចនរោត្តម សីហនុ ទេ? តើលោកស្រីធ្លាប់មានវត្តមានក្នុងកិច្ចប្រជុំបែបនេះដែរទេ?

**ឆ៖** អត់។

**លោក ឌេល លីសាក់៖**

សូមអធ្យាស្រ័យ ខ្ញុំអត់បានឮសូរចម្លើយទេ។

**ប្រធានអង្គជំនុំ៖**

លោកស្រីឆ្លើយតបនឹងចម្លើយដែលគាត់ តបនឹងសំណួរដែលគាត់សួរអម្បាញ់មិញនេះ។

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** អត់បានចូលរួមនៅក្នុង-- សំណួរហ្នឹងខ្ញុំអត់ដឹងដែរ។ អត់ដឹងហើយ អត់ដែលឮទៀត។ នេះខ្ញុំសូមនិយាយដោយស្មោះត្រង់នៅមុខអស់លោកទាំងអស់ ព្រោះការចូលរួមនេះ ខ្ញុំអត់ដែលបានចូលរួមទេ។ ហើយខ្ញុំឆ្លើយម៉េចរួច បើខ្ញុំអត់ដឹង។

[១៤:៣២:៥៦]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំមានសំណួរមួយចំនួនទៀត សួរទៅលោកស្រីទាក់ទងទៅនឹងការជម្លៀសប្រជាជនលើកទី-- សហការីរបស់ខ្ញុំបានសួរទៅលោកស្រីខ្លះៗហើយ ទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ។

ទីមួយ តើយោងទៅតាមសក្ខីកម្មរបស់លោកស្រីដែលបានផ្តល់ជូនយើងនៅថ្ងៃនេះ នៅថ្ងៃទី១៧ មេសា ១៩៧៥ លោកស្រីគឺជាសមាជិកតំបន់៣៥ នៅកំពត។ តើត្រឹមត្រូវទេ?

**ឆ៖** ត្រឹមត្រូវ។

**ស៖** លោកស្រីអាចជម្រាបជូនអង្គជំនុំជម្រះបានទេ នៅចាប់ពី១៧ មេសា ៧៥ នុ៎ង តើមានការខ្វះស្បៀងអាហារដែរឬទេ នៅកំពតនោះ?

**ឆ៖** កាលខ្ញុំនៅកំពត ការខ្វះស្បៀងអាហារគឺអត់សូវមានទេ ព្រោះក្នុងស្រុកហ្នឹងបើគិតទៅមានការហូបគ្រប់គ្រាន់ ស៊ីចុកគ្រប់គ្រាន់ អត់សូវខ្វះស្បៀងទេ។ អាហ្នឹងតាមការរស់នៅផ្ទាល់ខ្លួនខ្ញុំ ហើយខ្ញុំមើលប្រជាជននៅកំពតទាំងមូល អត់សូវមានអត់បាយអត់ទឹកទេ។ គឺមានហូបគ្រប់គ្រាន់ ប៉ុន្តែការហូបនោះក៏មិនមានគ្រប់គ្រាន់ទាំងអស់ទេ វាមានកន្លែងខ្លះខ្វះខាតដែរ ប៉ុន្តែអាចជួយគ្នាទៅវិញទៅមកបាន។ នេះនៅកំពតទាំងមូល អានេះខ្ញុំមើលឃើញជាក់ស្តែងតែម្តង ព្រោះខ្ញុំនៅហ្នឹងដែរ។ មិនទាន់អត់អាហារ ដល់ស្លាប់អី អត់មានទេ គឺគ្រាន់ថាទប់ទល់បាន ការជួយដោះដូរគ្នាបាន។ នេះខ្ញុំសូមមាន។

[១៤:៣៥:០៥]

**ស៖** ក្នុងឋានៈជាសមាជិកតំបន់៣៥ លោកស្រីអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា ហេតុអ្វីបានជាក្រុងកំពតនេះត្រូវបានគេជម្លៀសប្រជាជនចេញនៅថ្ងៃ១៧ មេសា ៧៥ហ្នឹង។ ហេតុអ្វីបានគេជម្លៀសប្រជាជនចេញពីក្រុងកំពត?

**ឆ៖** ខ្ញុំសូមជម្រាបលោកប្រធានទាំងអស់ថា ការជម្លៀសប្រជាជនក្រុង-- ខ្ញុំបានជម្រាបខាងដើមហើយថា ខ្ញុំអត់បានដឹងដែរ។ ការជម្លៀសប្រជាជនចេញពីក្រុងនេះ ខ្ញុំមិនបានចាំ មិនបានដឹងទេ។ ហើយបើសូម្បីតែគណៈតំបន់ ក៏គាត់មិនប្រាប់ខ្ញុំ ខ្ញុំក៏មិនបានដឹងថាត្រូវការជម្លៀសប្រជាជនចេញពីក្រុង ខ្ញុំអត់ដឹង។ នេះខ្ញុំនិយាយស្មោះត្រង់ ការពិតតែម្តង។ ហើយដល់គាត់ជម្លៀសមកខ្ញុំ ខ្ញុំមិនដឹងថាម៉េចក៏ខ្ញុំមិនអ្នកជម្លៀសឯណា ខាងលើគាត់ជម្លៀស ខ្ញុំអត់ដឹងដែរហ្នឹង។ អានេះខ្ញុំនិយាយដោយការពិតណាមិនមែនថា ខ្ញុំមកឡើងតុលាការហើយ ខ្ញុំចេះតែនិយាយឲ្យរួចខ្លួនទេ។ នេះខ្ញុំនិយាយឲ្យជូនលោកប្រធានឲ្យជ្រាបអ៊ីចឹង ខ្ញុំអត់បានដឹង ព្រោះមិនដឹងថា គាត់ជម្លៀសប្រជាជនហ្នឹង គាត់យកមតិពីខាងណា ក៏ខ្ញុំអត់ដឹងដែរ។ នេះសូមជម្រាបត្រង់តែម្តង។

[១៤:៣៦:៣៦]

**ស៖** នៅពេលដែលលោកស្រីនិយាយថា នៅពេលគេជម្លៀសប្រជាជនតើប្រជាជនទាំងនេះត្រូវបានគេជម្លៀសចេញពីក្រុងកំពត ឬទេ?

**ឆ៖** ចាស ឃើញតើ! ខ្ញុំឃើញដែរហ្នឹង ឃើញគេជម្លៀសចេញពីក្រុងកំពតដែរហ្នឹង។ ប៉ុន្តែថាឲ្យខ្ញុំដឹងថាអ្នកណាជម្លៀសឈ្មោះអី គឺខ្ញុំអត់ដឹង។ ខ្ញុំអត់ស្គាល់ដែរ មិនដឹងអ្នកជម្លៀស។

**សៈ** ក្នុងនាមជាសមាជិកតំបន់៣៥ តើលោកស្រីមានចូលរួមនៅក្នុងជម្លៀសប្រជាជននៅក្នុងក្រុងកំពតនេះដែរឬទេ ក្នុងនាមជាសមាជិកតំបន់៣៥?

**ធៈ** ខ្ញុំអត់បានចូលរួមទេ ហើយក៏ខ្ញុំមិនបាននៅហ្នឹងដែរ ខ្ញុំនៅស្រែរហូត។ ឋានៈខ្ញុំម្នាក់គឺនៅស្រែរហូត គឺអត់ដែលមាននៅក្នុងក្រុងទេ សូម្បីតែ៧ មករា ក៏ខ្ញុំមិនបានទៅដែរ ខ្ញុំនៅជាមួយប្រជាជនពលរដ្ឋនៅស្រែ នៅកន្លែងធ្វើទំនប់ ធ្វើប្រឡាយអីនេះ ខ្ញុំមិនដែលទៅនៅក្រុងទេ។ ហើយគាត់ធ្វើអី គឺគាត់ធ្វើនៅក្រុង ខ្ញុំអត់ដឹង។ អាហ្នឹងធម្មតាតែគាត់ជម្លៀសមក ខ្ញុំឃើញដែរ ប៉ុនខ្ញុំក៏មិនចាំអារម្មណ៍ថាម៉េចដែរ បើអាហ្នឹងខាងលើ ខ្ញុំនិយាយអ៊ីចឹងតែម្តង។

[១៤:៣៨:០៥]

**សៈ** ថាតើគណៈតំបន់៣៥ បានទទួលការណែនាំថាត្រូវធ្វើយ៉ាងម៉េច ចំពោះប្រជាជនដែលត្រូវជម្លៀសដែរឬទេ ប្រសិនបើលោកស្រីដឹងនោះ?

**ធៈ** អត់ដឹង ខ្ញុំអត់ដឹង។ ខ្ញុំអត់ដឹងដែរ គណៈតំបន់គាត់ធ្វើយ៉ាងម៉េចៗ ខ្ញុំអត់ដឹងទេ។ ដូចខ្ញុំជម្រាបអ៊ីចឹងថាដដែលៗអ៊ីចឹង ថាខ្ញុំវាអត់ដឹង ព្រោះគាត់ជម្លៀសមក គាត់ទទួលខុសត្រូវខ្លួនគាត់ គាត់ធ្វើខ្លួនគាត់ អ៊ីចឹងមិនដឹងថាយ៉ាងម៉េច ខ្ញុំអត់ដឹងដែរ។ អាហ្នឹងសួរពីរបីសាហើយរឿងហ្នឹង។

**សៈ** លោកប្រធាន ខ្ញុំនៅសល់តែសំណួរតែមួយទៀតទេ បើសិនជាអនុញ្ញាត ខ្ញុំសូមសួរចុងក្រោយ។ សំណួរចុងក្រោយ ដែលខ្ញុំសុំសួរលោកស្រី ប្រាក់ យុត នោះគឺថាតើគណៈតំបន់៣៥មានទទួលការណែនាំឲ្យធ្វើយ៉ាងម៉េច ចំពោះមន្ត្រីរដ្ឋការនៅក្នុងសម័យ លន់ នល់ ដែរឬទេ ដែលនៅសល់ហ្នឹង?

**ធៈ** ខ្ញុំអត់សូវច្បាស់ទេ សួរម្តងទៀត។

**សៈ** ថាតើគណៈតំបន់៣៥ មានទទួលការណែនាំ ឬក៏លោកស្រីមានទទួលការណែនាំថា តើត្រូវធ្វើយ៉ាងម៉េចចំពោះមន្ត្រី ឬក៏អ្នករដ្ឋការ រួមទាំងទាហានរដ្ឋការ លន់ នល់ ដែរឬទេ?

**ធៈ** ខ្ញុំអត់យល់។ អត់យល់សំណួរ។

[១៤:៤០:០០]

**សៈ** ខ្ញុំសូមអានសេចក្តីថ្លែងការណ៍ដែលលោកស្រីបានឆ្លើយទៅដល់អ្នកស៊ើបអង្កេត គឺឯកសារ D234/4 នៅលេខ ERN ជាភាសាអង់គ្លេសគឺ 00364084 ខ្មែរគឺ 00357514 ហើយភាសាបារាំងគឺ 00403127 ការឆ្លើយរបស់លោកស្រីមានដូចតទៅ៖ ថាតើមានផែនការអ្វីខ្លះចំពោះមន្ត្រីរដ្ឋការ ប៉ូលិស ទាហាន បញ្ញវន្ត របស់របបលន់ នល់? ចម្លើយ៖ ខ្ញុំទទួលបញ្ជាពីថ្នាក់តំបន់ឲ្យជួយអប់រំ ហើយការចាប់

យកទៅណាទៀតនោះ ខ្ញុំមិនដឹងទេ។ បញ្ចប់នូវការដកស្រង់ ចម្លើយដែលលោកស្រីបានឆ្លើយជូនអ្នកស៊ើបអង្កេត។

នៅពេលដែលលោកស្រីឆ្លើយជូនអ្នកស៊ើបអង្កេតនោះ ថាតើលោកស្រីមានបានឆ្លើយថាបានទទួលបញ្ជាសម្រាប់ការធ្វើផែនការចំពោះមន្ត្រីរដ្ឋការប៉ូលិស ទាហានលន់ នល់ ដែរឬទេ?

**ឆ៖** ខ្ញុំអត់បានទទួលផងហ្នឹង។ ចំពោះរដ្ឋការមន្ត្រីរាជការទាំងអស់ គឺដូចដែលតាមចម្លើយស៊ើបអង្កេត គឺខ្ញុំឯកភាព។

**ស៖** ខ្ញុំហាក់ដូចជាវិលវល់ទៅនឹងចម្លើយបន្តិច លោកស្រីបានជម្រាបអ្នកស៊ើបអង្កេតថា លោកស្រីបានទទួលបញ្ជាពីថ្នាក់តំបន់ឲ្យជួយអប់រំមន្ត្រីរដ្ឋការ ប៉ូលិស ទាហានពីសម័យលន់ នល់ តើមែនដែរឬទេ? ត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រូវ។

[១៤:៤២:១៨]

**ស៖** តើលោកស្រីទទួលបញ្ជាពីនរណាមកដែរ?

**ឆ៖** ខាង អង្គាល់ហ្នឹងតាចាបគាត់ឲ្យខ្ញុំធ្វើជួយអប់រំ រាជការ មន្ត្រីដែលយើងបាននេះនោះ ហើយគាត់ឲ្យអប់រំតាមភូមិឃុំហ្នឹងណា តាមស្រុក ខ្ញុំបានធ្វើតាមបញ្ជាគាត់។ ខ្ញុំស្តាប់សំណួរអត់បាន។

**ឆ៖** ដូច្នេះហើយលោកស្រីសំដៅទៅលើលេខាតំបន់ កង ចាប ដែលទទួលបញ្ជាពីគាត់មក តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ចាស ត្រឹមត្រូវ។

**លោក ខេល លីសាក់៖**

សូមអរគុណលោកស្រី ប្រាក់ យុត។ លោកប្រធាន ខ្ញុំអស់ហើយ ត្រឹមសំណួរប៉ុណ្ណឹង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយដល់ពេលសមល្មមនឹងសម្រាកដែរហើយ។ ប៉ុន្តែមុននឹងសម្រាក អង្គជំនុំជម្រះសូមសួរទៅភាគីទាំងអស់ --

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៤៤:០៣]

ឥឡូវនេះដល់ម៉ោងសមល្ហមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះទៅ រហូតដល់ម៉ោងបីប្រាំនាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៥ នាទី ដល់ម៉ោង ១៥:០៦ នាទី)*

[១៥:០៦:១១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយវេទិកាបន្តនេះ គឺដល់វេទិកាសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែមុននឹងផ្តល់វេទិកាទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការសួរដល់សាក្សីរូបនេះ អង្គជម្រះសូមប្រកាសនូវសេចក្តីសម្រេចផ្ទាល់មាត់ ស្តីពីបញ្ហាឯកសារដែលបានខ្ទឹមសារ ដូចខាងក្រោមនេះ៖

ក្នុងអំឡុងសវនាការសប្តាហ៍កន្លងទៅនេះ ភាគីបានលើកឡើងនូវសំណួរពាក់ព័ន្ធនឹងការអនុវត្តឲ្យបានសមស្របចំពោះវិធាន៨៧ នៃវិធានផ្ទៃក្នុង អ.វ.ត.ក។ ឥឡូវនេះ អង្គជម្រះសាលាដំបូង សូមផ្តល់គោលការណ៍ណែនាំដូចខាងក្រោម៖

ពាក់ព័ន្ធនឹងការអនុវត្តនូវវិធាន៨៧ នៃវិធានផ្ទៃក្នុង ដោយហេតុថា វិធាននេះជាប់ទាក់ទិននឹងភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន រួមទាំង យថាភាពនៃឯកសារដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ វិធាន៨៧(៣) ចំណុច(ក) នៃវិធានផ្ទៃក្នុងតម្រូវថា “ឯកសារត្រូវមានភាពជាប់ពាក់ព័ន្ធ ឯកសារមួយដែលមិនមានភាពជាប់ពាក់ព័ន្ធ ឬគ្មានយថាភាពទេនោះ អាចត្រូវបានពិចារណា ដោយអង្គជំនុំជម្រះថា មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុ ដែលជាគោលដៅ ដែលត្រូវបញ្ជាក់នោះឡើយ”។

[១៥:០៨:១៣]

វិធាន៨៧(៣) ចំណុច(គ) នៃវិធានផ្ទៃក្នុង។ វិធាន៨៧(៣) តម្រូវឲ្យឯកសារបំពេញនូវបទដ្ឋាននៃសេចក្តីបញ្ជាក់ដំបូង នៃភាពជាប់ពាក់ព័ន្ធ និងភាពអាចជឿជាក់បាន ដោយរួមបញ្ចូលទាំងយថាភាពនៃឯកសារនោះផង។ ឧទាហរណ៍ ប្រសិនបើឯកសារមួយ មិនបានបង្ហាញថាក្លែងក្លាយ ឬជាឯកសារមិនតំណាងឲ្យឯកសារដើមគ្តី ឯកសារនេះនឹងត្រូវបានចាត់ទុកថា បានដាក់នៅចំពោះមុខអង្គជំនុំជម្រះ។

ការជំទាស់ណាមួយលើបញ្ហានេះ ចាំបាច់ត្រូវលើកឡើងនៅពេលដែលឯកសារមួយ ឬភស្តុតាងផ្សេងទៀតកំពុងត្រូវបានដាក់ចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ សំណើផ្សេងៗអំពីភាពអាចជឿជាក់បាននៃឯកសារ អង្គជំនុំជម្រះនឹងថ្លឹងថ្លែងសម្រេចចំពោះឯកសារនោះ។

វិធាន៦៧(៣) នៃវិធានផ្ទៃក្នុង តម្រូវឲ្យសហចៅក្រមស៊ើបអង្កេត ធ្វើការត្រួតពិនិត្យ និងវាយតម្លៃឯកសារទាំងឡាយ ដើម្បីកំណត់ថា តើជាទូទៅមានភស្តុតាងគ្រប់គ្រាន់ក្នុងការគាំទ្រដល់បទចោទនានាប្រឆាំងនឹងជនជាប់ចោទដែរឬយ៉ាងណា? ដំណើរការនេះតម្រូវជាចាំបាច់នៅក្នុងដំណាក់កាលស៊ើបអង្កេតឲ្យមានការកំណត់នូវភាពពាក់ព័ន្ធ និងផ្តល់តម្លៃជាភស្តុតាងមួយចំនួន ដែលភស្តុតាងទាំងនោះ ត្រូវបានយោងនៅក្នុងដីកាដំណោះស្រាយ។ បន្ថែមលើនេះទៀត សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតនេះ ត្រូវបានពិនិត្យឡើងវិញនៅពេលមានបណ្តឹងឧទ្ធរណ៍ទៅកាន់អង្គបុរេជំនុំជម្រះ។

[១៥:១០:២៧]

អាស្រ័យនេះ អង្គជំនុំជម្រះសាលាដំបូងធ្វើការសន្មតទៅលើឯកសារនានា ក្នុងដីកាដំណោះស្រាយថា មានភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន រួមទាំងយថាភាពរបស់ផង ហើយអង្គជំនុំជម្រះបានផ្តល់ចំណាក់ថ្នាក់ E3 ដល់ឯកសារទាំងនោះ។ ពុំមានការសន្មតជាមុនបែបនេះឡើយចំពោះឯកសារទាំងឡាយដែលមាននៅក្នុងសំណុំរឿង ប៉ុន្តែពុំឃើញមានយោងនៅក្នុងដីកាដំណោះស្រាយនោះ។

ឯកសារដើមគឺជាវិធីសាស្ត្រប្រសើរជាងគេ នៃការយកមកបង្ហាញជាភស្តុតាង ហើយនិងត្រូវបានផ្តល់ទម្ងន់ច្រើនជាងឯកសារថតចម្លង។ ការដែលថា ពាក្យពេចន៍នៅក្នុងឯកសារមួយ ពុំអាចអានបាននោះ គឺមិនអាចរារាំងការដាក់ឯកសារនោះ ចំពោះមុខអង្គជំនុំជម្រះបានទេ។ បញ្ហាបែបនេះ គឺជាប់ពាក់ព័ន្ធនឹងទម្ងន់នៃភស្តុតាង ហើយនិងមិនត្រូវបានពិចារណាឡើយនៅពេលវាយតម្លៃអំពីលក្ខខណ្ឌតម្រូវនៃវិធាន៨៧(៣) នៃវិធានផ្ទៃក្នុង។ សម្ភារៈមួយចំនួន ដូចជារាយការណ៍ដែលមានកាលវិភាគ សៀវភៅភាពយន្តឯកសារ និងអត្ថបទដកស្រង់ចេញពីប្រព័ន្ធផ្សព្វផ្សាយ អាចមានការពាក់ព័ន្ធ ហើយនិងត្រូវរាប់ចូលជាប្រភេទនៃឯកសារមួយផងដែរ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះនឹងពិចារណាសម្រេចអំពីតម្លៃជាភស្តុតាងនៃឯកសារទាំងនេះ នាពេលសមស្របខាងមុខ។

[១៥:១២:១៤]

តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី អាយ.ស៊ី.ធី.វ៉ាយ និងតុលាការព្រហ្មទណ្ឌអន្តរជាតិនានា បានអនុម័តនូវការអនុវត្តដែលថា អនុញ្ញាតឲ្យចៅក្រមដកចេញនូវភស្តុតាង ប្រសិន

បើតម្លៃនៃភស្តុតាងនោះ មានលក្ខណៈលម្អៀងជាខ្លាំង។ តាមតម្រូវការនៃការធានាឲ្យមានការជម្រះក្តីប្រកបដោយយុត្តិធម៌។ គោលការណ៍នេះ មិនមានចែងនៅក្នុងច្បាប់ អ.វ.ត.ក ឬវិធាននៃក្របខ័ណ្ឌច្បាប់ទេ។ ហើយទោះក្នុងករណីណាក៏ដោយ វាមិនចាំបាច់នោះទេ ពីព្រោះថាចៅក្រមវិជ្ជាជីវៈ សមត្ថភាពក្នុងការដកចេញនូវភស្តុតាងទាំងឡាយណា ដែលលក្ខណៈបុរេវិនិច្ឆ័យដោយមិនត្រឹមត្រូវ។ ពុំមានលក្ខណៈតម្រូវផ្នែកនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងការកោះហៅសាក្សីដែលមានចំណេះដឹងផ្ទាល់ខ្លួនយកមកផ្តល់យថាភាពដល់ឯកសារនានា នៅក្នុងសំណុំរឿងនោះទេ។

ទោះជាយ៉ាងនេះក្តី សក្ខីកម្មទាក់ទិននឹងដំណើររក្សាទុកភស្តុតាង និងប្រភពឯកសារ និងជួយដល់អង្គជំនុំជម្រះក្នុងការវាយតម្លៃអំពីទម្ងន់ដែលត្រូវបញ្ជាក់លើឯកសារជាក់លាក់នានា។

[១៥:១៣:៤៨]

កន្លងមក អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ថាភាគីនានាដែលស្នើសុំបង្ហាញឯកសារ នៅពេលសវនាការត្រូវធានាឲ្យទាន់ពេលនូវឯកសារបកប្រែជាភាសាផ្លូវការទាំងបីភាសា។ មើលឯកសារ E131/1។ អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការលើកលែងខ្លះ ក្នុងករណីដែលភាគីមិនអាចផ្តល់ឯកសារទាំងបីភាសាបាន ដោយសារអង្គភាពបកប្រែភាសាមានទំហំការងារច្រើនពេក មិនបានអាចបកប្រែឯកសារបានទាន់ពេលវេលា និងផ្នែកពាក់ព័ន្ធនៃឯកសារ ដែលភាគីមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះត្រូវបានយកទៅប្រើជាមូលដ្ឋានក្នុងការសួរដេញដោលសាក្សី ឬជនជាប់ចោទ។ ប្រសិនបើឯកសារនោះ មានយ៉ាងហោចណាស់មួយភាសា ហើយជាភាសាដែលជនជាប់ចោទ ឬសាក្សីអាចយល់បាន។

[១៥:១៤:៤៨]

លើសពីនេះ ផ្នែកពាក់ព័ន្ធខ្លីៗនៃឯកសារដែលអាចងាយស្រួលក្នុងការបកប្រែក្នុងពេលសវនាការ អង្គជំនុំជម្រះអាចអនុញ្ញាតឲ្យយកផ្នែកពាក់ព័ន្ធខ្លីៗនៃឯកសារនោះ មកដាក់ចំពោះមុខជនជាប់ចោទ ឬសាក្សីបាន។

ដោយហេតុថា ភាគីនូវបន្តលើកឡើងអំពីបញ្ហានេះ អង្គជំនុំជម្រះសូមបញ្ជាក់ជាថ្មីថា ភស្តុតាងដែលទទួលបាន តាមរយៈការធ្វើទារុណកម្ម ត្រូវបានយកមកប្រើដោយមានកម្រិត។ អង្គជំនុំជម្រះសូមរំឭកឡើងវិញនូវអនុស្សរណៈ E74 របស់ខ្លួនក្នុងសំណុំរឿង០០២ និងសេចក្តីសម្រេចផ្ទាល់មាត់ក្នុងសំណុំរឿង០០១ នៅថ្ងៃទី២០ និងថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩។

នេះគឺជាសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូង លើការអនុវត្តទូទៅនៃវិធាន

៨៧ នៃវិធានផ្ទៃក្នុង។ ការជំទាស់ទៅនឹងឯកសារជាក់លាក់នានា នឹងត្រូវដោះស្រាយនៅពេលសមស្រប ខាងមុខ។

[១៥:១៦:០១]

បញ្ហាទីពីរ ដោយអង្គជំនុំជម្រះសាលាដំបូង មានបំណងធ្វើសវនាការនៅសប្តាហ៍ខាងមុខ និង សប្តាហ៍បន្ទាប់ ក្នុងការស្តាប់ចម្លើយសាក្សី ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយនិងស្តាប់ សក្ខីកម្មរបស់អ្នកជំនាញ TCE-80។ ដូច្នេះអង្គជំនុំជម្រះសូមសួរទៅភាគីទាំងអស់ សូមឲ្យផ្តល់នូវ ព័ត៌មាននូវការប៉ាន់ស្មានពេលវេលារបស់ខ្លួន ដែលមានបំណងនៅក្នុងសាកសួរទៅដល់សាក្សី និងអ្នក ជំនាញដូចបានជម្រាបជូនអម្បាញ់មិញនេះ។

ហើយអង្គជំនុំជម្រះគិតថា ប្រហែលជាទំនងមិនបានចម្លើយតបភ្លាមទេ ដោយសារត្រូវការពេល វេលាគិត។ ហេតុដូច្នេះ អង្គជំនុំជម្រះសូមឲ្យភាគីផ្តល់ព័ត៌មានអង្គជំនុំជម្រះសាលាដំបូង នៅព្រឹកថ្ងៃ ស្អែកឲ្យបានមុនម៉ោងដប់ពីរថ្ងៃត្រង់ ហើយសូមឲ្យផ្តល់មកតាមរយៈអ៊ីម៉ែល ជូនទៅមន្ត្រីច្បាប់ជាន់ខ្ពស់ នៃអង្គជំនុំជម្រះសាលាដំបូង។ ឯកាលវិភាគ និងការបែងចែកពេលវេលាជាក់លាក់ អង្គជំនុំជម្រះនឹង ជម្រាបជូនដំណឹងដល់ភាគីក្នុងពេលឆាប់ៗ។

ជាកិច្ចបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកា ទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលមានមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទទួលសិទ្ធិឡើង អាចតាំងសំណួរចំពោះសាក្សីរូបនេះ។

បាទ ដោយសារមានបញ្ហាការក្រោកឈរ របស់លោកមេធាវីអន្តរជាតិការពារក្តី នួន ជា។

សូមអញ្ជើញលោកមេធាវី!

[១៥:១៨:១២]

**លោក ម៉ៃខល ផេសមិនៈ**

សូមអរគុណលោកប្រធាន។ តាមដែលខ្ញុំយល់ គឺថាតើសាក្សីជំនាញមួយណាដែលអង្គជំនុំជម្រះ មានគោលបំណងនឹងកោះហៅនោះ? តើអង្គជំនុំជម្រះមិនចង់ស្តាប់ចម្លើយកូនក្តីរបស់ខ្ញុំ ស្តីអំពីប្រវត្តិនៃ កម្ពុជាប្រជាធិបតេយ្យទេឬ?

[១៥:១៨:៤០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:១៩:៣៧]

**ប្រធានអង្គជំនុំ៖**

ខ្ញុំសូមជម្រាបបញ្ជាក់បន្ថែម ដោយសារបញ្ហាដែលយើងជម្រាបជូនរួចហើយ ក្នុងការស្តាប់សក្ខីកម្មដែលយើងធ្វើទន្ទឹមគ្នាជាមួយនឹងជនជាប់ចោទ។ ហើយអ្វីដែលអង្គជំនុំជម្រះបានជម្រាបជូនកន្លងមក គឺដំណើរការនីតិវិធីក្នុងការសួរចម្លើយជនជាប់ចោទ យើងនឹងធ្វើបន្តជាហូរហែ ប៉ុន្តែអម្បាញ់មិញនេះ គឺបំពេញបន្ថែមនូវពេលវេលាសម្រាប់កិច្ចដំណើរការសម្រាប់សប្តាហ៍ក្រោយ និងសប្តាហ៍ក្រោយមួយទៀត។ ដោយពេលវេលាដែលជនជាប់ចោទលោក នួន ជា គាត់រក្សាសិទ្ធិនៅក្នុងការប្រើប្រាស់ពេលវេលាឆ្លើយតបនឹងសំណួរផ្សេងៗតែពេលព្រឹកទេ។ អ៊ីចឹងនៅក្នុងគ្រប់កិច្ចដំណើរការទាំងអស់គឺរាល់ពេលវេលាគឺសម្រាប់សប្តាហ៍នីមួយៗ ការពាក់ព័ន្ធទៅនឹងការសួរចម្លើយលោក នួន ជា គឺវាអាស្រ័យទៅលើពេលវេលាដែលចាំបាច់នៅក្នុងកិច្ចដំណើរការ ប៉ុន្តែជាទូទៅយើងនឹងប្រើប្រាស់ពេលវេលាពេលព្រឹកសម្រាប់សួរឲ្យជនជាប់ចោទ នួន ជា។

ហើយដោយឡែកនៅសប្តាហ៍ក្រោយនេះ យើងនឹងកំណត់ជូនដំណឹងតាមរយៈដែលយើងប្រាប់អំមិញ បន្ទាប់ពីទទួលនូវសំណូមពរ សំណើសុំអំពីការចំណាយពេលវេលាផ្សេងៗសម្រាប់សួរដល់សាក្សី និងអ្នកជំនាញ គឺអង្គជំនុំជម្រះក៏នឹងសួរដល់ នួន ជា នៅពេលព្រឹកដែរ។ ជាពិសេស នៅពេលព្រឹកថ្ងៃច័ន្ទ ហើយនិងថ្ងៃអង្គារ ដើមសប្តាហ៍ក្រោយ។

ហើយចំណែកឯរសៀល យើងនឹងបន្តស្តាប់សក្ខីកម្មសាក្សី ប្រាក់ យុត ដែលភាគីមិនទាន់បានសាកសួរនៅឡើយ។ ហើយបញ្ហាផ្សេងទៀតគឺមានសាក្សីដែលយើងបានប្រាប់អម្បាញ់មិញ រួមទាំងអ្នកជំនាញ TCE-80 ផង។ ឯកាលវិភាគលម្អិតនោះ គឺអង្គជំនុំជម្រះនឹងជម្រាបជូនពេលឆាប់ៗ ទំនងជាស្អែករសៀល បន្ទាប់ពីបានទទួលព័ត៌មានស្តីពីការស្នើសុំពេលវេលាសមស្របសម្រាប់សួរដល់អ្នកជំនាញ និងសាក្សី។

អាចៗស្តាប់ច្បាស់ទេ?

[១៥:២២:០៥]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន ច្បាស់ហើយ។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តសូមផ្តល់វេទិកាទៅមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលទទួលសិទ្ធិពី

មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានឱកាសក្នុងការតាំងសំណួរចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

[១៥:២២:៣២]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក សំ សុគង់៖**

បាទ ជាបឋម ខ្ញុំបាទសូមគោរពលោកប្រធាន ហើយនិងសូមគោរពចៅក្រមប្រឹក្សា! ហើយសូមជម្រាបសួរលោកស្រី ប្រាក់ យុត ហើយខ្ញុំសូមតាំងសំណួរមួយចំនួនទៅលោកស្រី។

**ស៖** ពីព្រឹកមិញ ក៏ដូចជាពីម៉ោងពីខាងមុខនេះ លោកស្រីបានមានប្រសាសន៍ថា លោកស្រីបានចូលបដិវត្តន៍។ ចូលបដិវត្តន៍ហ្នឹងតាមរយៈពូ លោកពូឈ្មោះ អ៊ំហែម ជាគណៈស្រុកខេត្តកំពត។ តើនៅពេលដែលលោកស្រីចូលបដិវត្តន៍ហ្នឹង តើលោកស្រីមានបានធ្វើអ្វី ការងារអ្វីសម្រាប់ឲ្យបដិវត្តន៍ទេនៅពេលដែលលោកស្រីចូលបដិវត្តន៍ដំបូងនោះ?

[១៥:២៣:២០]

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំសូមឆ្លើយ។ កាលនោះ ខ្ញុំនៅអាយុ១៣ឆ្នាំចូលជាមួយអ៊ំខ្ញុំនៅកំពង់ស្ពឺ អ៊ំហែម ហ្នឹង តែកាលនោះខ្ញុំអត់បានធ្វើអីទេ គ្រាន់តែចូលមកគាត់ណែនាំខ្ញុំទេ តែចំពោះខ្ញុំអត់ទាន់បានធ្វើ អត់ទាន់បានការដឹកនាំអីទេ។ អ៊ីចឹងខ្ញុំសូមជម្រាបខ្លីតែប៉ុណ្ណឹង។ ខ្ញុំចូលបដិវត្តន៍ហ្នឹងអត់បានធ្វើអីទេ។

**ស៖** នៅពេលដែលលោកស្រីចូលបដិវត្តន៍ហ្នឹង លោកស្រីធ្លាប់ធ្វើការជាអ្នកកាត់ដេរនៅក្នុងរោងចក្រទេ?

**ឆ៖** ខ្ញុំអត់មានចូលបដិវត្តន៍ហ្នឹង កាលនៅជំនាន់នោះ ខ្ញុំអត់ទាន់បានអីទេ ខ្ញុំគ្រាន់តែកាត់ដេរនៅតំបន់កំពតហើយហ្នឹង ខ្ញុំមកនៅកំពតហ្នឹង ខ្ញុំកាត់ដេរខោអាវកងទ័ព។ ហើយមានកម្លាំងហ្នឹងប្រហែលជាង ១៥០នាក់ ដេរខោអាវឲ្យកងទ័ពទេ ជំនាន់នោះ។ នេះខ្ញុំនៅខេត្តកំពតហើយ ខ្ញុំមកកាត់ដេរនោះ។

**ស៖** បាទ សូមអរគុណ។ ហើយទាក់ទងទៅនឹងកន្លែងកាត់ដេរនៅខេត្តកំពតហ្នឹង តើលោកស្រីជាប្រធាននៅរោងចក្រកាត់ដេរតែម្តង ឬក៏មានអ្នកណាធ្វើប្រធាន?

**ឆ៖** មានប្រធាន-- អត់មានរោងចក្រអីទេ គ្រាន់ថា កន្លែងហ្នឹងយើងរៀបរយនៅភូមិប្រជាជនយើងដាក់ម៉ាស៊ីនក្រោមផ្ទះគេអ៊ីចឹង យើងដេរ កាលជំនាន់នោះណាអូន។ អត់មានទៅមានរោងចក្រទេ

គ្រាន់ថាកាត់ដេរឲ្យកងទ័ពជាខោអាវអ៊ីចឹង ខោអាវស្លៀកពាក់ទេ។ ហើយនារីហ្នឹងប្រហែលជា ១៥០ ហើយក្នុងហ្នឹងមានខ្ញុំជាអ្នកទទួលខុសត្រូវនៅហ្នឹងដែរ។

[១៥:២៤:៥៨]

**ស៖** នៅពេលដែលលោកស្រីធ្វើជាអ្នកកាត់ដេរហ្នឹង តើនៅមុនឆ្នាំ១៩៧៥ ឬនៅក្រោយឆ្នាំ ១៩៧៥?

**ឆ៖** មុន មុន៧៥។

**ស៖** ទាក់ទងនឹងការដែលលោកស្រីធ្វើការកាត់ដេរជាខោអាវកងទ័ពហ្នឹង តើអ្នកណាដែលជាអ្នកបញ្ជាលោកស្រីឲ្យដើម្បីឲ្យធ្វើកាត់អាវកងទ័ពហ្នឹង ហើយកាត់ខោអាវកងទ័ពហ្នឹងដើម្បីអ្វី?

**ឆ៖** កាលហ្នឹង តាចាប គាត់ឲ្យខ្ញុំកាត់ខោអាវ។ កងទ័ពយកឲ្យស្លៀកពាក់ ព្រោះយើងកាលហ្នឹងមានទ័ពអី បើអត់មានខោអាវបានអីស្លៀក។ ទាល់តែយើងកាត់ដេរបញ្ជូនឲ្យគាត់។

[១៥:២៥:៤៣]

**ស៖** ហើយទាក់ទងនឹងការកាត់ខោអាវកងទ័ពហ្នឹង តើនៅពេលដែលកាត់បានហ្នឹង លោកស្រីបញ្ជូនទៅខាងណាវិញ?

**ឆ៖** បញ្ជូនឲ្យតាចាប។

**ស៖** បញ្ជូនឲ្យតាចាប។ មួយទៀតសំណួរទាក់ទងនឹងការជម្លៀស ដោយសារលោកស្រីពីព្រឹកមិញ លោកស្រីបានមានប្រសាសន៍ថា លោកស្រីបានឮអំពីការជម្លៀសពីខេត្តកំពត ប៉ុន្តែនៅពេលដែលនោះ គឺលោកស្រីជាគណៈតំបន់៣៥ផង ហើយក៏ជាកាន់នៅស្រុកកំពត។ ខ្ញុំចង់សួរថាតើទីតាំងស្រុកកំពត នៅក្នុងទីរួមខេត្តកំពត ឬមួយក៏នៅឆ្ងាយពីទីរួមខេត្តកំពត?

**ឆ៖** ទីតាំងស្រុកកំពត វានៅទីរួមខេត្តកំពត ជុំវិញកំពត ស្រុកកំពតហើយ នៅជិតគ្នាដែរ ដូចថានៅក្បាលរមាស អីអ៊ីចឹងណា៎ នៅជិតគ្នា។ ប៉ុន្តែនិយាយរួម គឺទីតាំងស្រុកកំពត វាទីរួមខេត្តហើយ។

**ស៖** អ៊ីចឹងនៅពេលដែលមានជម្លៀស នៅពេលដែលមានអ្នកជម្លៀសប្រជាពលរដ្ឋចេញពីទីរួមខេត្តកំពតហ្នឹង តើលោកស្រីមានបានឮគេប្រកាសជាវិទ្យុ ឬក៏មីក្រូ ដើម្បីឲ្យប្រជាពលរដ្ឋចេញពីទីរួមខេត្តកំពតទេ បើកន្លែងលោកស្រីធ្វើការនៅទីរួមខេត្តកំពតដែរនោះ?

**ឆ៖** កាលហ្នឹង ខ្ញុំមិននៅស្រុកកំពត ប៉ុន្តែខ្ញុំក៏មកនៅជិតនោះ នៅឆ្ងាយពីក្រុងកំពតដែរ។

តាណយ គាត់នៅហ្នឹង តែចំពោះខ្ញុំវាអត់បាននៅជាប់លាប់នៅហ្នឹងទេ។ ហេតុនេះការជម្លៀសប្រជាជនចេញពីក្រុងអី ក៏ខ្ញុំអត់បានដឹងទេ ព្រោះខ្ញុំនៅត្បិតស្រុកកំពតមែន ប៉ុន្តែនៅស្រែឆ្ងាយ នៅឃុំឆ្ងាយពីកំពតអីអ៊ីចឹង ខ្ញុំមកនៅអាឃុំឆ្ងាយទៅ ខ្ញុំមិនបាននៅជិតក្រុងទេ។ ហើយការជម្លៀសនេះ ក៏ខ្ញុំអត់ដឹងដែរ។ មិនដឹងជម្លៀសម៉ោងណា ពេលណា ខ្ញុំអត់ដឹងទេ។ ព្រោះខ្ញុំនៅឆ្ងាយពីស្រុក ខ្ញុំដូចថាស្រុកហ្នឹងវានៅជិតនៅខ្សែក្រវ៉ាត់ក្រុងមែន តែខ្ញុំអត់បាននៅហ្នឹងទេ ខ្ញុំនៅឆ្ងាយ ឆ្ងាយពីហ្នឹង នៅភូមិឆ្ងាយហួង ខ្ញុំមិនបាននៅជិតក្រុងទេ។

[១៥:២៧:៥៨]

**ស៖** ពាក់ព័ន្ធនឹងការជម្លៀស លោកស្រីពីព្រឹកមិញបានមានប្រសាសន៍ថា លោកស្រីបានឃើញមានប្រជាពលរដ្ឋដើរចេញពីទីរួមខេត្ត ទៅតំបន់នានា។ នៅពេលដែលលោកស្រីឃើញហ្នឹង តើលោកស្រីមានឃើញមានទាហានដើរអមជាមួយប្រជាពលរដ្ឋដែរឬទេ នៅពេលដែលលោកស្រីឃើញមានប្រជាពលរដ្ឋដើរតាមផ្លូវនោះ?

**ឆ៖** ក្នុងហ្នឹង ខ្ញុំមិនបានពិនិត្យពិច័យគ្រប់មុខដែរ មិនដឹងជាមានទាហាន ឬអត់ ព្រោះខ្ញុំក៏មិនបានដើរនៅតាម-- ដើរនៅ-- ដើរមកជិតដែរ ខ្ញុំនៅឆ្ងាយៗដែរ ខ្ញុំមិនបានដឹងថាទាហាន ឬអត់ទេ ខ្ញុំមិនបានពិនិត្យផ្ទាល់ដែរ។ មិនដឹងមានទាហាន កងការពារមកប្រជាជនហ្នឹងឬក៏អត់ ក៏ខ្ញុំវាអត់បានឃើញ។ វាមិនបានឃើញទាហានដើរតាម ឬក៏អត់។ នេះខ្ញុំសូមបញ្ជាក់ឲ្យខ្លីអ៊ីចឹង ព្រោះខ្ញុំវាអត់មានពិនិត្យពិច័យដែរក្នុងការជម្លៀសហ្នឹង។ ដូចខ្ញុំបានលើកឡើងមកហើយ គឺថាការជម្លៀសប្រជាជនេះ ខ្ញុំមិនបានដឹងដែរ ហើយមិនដឹងថាមានខាងណាអមដំណើរគាត់ ក៏អត់ ឬក៏មានអ្នកអម ឬក៏មានអ្នកអត់ គឺខ្ញុំអត់បានគិតគូរបញ្ហាហ្នឹងដែរ។ សូមអស់។

**ស៖** ខ្ញុំសូមឲ្យឆ្លងសំណួរមួយទៀតពាក់ព័ន្ធនឹងគណៈភូមិភាគ។ លោកស្រីអាចប្រាប់អង្គសវនាការបានទេថា ភូមិភាគនិរតីហ្នឹង តើមានប៉ុន្មានខេត្តដែលខាងភូមិភាគនិរតីគ្រប់គ្រង?

**ឆ៖** ភូមិភាគនិរតីមានតែតាកែវ កំពត កំពង់ស្ពឺ ហើយនិង-- តាកែវ កំពត កំពង់ស្ពឺ ប៉ុណ្ណឹងមានតែបួនខេត្ត។ មើល៍! តាកែវ កំពត កំពង់ស្ពឺ ហើយមានបួនខេត្ត បី! តាកែវ កំពត កំពង់ស្ពឺ។

**ស៖** នៅក្នុង--

**ឆ៖** មានបួនខេត្ត។

**ស៖** នៅក្នុងភូមិភាគ តើលោកស្រីអាចរៀបរាប់ពីរចនាសម្ព័ន្ធនៃការគ្រប់គ្រងនៅភូមិភាគបានទេ?

**ផ៖** អត់ទេ ខ្ញុំអត់មានគ្រប់គ្រងភូមិភាគផង។

**ស៖** លោកស្រីបានមានប្រសាសន៍ពីព្រឹកមិញថា លោកស្រីជាសមាជិកទីប្រាំមួយនៃតំបន់៣៥។ តើនៅក្នុងតំបន់៣៥ ជាតំបន់នៅទីរួមខេត្តកំពត ឬមួយក៏ជាតំបន់ដែលមាននៅទីរួមខេត្តតាកែវផងដែរ។

**ផ៖** ខេត្តកំពតៗ តាកែវៗ។

[១៥:៣០:៤៦]

**ស៖** នៅក្នុងតំបន់៣៥ ហ្នឹង តើនៅក្នុងតំបន់ហ្នឹងមានការិយាល័យធ្វើការ ឬក៏មានរចនាសម្ព័ន្ធបែបណាដែរ នៅក្នុងតំបន់៣៥ហ្នឹង?

**ផ៖** នៅក្នុងខេត្តកំពតមានការិយាល័យក្នុងខេត្តកំពតហ្នឹង មានតំបន់ណាចូលរួម។

**ស៖** នៅក្នុងតំបន់៣៥ ហ្នឹង តើមានការិយាល័យប៉ុន្មានដែលធ្វើការនៅក្នុងតំបន់៣៥ហ្នឹង?

**ផ៖** ខ្ញុំអត់បានដឹងដែរ ព្រោះអាហ្នឹងរបស់គណៈតំបន់។ ខ្ញុំមិនបានទៅត្រួតពិនិត្យ មិនដឹងជាមានការិយាល័យប៉ុន្មាន ខ្ញុំមិនបានដឹងទេ។ មិនដឹងជាការិយាល័យអីខ្លះ ព្រោះក្នុងហ្នឹងគាត់ប្រធាន គាត់អ្នករៀបរយ។

**ស៖** ខ្ញុំបានឮលោកស្រីមានប្រសាសន៍ពីព្រឹកមិញថា លោកស្រីជាប្រធាននៃកងចល័ត។ ខ្ញុំចង់សួរថា តើកងចល័តហ្នឹងស្ថិតនៅក្រោមការគ្រប់គ្រងថ្នាក់ណាមួយ? ហើយកងចល័តហ្នឹង គាត់មានសិទ្ធិសម្រេចអ្វីខ្លះទៅលើ នៅពេលនោះ?

[១៥:៣១:៥៤]

**ផ៖** ខ្ញុំលើកឡើងអំពីកងចល័ត។ ខ្ញុំកាន់កងចល័ត ខាងចល័តស្រុក ឬឃុំ។ ខ្ញុំមិនមែននៅក្នុងចល័តតំបន់ទេ។ អីចឹងនេះនៅការគ្រប់គ្រង ដូចថាខ្ញុំមានប្រធាន ខ្ញុំប្រធានរួមអីចឹង ប៉ុន្តែមានអនុខ្ញុំសមាជិកនៅក្នុងចល័តហ្នឹងទៅ។

**ស៖** អីចឹងនៅពេលដែលលោកស្រីមានបញ្ហា ឬក៏លោកស្រីមានការងារអីមួយ ដែលលោកស្រីត្រូវរាយការណ៍។ តើលោកស្រីរាយការណ៍ទៅណា ក្នុងនាមជាប្រធានកងចល័តនោះ?

**ផ៖** ខ្ញុំរាយការណ៍ទៅស្រុក។ ខ្ញុំក្រោមការដឹកនាំរបស់ស្រុក។

**ស៖** តើនៅពេលដែលរាយការណ៍ដល់ស្រុកហើយ តើថ្នាក់ស្រុករាយការណ៍ទៅណាបន្តទៀតលោកស្រី?

**ផ៖** កាលហ្នឹងរាយការណ៍ ស្រុករាយការណ៍ទៅតំបន់ទៅ។ គាត់រាយការណ៍ទៅតំបន់។ ខ្ញុំរាយការណ៍ឲ្យគាត់ តែគាត់រាយការណ៍ឲ្យតំបន់។

[១៥:៣២:៥៧]

**ស៖** នៅក្នុងតំបន់៣៥ ដែលលោកស្រីជាសមាជិកទីប្រាំមួយនៅទីនោះ ក៏ដូចជាលោកស្រីធ្លាប់ថាជាក្រុមការងារនៅក្នុងស្រុកកំពត តើនៅទីនោះមានសហករណ៍ទេ លោកស្រី?

**ផ៖** មានតើ។

**ស៖** ហើយនៅពេលនោះ តើសហករណ៍ហ្នឹងគាត់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ថ្នាក់ណាដែរ?

**ផ៖** សហករណ៍ ការគ្រប់គ្រងរបស់ឃុំនិងភូមិ។ ហើយហ្នឹងរបស់-- សំខាន់គឺភូមិ ឃុំហ្នឹងគ្រប់គ្រងសហករណ៍។

**ស៖** ពីព្រឹកមិញលោកស្រីបានមានប្រសាសន៍ថា ខាងថ្នាក់ស្រុកមានការប្រជុំយ៉ាងល្អិតល្អន់ ហើយក៏មានការធ្វើរបាយការណ៍ទៅថ្នាក់លើ ជាពិសេសគឺថ្នាក់តំបន់។ ខ្ញុំចង់ដឹងថា តើនៅពេលដែលធ្វើរាយការណ៍ជាលាយលក្ខណ៍អក្សរនេះ អ្នកណាជាអ្នកធ្វើរបាយការណ៍ ហើយនៅក្នុងរបាយការណ៍ហ្នឹងមានការចុះហត្ថលេខា ឬមានការស៊ីញ៉េទៅលើរបាយការណ៍ដើម្បីផ្ញើទៅថ្នាក់លើដែរឬទេ?

[១៥:៣៤:១១]

**ផ៖** ការរាយការណ៍ គឺស្រុកគាត់រាយការណ៍ គាត់ស៊ីញ៉េរបស់គាត់នៅក្នុងរបាយការណ៍ហ្នឹងរាយការណ៍ឲ្យតំបន់ ដោយមានស៊ីញ៉េ ដូចថាថ្នាក់ស្រុកគាត់ស៊ីញ៉េឲ្យទៅតំបន់។ នេះឆ្លើយប៉ុណ្ណឹង ខ្ញុំយល់ប៉ុណ្ណឹងដែរ។

**ស៖** នៅក្នុងរបាយការណ៍នីមួយៗ តើលោកស្រីមានបានឃើញថា នៅក្រោមរបាយការណ៍ហ្នឹងមានដាក់ថាចម្លងជូនទៅអ្នកណា ឬក៏ទៅខាងណាទេ លោកស្រី?

**ផ៖** ចម្លងជូនទៅ ដូចថា កង ចាប ជូនទៅ កង ចាប អ៊ីចឹងទៅ។ គាត់ប្រធានតំបន់មិនជូនទៅឲ្យគាត់។

**ស៖** ចុះក្រៅពី កង ចាប តើមានដាក់ចំណាងជើងថា ចម្លងជូនទៅអ្នកផ្សេងទៀតទេ?

**ផ៖** អត់ទេ។

[១៥:៣៥:០៩]

**សះ** បើតាមខ្ញុំស្តាប់ពីព្រឹកមិញ លោកស្រីថាកាលក្នុងឋានៈលោកស្រីជាសមាជិកទី៦ នៃគណៈតំបន់៣៥ ក៏ដូចជាអ្នកមានតួនាទីជួយលោក តាណយ ដែលគាត់ជាគណៈស្រុកនៅកំពតនោះ លោកស្រីជាអ្នកដើរអប់រំទៅលើយុវជន ក៏ដូចជាយុវនារី។ ខ្ញុំចង់ដឹងថាតើនៅពេលដែលលោកស្រីដើរអប់រំហ្នឹង តើលោកស្រីអប់រំពីប្រធានបទអីទៅដល់ខាងយុវជន និងយុវនារីទាំងនោះ?

**ឆះ** កាលហ្នឹងយើងអប់រំពីការ ធ្វើជាក់ស្តែងខ្ញុំកាលហ្នឹង អត់មានយកប្រធានបទអី ដូចថាអើប្រធានបទគ្រាន់ថា យើងយកគោលការណ៍មួយអប់រំអំពីការធ្វើអីមួយឲ្យច្បាស់លាស់ ដូចជាធ្វើប្រឡាយ ធ្វើទំនប់អីអ៊ីចឹង យើងកំណត់ជាគោលការណ៍ នៅក្នុងភូមិមួយៗក្នុងឃុំហ្នឹង យើងកំណត់ជាគោលការណ៍ឲ្យច្បាស់លាស់ ប៉ុន្តែឲ្យប្រធានបទច្បាស់លាស់ ក៏ខ្ញុំអត់មានដែរ។

[១៥:៣៦:២២]

**សះ** ពីព្រឹកមិញផងដែរ លោកស្រីក៏បានមានប្រសាសន៍ថា ភាគច្រើនគឺលោកស្រីថា មានកិច្ចប្រជុំ ជាពិសេសគឺជជែកគ្នាទាក់ទងនឹងការជីកប្រឡាយ ក៏ដូចជាធ្វើទំនប់ តើការជីកប្រឡាយ ឬធ្វើទំនប់នេះ គឺជាគំនិតផ្តួចផ្តើមរបស់លោកស្រីផ្ទាល់ ឬក៏ថ្នាក់ស្រុក ឬក៏ជាបញ្ជាពីខាងណាមកដែរ?

**ឆះ** ដូចថាយើងចង់ជីកប្រឡាយ ទំនប់ ឬមួយទំនប់កន្លែងណា គឺបញ្ជារបស់ស្រុក គឺគាត់បានប្រជុំគ្នា ឯកភាពជាមួយស្រុកហ្នឹង យើងដាក់ថា ឥឡូវស្រុកយើងជីកទំនប់មួយ ឬក៏ប្រឡាយមួយអ៊ីចឹងទៅណា។ យើងបានឯកភាពជាមួយស្រុក ហើយដល់ក្នុងហ្នឹងយើងមានគម្រោងហើយ យើងរាយការណ៍ឲ្យតំបន់ថា ឥឡូវហ្នឹងទំបន់ហ្នឹងធ្វើនៅកន្លែងណា ឲ្យគាត់ជួយមតិមកធ្វើបានឬអត់។ អាហ្នឹងគឺមានតំបន់យើងរាយការណ៍ឲ្យតំបន់ដែរ ព្រោះយើងមិនអាចធ្វើបានទេ មុននឹងធ្វើកន្លែងទំនប់មួយៗទាល់តែយើងវិភាគគ្នាល្អិតល្អន់។ នេះសូមមានមតិប៉ុណ្ណឹង។ មិនមែនធ្វើតែស្រុកទេ ហើយឃុំបានទេទាល់តែតំបន់ជួយមតិមកដែរ ហើយក្នុងហ្នឹងក៏មានខ្ញុំដែរ ជួយមតិគ្នា។

[១៥:៣៧:៣៥]

**សះ** នៅពេលដែលលោកស្រីនៅតំបន់៣៥ ហើយលោកស្រីបានធ្វើទំនប់ ក៏ដូចជីកប្រឡាយនោះតើលោកស្រីមានដែលឃើញមេដឹកនាំខ្ពស់ៗគាត់មកពិនិត្យមើលប្រឡាយ ឬទំនប់ទាំងនោះទេ?

**ឆះ** អត់ផង។

**សះ** មួយទៀតទាក់ទងនឹងចម្លើយរបស់លោកស្រីពីព្រឹកមិញ ក៏ដូចជាពីរម៉ោងខាងមុខនេះលោកស្រីថា នៅខេត្តកំពង់ចាម លោកស្រីថា មានមន្ទីរសន្តិសុខ ប៉ុន្តែខ្ញុំចង់ដឹងថា តើនៅតំបន់៣៥ នៅ

ខេត្តកំពត តើនៅទីនោះមានមន្ទីរសន្តិសុខទេ?

**ឆ៖** អត់ដឹងមានអត់ ខ្ញុំមិនបានសួរតំបន់ដែរ គាត់រៀបរយ។ ខ្ញុំមិនអ្នករៀបរយ គាត់រៀបរយ មិនដឹងគាត់ដាក់កន្លែងណា ខ្ញុំមិនដែលបានសាកសួរគាត់ដែរ ព្រោះមន្ទីរសន្តិសុខរបស់គាត់។ គាត់អ្នកចាត់ចែង។

[១៥:៣៨:៣៣]

**ស៖** នៅក្នុងនាមលោកស្រីជាសមាជិកទី៦ នៃគណៈតំបន់៣៥ លោកស្រីមានធ្លាប់ដែលទៅប្រជុំជាមួយនឹងគណៈភូមិភាគទេ?

**ឆ៖** ខ្ញុំប្រជុំជាមួយ តាម៉ុក។

**ស៖** លោកស្រីធ្លាប់ប្រជុំជាមួយ តាម៉ុក?

**ឆ៖** ចាស។

**ស៖** ហើយប្រជុំជាមួយ តាម៉ុក ហ្នឹងតើនៅពេលប្រជុំហ្នឹងតើគេពិភាក្សាពីរឿងអីដែរ ជាមួយ តាម៉ុក?

**ឆ៖** អត់មាននិយាយរឿងអីផង។ គាត់និយាយពីការកសាងទំនប់ ប្រឡាយដែរហ្នឹង គាត់មិននិយាយពីរឿអីផង។ ឲ្យយើងប្រឹងប្រែងធ្វើទំនប់ប្រឡាយយើងឲ្យបាន ដូចថា ប្រព័ន្ធភ្លឺអីចឹងទៅណា ទំនប់ប្រឡាយយើងឲ្យច្រើនអីចឹងទៅ គាត់ពិភាក្សាតែរឿងបញ្ហាហ្នឹង អត់មាននិយាយពីរឿងអីទៀតទេ ហ្នឹងបានខ្ញុំចូលរួមជាមួយគាត់ដែរកាលជំនាន់នោះ បានប្រជុំជាមួយគាត់ដែរ។

**ស៖** ខ្ញុំសូមសួរសំណួរបន្ថែមមួយទៀត ទាក់ទងនឹងពេលគេបញ្ជូនលោកស្រីពីភូមិភាគនិរតីទៅភូមិភាគកណ្តាល គឺពីខេត្តកំពតទៅកំពង់ចាម។ នៅពេលដែលគេសម្រេចបញ្ជូនលោកស្រី ពីភូមិភាគនិរតីទៅភូមិភាគកណ្តាលហ្នឹង តើនៅក្នុងតំបន់របស់លោកស្រីមានការបញ្ជូនមនុស្សពីតំបន់របស់លោកស្រីប៉ុន្មាននាក់ដែរ? ឬក៏មានតែលោកស្រីទេ?

[១៥:៤០:០០]

**ឆ៖** កាលនុ៎ង ខ្ញុំទៅ មានម៉ែខ្ញុំ បងប្អូនខ្ញុំមួយក្រុមខ្ញុំ អត់មានអ្នកក្រៅទៅជាមួយផង។ ខ្ញុំអត់យកទៅ វាឆ្ងាយពេក។ ហើយម្យ៉ាងគេ ចិត្តគេក៏មិនចង់ទៅ ខ្ញុំយកបងប្អូនខ្ញុំទៅ សាច់ញាតិសន្តានខ្ញុំហ្នឹងទៅជាមួយខ្ញុំ។

**ស៖** អ៊ីចេះ សំណួរចង់សួរថា អត់ចង់និយាយទាក់ទងនឹងញាតិទេ។ ចង់និយាយថា អ្នកដែល

ធ្វើការនៅក្នុងគណ:ស្រុក ក៏ដូចជាអ្នកដែលធ្វើការនៅក្នុងតំបន់ហ្នឹង តើមានការផ្លាស់ប្តូរ? ឬមានបញ្ជូនចេញពីខេត្តកំពតទេ នៅពេលដែលគេបញ្ជូនលោកស្រីចេញពីខេត្តកំពតនោះ?

**ឆ៖** កាលហ្នឹង ខ្ញុំទៅម្នាក់ឯង ប៉ុនដល់ក្រោយមក ខ្ញុំទៅដល់កំពង់ចាមតែគ្រួសារសាច់ញាតិខ្ញុំ ប៉ុនក្រោយមកឃើញមិនដឹងខាងណាបញ្ជូនទៅ គេបញ្ជូនទៅនៅខ្លះដែរ ប៉ុនដូចថាប្អូនដប់នាក់ដែរហ្នឹង។ ប៉ុនក្រោយខ្ញុំ ខ្ញុំអត់បានដឹងទេ ព្រោះខ្ញុំទៅមុនគេ។ មិនដឹងគេ-- គាត់ជូនដាក់ណាខ្លះ ប៉ុនទៅៗហើយ។ ប៉ុនមិនដឹងឈ្មោះអីខ្លះៗ ខ្ញុំមិនបានស្គាល់ទេ។ ដូចឧទាហរណ៍ទៅនៅស្រុកចម្ការលើ ស្រុកអីដែរហ្នឹង ប៉ុនថាមិនដឹងឈ្មោះអីខ្លះ ហើយគាត់បញ្ជូនទៅនៅ-- ទៅកន្លែងណាខ្លះ ខ្ញុំវាមិនបានដឹង។

**ស៖** អ៊ីចឹងមានន័យថា នៅពេលហ្នឹងមានការបញ្ជូនអ្នកផ្សេងដែរ?

**ឆ៖** ចាស ប៉ុនបញ្ជូនដែរ ប៉ុនខ្ញុំអត់ដឹងថាប៉ុន្មាននាក់ កន្លែងណាខ្លះ។ ខ្ញុំគ្រាន់តែឃើញ គ្រាន់តែបញ្ជូន ប៉ុនវាអត់បានជួបគ្នាទេ ព្រោះខ្ញុំនៅស្រុកខ្ញុំ គេនៅកន្លែងគេ ខ្ញុំមិនបានឃើញ។

[១៥:៤១:២៧]

**ស៖** នៅពេលដែលលោកស្រីទៅដល់កំពង់ចាម នៅស្រុកកំពង់សៀម លោកស្រីធ្វើជាប្រធានតំបន់៤១ មែនទេលោកស្រី?

**ឆ៖** អត់ទេ ខ្ញុំធ្វើសមាជិកទី៦។

**ស៖** នៅទីរួមខេត្តកំពង់ចាម?

**ឆ៖** ចាស។

**ស៖** នៅពេលដែលលោកស្រីទៅដល់ទីនោះ លោកស្រីទៅជំនួសកន្លែងអ្នកផ្សេង អ្នកចាស់ តើលោកស្រីដឹងថា អ្នកដែលធ្លាប់ធ្វើការនៅកន្លែងលោកស្រីទៅជំនួសហ្នឹង តើគេយកគាត់ទៅណាដែរ?

**ឆ៖** អត់ដឹង។ ខ្ញុំទៅគេ ឃើញតែកន្លែង អត់មានមនុស្សផង។ ខ្ញុំទៅនៅក្រោយគេ ខ្ញុំអត់ឃើញមានមនុស្សផង។

**ស៖** ទាក់ទងនឹង ទៅដល់ទីរួមខេត្តកំពង់ចាម ជាពិសេសគឺស្រុកកំពង់សៀម តើលោកស្រីមានដែលបានជួបមនុស្សម្នាក់ឈ្មោះ ចាន់ ចក្រី ទេ លោកស្រី?

**ឆ៖** ហ្នឹងជាប់ ចុះខ្ញុំស្រុកជិតនៅ ហើយ ចក្រី កងទ័ពនៅជាប់ហ្នឹង ប៉ុនខ្ញុំស្គាល់ពេលកងទ័ពហ្នឹងមកបុករុកនៅកន្លែងទេ ខ្ញុំជួបគាត់នុ៎ង។ តែឲ្យខ្ញុំជួបបិតថេរចីរកាល ខ្ញុំអត់ស្គាល់ទេ។ តែកាលនោះ កងទ័ពហ្នឹង ដូចថានៅជាប់ជាមួយប្រជាជន។ អ៊ីចឹងគាត់មកអុកឡុក ដូចថាមានរឿងអ៊ីចឹង ខ្ញុំទៅ

ជួបគាត់ ថាឥឡូវអ៊ីចេះៗ ខ្ញុំប្រាប់ខ្ញុំ។ ប៉ុនថាឲ្យខ្ញុំស្គាល់គាត់ហ្នឹង ខ្ញុំអត់ស្គាល់ទេ ព្រោះខ្ញុំទៅថ្មី។ ខ្ញុំមិនដែលស្គាល់ គ្រាន់តែឮថា ចក្រីៗ ដែរ តែខ្ញុំវាមិនបានជិតដិតអីទេ គ្រាន់តែស្គាល់គ្នាម្តងមួយយាម ប៉ុនស្គាល់តែម្តង ពេលគាត់ជួបហ្នឹងទេ។

[១៥:៤៣:០៥]

**ស៖** នៅពេលដែលលោកស្រីទៅធ្វើការងារនៅស្រុកកំពង់សៀម នៅខេត្តកំពង់ចាមហ្នឹង តើលោកស្រីអាចរៀបរាប់បានទេ ថារចនាសម្ព័ន្ធរដ្ឋបាល ក៏ដូចជារចនាសម្ព័ន្ធផ្សេងៗហ្នឹង វាមានលក្ខណៈដូចជានៅខេត្តកំពត? ឬក៏មានកលក្ខណៈខុសគ្នា?

**ឆ៖** អត់ដឹងដែរ ព្រោះអាហ្នឹង ការរៀបចំរបស់គណៈភូមិភាគហ្នឹង ខ្ញុំមិនដែលបានចូលរួមទេ ហ្នឹងគាត់រៀបចំម៉េចទេ ព្រោះនៅខេត្តកំពត អាហ្នឹងយើងនៅនេះ។ ប៉ុនខ្ញុំទៅកំពង់ចាម មិនដឹងគាត់រៀបរយម៉េចខាងគណៈភូមិភាគ។ មិនដឹងរចនាសម្ព័ន្ធគាត់យ៉ាងម៉េច ខ្ញុំមិនសូវដឹងដែរ។

**ស៖** នៅពេលដែលលោកស្រីទៅដល់កំពង់ចាម នៅពេលនោះ លោកស្រីមានកិច្ចប្រជុំជាមួយនឹងគណៈស្រុកនៅខេត្តកំពង់ចាមទេ?

**ឆ៖** ខ្ញុំទៅដល់មុនដំបូង គឺគណៈភូមិភាគ គាត់ប្រជុំជាមួយខ្ញុំ រៀបរយឲ្យខ្ញុំមកនៅស្រុកកំពង់សៀម។ ហើយដល់ពេលក្រោយមក គាត់មកប្រជុំរួមជាមួយខ្ញុំហ្នឹង នៅក្នុងស្រុកកំពង់សៀម ឲ្យរៀបរយគណៈកម្មការអី គាត់ចាត់ចែងទៅ ខ្ញុំក៏ធ្វើតាមគាត់។

**ស៖** នៅពេលដែលលោកស្រីទៅដល់ស្រុកកំពង់សៀម នៅពេលដែលមានកិច្ចប្រជុំជាមួយគណៈស្រុក ឬក៏គណៈតំបន់ផ្សេងៗហ្នឹង តើលោកស្រីមានផែនការក្នុងការផ្លាស់ប្តូរគណៈស្រុកចាស់ ឬមួយក៏មានផែនការក្នុងការផ្លាស់ប្តូរគណៈឃុំចាស់ដែរឬទេ?

[១៥:៤៤:៥១]

**ឆ៖** ខ្ញុំអត់ទាន់មានការផ្លាស់ប្តូរផង។ ព្រោះខ្ញុំទៅ បើគេនៅចាស់ៗ ខ្ញុំអត់ដែរផ្លាស់ប្តូរទេ។

**លោក សំ សុគង់៖**

បាទ សូមអរគុណលោកប្រធាន ដោយសារខ្ញុំអស់សំណួរហើយ ខ្ញុំទុកឲ្យសហការីរបស់ខ្ញុំខាងអន្តរជាតិដើម្បីគាត់តនូវសំណួរ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញមេធាវី!

[១៥:៤៥:២៣]

**សួរដោយកញ្ញា ហ្វីលីពីន ស៊ុតហ្ស៍៖**

សូមអរគុណលោកប្រធាន សូមគោរពភាគីទាំងអស់។ ជម្រាបសួរសាក្សី។ ខ្ញុំនឹងសួរឲ្យបានលឿនព្រោះខ្ញុំនៅសល់ពេលតិច។ ខ្ញុំជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំនឹងសួរសំណួរមួយចំនួនទៅកាន់លោកស្រី។

**ស៖** ខ្ញុំចង់ត្រឡប់មកសួរអំពីកាលប្រវត្តិមួយចំនួន ព្រោះថាម្សិលមិញលោកនិយាយថា លោកស្រីបានចូលបដិវត្តន៍នៅឆ្នាំ៧០ ហើយលោកស្រីបានបញ្ជាក់ថា កើតនៅឆ្នាំ១៩៤៧។ បើសិនបើខ្ញុំគណនាមើលទៅ គឺថាលោកស្រីអាយុប្រហែល២៣ឆ្នាំហើយៗលោកស្រីបានបញ្ជាក់ជូនថា លោកស្រីមានអាយុត្រឹមតែ១៣ឆ្នាំទេ នៅពេលដែលចូលបដិវត្តន៍នោះ។ ហើយលោកក៏បានបញ្ជាក់ថា គឺនៅកំពង់ស្ពឺ ហើយព្រឹកមិញនេះលោកស្រីបញ្ជាក់ជូនដល់សហព្រះរាជអាជ្ញា គឺថានៅខេត្តតាកែវ។ អ៊ីចឹងថាលោកស្រីអាចបញ្ជាក់ឲ្យបានច្បាស់បន្តិចទេ? ហើយលោកស្រីអាចគិតមើលពីកាលបរិច្ឆេទនេះឲ្យបានច្បាស់បន្តិចទេ? សូមអញ្ជើញលោកស្រីបញ្ជាក់។

[១៥:៤៦:៣១]

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំស្រុកកំណើតនៅតាកែវ មិននៅកំពង់ស្ពឺទេ។

**ស៖** បាទ ខ្ញុំយល់ច្បាស់ ខ្ញុំដឹងច្បាស់ ប៉ុន្តែលោកស្រីជាអ្នកនិយាយខ្លួនឯងទេ ថាលោកស្រីបានចូលបដិវត្តន៍នៅខេត្តតាកែវនៅឆ្នាំ១៩៧០។ ដូច្នេះ គឺលោកស្រីមានអាយុ២៣ឆ្នាំហើយនៅពេលនោះ ហើយលោកស្រីទើបតែបញ្ជាក់ជូនសហភាតារបស់ខ្ញុំថា លោកស្រីមានអាយុត្រឹមតែ១៣ឆ្នាំទេ នៅពេលដែលលោកស្រីចូលបដិវត្តន៍នោះ។ ដូច្នេះខ្ញុំអត់ច្បាស់ទេ ថាតើមិនដឹងថាលោកស្រីអាយុប៉ុន្មានឲ្យច្បាស់? សូមឲ្យលោកស្រីពន្យល់ឲ្យច្បាស់បន្តិចមើល ថាចូលមុនឆ្នាំ៧០ ឬក៏យ៉ាងម៉េច?

[១៥:៤៧:១៦]

**ឆ៖** ខ្ញុំសូមចម្លើយថា ពេលនោះខ្ញុំក៏វង្វេងវង្វាន់ដែរ ព្រោះវាចូលមកមិនដឹងឆ្នាំណាៗ ខ្ញុំមិនគិតជាឆ្នាំជាអាយុអីទេ។ អានេះខ្ញុំសូមអត់ទោស ហើយថាដូចវាមិនចាំតែម្តង មិនចូលឆ្នាំណា អីឆ្នាំណា។ ទើបដល់លោកមានការវិភាគថា ឥឡូវ២៣, ២០ ខ្ញុំគឺវាអត់ចាំអាយុខ្លួនឯងដែរ។ មិនដឹងចូលឆ្នាំណា? នៅថ្ងៃណា ខែណា? អ៊ីចឹងខ្ញុំរកអត្ថាធិប្បាយអត់កើត។ នេះសូមជម្រាបត្រង់ៗតែម្តង ដល់លោក។ ខ្ញុំ

មានមតិប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ ដូច្នេះ ខ្ញុំចូលទៅដល់សំណួរមួយទៀត នៅរបបកម្ពុជាប្រជាធិបតេយ្យ តើលោកស្រីមានឈ្មោះហៅក្រៅ ឬក៏រហស្សនាមអីទេ?

[១៥:៤៨:១២]

**ឆ៖** ខ្ញុំឈ្មោះអ៊ីចឹងតែម្តង។ ប្រាក់ យុត អ៊ីចឹងតែម្តងតាំងពីដើមមក។

**ស៖** តើលោកស្រីមិនដែលមានឈ្មោះថា យាយ យុត ឬក៏យាយ ម្លូ? តើលោកស្រីធ្លាប់មានឈ្មោះថា យាយ យុត ឬយាយ ម្លូ ទេ?

**ឆ៖** ពាក្យសម្រាយរបស់ប្រជាជនគេហៅម៉េចក៏បាន ព្រោះយើងហួបម្លូក៏មាន គេធ្វើម៉េចក៏បានស្រេចគេថា។ ប៉ុន្តែការពិត ខ្ញុំឈ្មោះ ប្រាក់ យុត អ៊ីចឹងតែម្តង មិនមែនយាយម្លូ អាហ្នឹងជាពាក្យសម្រាយរបស់ប្រជាជនហើយ តាមគាត់និយាយតើ! គាត់ហៅម៉េចហៅទៅ ប៉ុន្តែការពិតខ្ញុំ ប្រាក់ យុត អ៊ីចឹងតែម្តង តាំងពីដើមមករហូត។ យាយម្លូ, យាយយុត អីហ្នឹងអាហ្នឹងឈ្មោះខ្ញុំដែលហ្នឹង។ ប៉ុន្តែយាយម្លូ ដូចថាខ្ញុំហួបម្លូអ៊ីចឹង ប្រជាជនហៅម៉េចក៏បាន។ តើយើងមិនធ្វើម៉េចគាត់។ នេះខ្ញុំសូមជម្រាបត្រង់ហើយណ៎ា មិនមែនទៅនិយាយថា អី!ខឹងអី អត់ទេ។ ប៉ុន្តែអាហ្នឹងខ្ញុំឈ្មោះដើមឈ្មោះ ប្រាក់ យុត អ៊ីចឹង។ ប៉ុន្តែគេហៅយាយម្លូ អី អាហ្នឹងគេហៅម៉េចហៅទៅ ព្រោះយើងហួបម្លូ។ យាយយុត អីក៏ហៅទៅ ខ្ញុំអត់ឃាត់ទេ។ នេះសូមជម្រាប់ត្រង់។ នេះសូមមានមតិប៉ុណ្ណឹង។

[១៥:៤៩:៣២]

**ស៖** សូមអរគុណ។ ខ្ញុំនឹងសួរសំណួរមួយចំនួនទៀត ពាក់ព័ន្ធទៅនឹងបរិបទប្រវត្តិសាស្ត្រជាទូទៅនៅសម័យនោះ ហើយជាពិសេសគឺនៅមុនឆ្នាំ៧៥។ លោកស្រីបានបញ្ជាក់ពីព្រឹកមិញនេះថា បានចូលបក្ស។ តើលោកស្រីអាចបញ្ជាក់ឈ្មោះបក្ស ដែលលោកស្រីបានចូលរួមនោះបានទេ?

**ឆ៖** អត់ចាំទេ។

**ស៖** តើជាបក្សកុម្មុយនីស្តកម្ពុជា?

**ឆ៖** ខ្ញុំអត់ច្បាស់លាស់បញ្ហាហ្នឹងដែរ។ សូមឆ្លើយខ្លីអ៊ីចឹងតែម្តង អត់យល់។

**ស៖** តើលោកស្រីស្គាល់ឈ្មោះអ្នកដឹកនាំបក្ស ដែលលោកស្រីចូលរួមនោះទេ?

**ឆ៖** ខ្ញុំអត់ស្គាល់ផង។

**ស៖** តើលោកស្រីធ្លាប់ឮគណៈអចិន្ត្រៃយ៍ទេ?

**ឆ៖** ពេលហ្នឹងខ្ញុំធ្លាប់ឮដែរ ប៉ុន្តែគណៈអចិន្ត្រៃយ៍ហ្នឹង មិនដឹងថាយ៉ាងម៉េចដែរទេ វាអត់ច្បាស់លាស់ខ្លួនឯងដែរទេ។ នេះសូមជម្រាបខ្លីអ៊ីចឹង។

**ស៖** តើលោកស្រីមិនដឹងទេអំពីតួនាទីរបស់គណៈអចិន្ត្រៃយ៍នេះ?

**ឆ៖** ចាស អត់ដឹងទេ។

[១៥:៥១:៤២]

**ស៖** តើលោកស្រីស្គាល់ឈ្មោះមួយចំនួននៃគណៈអចិន្ត្រៃយ៍ទេ?

**ឆ៖** ចាស អត់ច្បាស់សួរម្តងទៀត។

**ស៖** តើលោកស្រីស្គាល់សមាជិកមួយចំនួនរបស់គណៈអចិន្ត្រៃយ៍ដែរឬទេ?

**ឆ៖** ខ្ញុំអត់យល់បញ្ហា។

**ស៖** តើលោកស្រីធ្លាប់ឮពាក្យថា គណៈមជ្ឈិមទេ?

**ឆ៖** ខ្ញុំមិនធ្លាប់ឮទេ។

**ស៖** នៅពេលដែលលោកស្រីចូលបដិវត្តន៍ តើលោកស្រីធ្លាប់ឮឈ្មោះ ខៀវ សំផន, អៀង សារី ឬក៏ នួន ជា ទេ?

**ឆ៖** អត់។

**កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍៖**

ខ្ញុំមិនបានឮចម្លើយតាមការបកប្រែទេ។

[១៥:៥៣:១៨]

**ប្រធានអង្គជំនុំ៖**

មេធាវីសួរសំណួរម្តងទៀត សួរសំណួរចុងក្រោយអំមិញម្តងទៀត។

**សួរដោយកញ្ញា ហ្វីលីពីន ស៊ុតហ្ស៍៖**

**ស៖** តើលោកស្រីធ្លាប់ឮឈ្មោះ នួន ជា, អៀង សារី និង ខៀវ សំផន ដែរទេ នៅពេលដែលលោកស្រីចូលបដិវត្តន៍នោះ?

**ប្រធានអង្គជំនុំ៖**

លោកស្រី ប្រាក់ យុត អាចឆ្លើយនឹងសំណួរនេះបានទេ? បើបានសូមអញ្ជើញឆ្លើយ។

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ឆ្លើយ បើខ្ញុំ-- ធ្លាប់ឮ ធ្លាប់ដឹងដែរ ប៉ុន្តែធ្លាប់តែឮ មិនស្គាល់ច្បាស់លាស់។ សូមឆ្លើយប៉ុណ្ណឹង។

**សួរដោយកញ្ញា ហ្វីលីពីន ស៊ុតហ្ស៍៖**

**ស៖** តើលោកស្រីអាចបញ្ជាក់ជូនបានទេថា លោកស្រីដឹងអីខ្លះពីអ្នកទាំងអស់នេះនៅសម័យនោះ?

**ឆ៖** ខ្ញុំអត់ដឹង ដឹងសម័យនោះគាត់ធ្វើអីខ្លះ ខ្ញុំអត់ដឹងដែរ។

[១៥:៥៣:៤៦]

**ស៖** ខ្ញុំនឹងចូលទៅកាន់សំណួរផ្សេងទៀត។ ពាក់ព័ន្ធទៅនឹងរយៈកាលដែលលោកស្រីនៅខេត្តកំពត គឺនៅតំបន់៣៥ គឺចាប់ពីឆ្នាំ៧៣។ លោកស្រីបានបញ្ជាក់ថា លោកស្រីនៅខេត្តកំពត ក្នុងឋានៈជាលេខាស្រុកនៃតំបន់៣៥ នៅចាប់ពីឆ្នាំ៧៣មក គឺមានន័យថាពីរឆ្នាំមុននឹងពេលដណ្តើម-- ខ្មែរក្រហមដណ្តើមយករាជធានីភ្នំពេញបាន។ តើនេះមានន័យថានៅឆ្នាំ១៩៧៣ គឺតំបន់នេះស្ថិតនៅក្រោមការត្រួតត្រារបស់ខ្មែរក្រហមហើយមែនទេ?

**ឆ៖** ចាស កាលនុំងនៅជំនាន់ខ្មែរក្រហម។

**ស៖** តើលោកស្រីអាចរៀបរាប់អំពីការរៀបចំនៃភូមិភាគនេះនៅឆ្នាំ៧៣បានទេ គឺមុនឆ្នាំ៧៥ គឺមុនពេលខ្មែរក្រហមវាយយកភ្នំពេញបាន។ ថាតើការរៀបចំនេះ គឺដូចគ្នាទៅហ្នឹងអ្វីដែលលោកស្រីបានរៀបរាប់កាលពីព្រឹកមិញនេះ ក្រោយឆ្នាំ៧៥ដែរឬទេ?

**ឆ៖** ខ្ញុំមិនអាចរៀបរាប់បានទេ នៅគណៈភូមិភាគមិនដឹងគាត់រៀបរយយ៉ាងម៉េចទេ។ មិនដឹងគាត់ដាក់ គាត់ធ្វើយ៉ាងម៉េច ខ្ញុំមិនបានដឹងទេ ព្រោះក្នុងគណៈភូមិភាគហ្នឹង គាត់មិនដឹងរៀបរយយ៉ាងម៉េច។ ខ្ញុំវាមិនបានច្បាស់លាស់ដែរ។

[១៥:៥៦:៤៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន ខ្ញុំសូមទោសចំពោះការរំខាននេះ។ ពីព្រឹកមិញច្បាស់ហើយថា គាត់

បានថា គាត់មិនបានដឹងអំពីបញ្ហាថ្នាក់ភូមិទេ។ បន្ទាប់ពីគាត់បានប្រាប់អំពីកិច្ចការរបស់គាត់ គឺថាគាត់មិនអាចផ្តល់ចម្លើយនេះបានដូចបំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ។ ខ្ញុំសូមលើកឡើងថា កាលដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទៅហួសពីដែនសមត្ថកិច្ចរបស់គាត់ ដែលត្រូវបានសួរគាត់យ៉ាងច្បាស់លាស់រួចមកហើយ ដោយសហព្រះរាជអាជ្ញា។ ដូច្នេះមិនគួរសួរដដែលៗម្តងទៀតនោះទេ។

**កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍៖**

ខ្ញុំចង់ឆ្លើយតបទៅនឹងបញ្ហានេះ លោកប្រធាន។ សំណួររបស់ខ្ញុំហ្នឹង គឺពាក់ព័ន្ធទៅនឹងសម័យកាលមុនឆ្នាំ៧៥ គឺបរិបទប្រវត្តិសាស្ត្រ ខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់ថា តើរចនាសម្ព័ន្ធ ប្រហែលជាពាក្យ "ភូមិភាគ" នេះ មិនមែនជាពាក្យដែលខ្ញុំចង់ប្រើ។ ប៉ុន្តែអ្វីដែលខ្ញុំដឹងនោះ គឺរចនាសម្ព័ន្ធរបស់តំបន់៣៥ ខ្ញុំចង់ដឹងថា តើមុនឆ្នាំ៧៥ ហើយនិងក្រោយឆ្នាំ៧៥ហ្នឹង តើរចនាសម្ព័ន្ធវាដូចគ្នា ឬក៏មានការខុសគ្នា?

[១៥:៥៨:២០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៥៨:៤៩]

**ប្រធានអង្គជំនុំ៖**

ជំទាស់របស់មេធាវីការពារក្តី នួន ជា គ្មានប្រសិទ្ធភាព។ អង្គជំនុំជម្រះត្រូវស្តាប់នូវចម្លើយនេះ។ សាក្សី សូមសាក្សីឆ្លើយតបទៅនឹងសំណួរដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានសួរអម្បាញ់មិញ។ ប្រសិនជាអាចឆ្លើយបាន ហើយបើស្តាប់នូវសំណួរមិនទាន់ទេ អាចសុំឲ្យមេធាវីតាំងសំណួរសាជាថ្មី។

ទំនងជាភ្លេចសំណួរហើយ លោកស្រីមេធាវីតាំងសំណួរអម្បាញ់មិញសាជាថ្មីម្តងទៀត ដើម្បីឲ្យគាត់បានស្តាប់បានជាក់ច្បាស់នូវសំណួរដែលសួរចំពោះគាត់ដើម្បីគាត់ឆ្លើយតប។

**សួរដោយកញ្ញា ហ្វីលីពីន ស៊ុតហ្ស៍៖**

**ស៖** លោកប្រធាន ខ្ញុំនឹងសួរដោយខ្លី ពីព្រោះពេលវេលាទៅលឿនណាស់។ តើនៅឆ្នាំ១៩៧៣ រចនាសម្ព័ន្ធនៅតំបន់កំពតហ្នឹងគឺដូចគ្នាទៅនឹងអ្វីដែលលោកស្រីបាននិយាយរៀបរាប់កាលពីព្រឹកមិញនេះ គឺស្រុក តំបន់ ហើយនិងភូមិភាគ។ តើវាដូចគ្នាទេ?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ដូចជាមិនយល់សំណួរហ្នឹង សូមឲ្យសួរឲ្យច្បាស់ដែរហ្នឹង។ ដូចថា ចង់ឲ្យនិយាយថា

តំបន់ ភូមិភាគ ហើយនិងស្រុក អាហ្នឹងយើងចង់និយាយថា រៀបរយអំពីការរៀបរយ រៀបចំរចនាសម្ព័ន្ធហ្នឹង វាដូចគ្នាអត់? រឿងនេះវាយ៉ាងម៉េច? ខ្ញុំដូចមិនយល់សំណួរ។ សូមឲ្យលោកស្រីសួរបញ្ជាក់ម្ដងទៀត។ ព្រោះខ្ញុំបានឆ្លើយហើយព្រឹកមិញ តែសំណួរនេះយកមកសួរទៀត។

**ស៖** លោកស្រី ខ្ញុំចង់ៗទៅចូលទៅសំណួរបន្ទាប់ទៀត ហើយខ្ញុំបិទ។ តើនៅឆ្នាំ១៩៧៣ នៅតំបន់៣៥ តើមានសហករណ៍ហើយឬនៅ?

**ផ៖** ខ្ញុំបានឆ្លើយរួចហើយ មានតើ។ ឆ្នាំ៧៣ មានសហករណ៍។ មានសហករណ៍ចាត់តាំងហើយ គឺឆ្នាំ៧៣។ ប៉ុន្តែមិនទាន់បានរៀបរយធំដុំអីទេ គ្រាន់តែរៀបរយជាតូចតាចនៅឡើយ។

[១៦:០១:៤៥]

**ស៖** សូមអរគុណ។ ខ្ញុំនឹងចូលទៅកាន់ប្រធានមួយផ្សេងទៀត ខ្ញុំចង់ត្រឡប់មកនិយាយអំពីសម័យដែលលោកស្រីនៅខេត្តកំពង់ចាម គឺនៅស្រុកកំពង់សៀម។ លោកស្រីបាននិយាយកាលពីព្រឹកមិញថា លោកស្រីជាលេខាស្រុកកំពង់សៀម។ តើលោកស្រីមានឋានៈអីឲ្យពិតប្រាកដទៅ?

**ផ៖** ខ្ញុំធ្វើលេខាស្រុកកំពង់សៀម គឺខ្ញុំឋានៈខ្ញុំប្រធានហ្នឹងតែម្ដង។ អាហ្នឹងពិតប្រាកដ។ អាហ្នឹងឋានៈរបស់ខ្ញុំ។

**ស៖** នៅសម័យនោះ តើលោកស្រីមានតួនាទីផ្សេងទៀតនៅថ្នាក់ស្រុក អ៊ំនៅថ្នាក់តំបន់ និងថ្នាក់ភូមិភាគដែរឬទេ?

**ផ៖** អត់ទេ។ ខ្ញុំនៅតំបន់៤១ តែខ្ញុំក្ដាប់នៅស្រុកកំពង់សៀម។ ខ្ញុំជាលេខា តែភូមិភាគខ្ញុំអត់បានជាប់ទេ។

**ស៖** តើ គឺថាលោកស្រី គឺថាស្ថិតនៅក្នុងជាសមាជិកនៃគណៈតំបន់៤១ មែនទេ?

**ផ៖** នៅក្នុងគណៈតំបន់៤១ សមាជិកទីប្រាំមួយ អ៊ំទីៗប៉ុន្មានទេភ្លេចហើយ។

[១៦:០៣:៤២]

**ស៖** ខ្ញុំចង់ឲ្យលោកស្រីមានការចងចាំបន្តិចចំពោះរឿងហ្នឹង។ លោកស្រីបានឆ្លើយទៅនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយសាក្សីលេខ D234/4 ហើយលេខ ERN ជាភាសាអង់គ្លេស 00751716។ 'នៅកំពង់សៀម គឺខ្ញុំជាគណៈកម្មាធិការស្រុកកំពង់សៀម ហើយជាសមាជិកទីបួននៃតំបន់៤១"។ តើលោកស្រីអាចបញ្ជាក់អំពីអ្វីដែលលោកស្រីបាននិយាយនៅក្នុងកំណត់ហេតុនេះបានទេ?

[១៦:០៤:៣៤]

**ឆ៖** ខ្ញុំមិនអាចនិយាយបានទេ ព្រោះខ្ញុំភ្លេច។ ខ្ញុំចាំថា ខ្ញុំសមាជិកទីបួននៅក្នុងគណៈតំបន់៤១ ហ្នឹង តែក្រៅពីនេះ ខ្ញុំមិនអាចអត្ថាធិប្បាយបានទេ ព្រោះខ្ញុំភ្លេច។ ខ្ញុំភ្លេចតែម្ដង។ ដូចថានិយាយហើយ ដូចថាខ្ញុំមានការភ្លេចភ្លាំងដែរ។ វាមិនចងចាំទាំងអស់។

**កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតលើកឡើងនូវឯកសារមួយ នៅក្នុងសំណុំរឿង គឺជាការការស្ដាប់ចម្លើយ-- គឺការសម្ភាសសាក្សីគឺលេខ TCW-695 តើលោកប្រធានអនុញ្ញាតឲ្យខ្ញុំអាននូវសេចក្ដីសម្រង់នេះបានទេ?

**ប្រធានអង្គជំនុំ៖**

បង្ហាញពីអត្តសញ្ញាណឯកសារជាមុនសិន។ ឯកសារហ្នឹងនៅក្នុងសំណុំរឿងដែរឬទេ? ហើយលេខ ERN ជាបីភាសាយ៉ាងដូចម្ដេចដែរ ដើម្បីឲ្យភាគីផ្សេងទៀតបានស្ដាប់បាន នូវបញ្ហានេះផង។

**កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍៖**

គឺឯកសារដែលមានលេខ D232/9 ERN ជាភាសាអង់គ្លេស 00390077 ERN ជាភាសាបារាំង 00424036 ហើយនិង ERN ជាភាសាខ្មែរ 00373510។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីការពារក្ដី នួន ជា!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំហាក់មានការច្របូកច្របល់បន្តិច។ ខ្ញុំនៅពេលដែលយើងសួរទៅអនុប្រធាន ស៊ី.ឌី.ខេម គឺថាសាក្សីរូបនេះត្រូវស្ដាប់ចម្លើយគាត់នៅក្នុងបន្ទប់សវនាការ ខ្ញុំមិនដឹង-- ចំពោះសាក្សីនេះ ខ្ញុំមិនដឹងលេខ TC នោះទេ។ គឺខ្ញុំគិតថា វាអាចនឹងមានបញ្ហា--

**អ្នកបកប្រែ៖**

លោកប្រធានសូមការអនុញ្ញាត គាត់និយាយក្រៅក្បាលមីក្រូពេក ស្ទើរតែមិនឮសម្រាប់ខ្ញុំ។

[១៦:០៧:២៥]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីដាក់ឲ្យជិតក្បាលមីក្រូបន្តិច!

លោកស្រីមេធាវីបញ្ជាក់អំពីអត្តសញ្ញាណឯកសារម្តងទៀត។ ឯកសារហ្នឹងលេខយ៉ាងម៉េច? ដោយសារលោកស្រីប្រើលេខប្លែក ដែល TC ហ្នឹងគឺវាប្លែក អ៊ីចឹងហើយបានជាវាមានបញ្ហា បើ “D” ហ្នឹងគឺលេខឯកសារ ដែលមានប្រើប្រាស់នៅក្នុងសំណុំរឿង។ យក“D” លេខណាមួយឲ្យច្បាស់លាស់ អត្តសញ្ញាណនៃឯកសារហ្នឹង ដើម្បីដាក់ចំពោះមុខភាគី។

**កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍៖**

លោកប្រធាន។ ខ្ញុំនឹងផ្តល់លេខកូដឯកសារនេះម្តងទៀតគឺ D232/9 ហើយខ្ញុំផ្តល់លេខ ERN ហើយៗ។ បើចង់បានខ្ញុំអាចផ្តល់ជូនម្តងទៀតបាន។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការបង្ហាញឯកសារនៅលើអេក្រង់ទូរទស្សន៍ សម្រាប់ភាគីហើយនិងសាក្សីពិនិត្យ។

[១៦:០៨:៥២]

អញ្ជើញមេធាវី!

**លោក ម៉ៃខល ផេសមិន៖**

គឺខ្ញុំត្រូវបានបង្គាប់ឲ្យនិយាយឲ្យបានកៀកទៅនឹងមីក្រូហ្វូន អ៊ីចឹងថាតើអង្គជំនុំជម្រះគួរតែឲ្យខ្ញុំលើកសាជាថ្មីទេ អ្វីដែលខ្ញុំលើកឡើងអម្បាញ់មិញនេះ?

[១៦:០៩:១៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:១២:៣៥]

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវី ឯកសារដែលលោកស្រីលើកឡើង មានបំណងដាក់ដេញដោលសាក្សីរូបនេះ D232/9 នេះ តើជាឯកសារដែលសេចក្តីថ្លែងការណ៍របស់សាក្សីនៅចំពោះមុខអ្នកស៊ើបអង្កេត ឬក៏សហចៅក្រមស៊ើបអង្កេត? ឬក៏ឯកសារផ្សេង ដែលមិនមែនជាសេចក្តីថ្លែងការណ៍របស់សាក្សីរូបនេះទេ? ហើយបើសិនអ្នកផ្សេង គឺសូមបង្ហាញឲ្យច្បាស់ ហើយបើឯកសារដែលជារបស់សាក្សីរូបនេះ សូមបង្ហាញឲ្យច្បាស់ ដើម្បីអង្គជំនុំជម្រះទុកលទ្ធភាពភាគីពាក់ព័ន្ធនឹងរឿងក្តីនេះ មានមតិយោបល់ មុននឹងអង្គជំនុំជម្រះសម្រេច។

**កញ្ញា ហ្វីលីពីន ស៊ុតហ្វ៍៖**

ឯកសារនេះ គឺជាកំណត់ហេតុស្តាប់ចម្លើយសាក្សីផ្សេងមួយទៀត ដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត។ ខ្ញុំចង់គ្រាន់តែអានពីរបន្ទាត់នៅក្នុងកំណត់ហេតុនេះទេ ហើយមិនចាំបង្ហាញនៅលើអេក្រង់ទូរទស្សន៍ក៏បានដែរ។

[១៦:១៣:៥៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលើយកឯកសារដែលជាការបទសម្ភាសន៍សាក្សីផ្សេងទៀត យកមកសួរដេញដោលសាក្សីមួយផ្សេងទៀតទេ។ បញ្ហានេះ អង្គជំនុំជម្រះបានសម្រេចរួចហើយ កាលពីអំឡុងពេលនៃដំណើរការសវនាការដើមសប្តាហ៍នេះ ដែលសួរទៅសាក្សី 766។

ដូច្នេះ ពេលវេលារបស់លោកស្រីអស់ហើយ។ ឥឡូវនេះ ដល់ពេលម៉ោងសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្ត នៅថ្ងៃច័ន្ទ ទី៣០ ខែមករា ឆ្នាំ២០១២ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

លោកស្រី ប្រាក់ យុត អង្គជំនុំជម្រះអញ្ជើញលោកស្រីមកផ្ទាល់សក្ខីកម្មជាបន្តទៀត ហើយទំនងជាការបញ្ចប់ផងដែរ នៅថ្ងៃច័ន្ទ ទី៣០ ខែមករា ឆ្នាំ២០១២ ដើមសប្តាហ៍អាទិត្យក្រោយ។

មន្ត្រីរដ្ឋបាលតុលាការសូមសម្របសម្រួលជាមួយនឹងខាងអង្គភាពគាំពារសាក្សី ហើយនិងអ្នកជំនាញ ដើម្បីរៀបចំការធ្វើដំណើរទៅមករបស់គាត់ និងកន្លែងស្នាក់នៅសម្រាប់គាត់ដោយមានសុវត្ថិភាព។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំខ្លួនជនជាប់ចោទទាំងបីរូប ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញ ហើយឲ្យនាំខ្លួនជនជាប់ចោទបីរូបមកកាន់បន្ទប់សវនាការនេះ នៅព្រឹកថ្ងៃច័ន្ទ ទី៣០ ខែមករា ឆ្នាំ២០១២ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:១៦ នាទី)*